ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

# របាយការណ៍
# បូកសរុបលទ្ធផលការងារពាណិជ្ជកម្មឆ្នាំ២០២១
# និងទិសដៅការងារពាណិជ្ជកម្មឆ្នាំ២០២២




ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ខែធ្នូ ឆ្នាំ២០២១

# មាតិកា


សេចក្តីផ្តើម ........................................................................................................................................... ១

**ជំពូក១**

**សកម្មភាព និងលទ្ធផលការងារពាណិជ្ជកម្ម ឆ្នាំ២០២១**

**១. ការងារកំណែទម្រង់** ........................................................................................................................... ៤

១.១. រដ្ឋបាលសាធារណៈ ............................................................................................................... ៤

១.២. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........................................................................................... ៥

១.៣. វិមជ្ឈការ និងវិសហមជ្ឈការ ................................................................................................. ៦

**២. ការងារផ្តល់សេវាពាណិជ្ជកម្ម** ................................................................................................................ ៦

២.១. ការនាំចេញ-នាំចូល ............................................................................................................ ៦

២.២. ការងារកម្មសិទ្ធិបញ្ញា ........................................................................................................ ១០

២.៣. ការចុះបញ្ជីពាណិជ្ជកម្ម ........................................................................................................ ១៣

២.៤. តំណាងពាណិជ្ជកម្មប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ............................................................ ១៤

**៣. ការងារពាណិជ្ជកម្មក្នុងប្រទេស** ............................................................................................................. ១៥

៣.១. ការកសាង ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការ ដែលមានកិច្ចធានា ............................................................................................................................ ១៥

៣.២. ការអភិវឌ្ឍវិស័យឯកជន ...................................................................................................... ១៦

៣.៣. ការងារផែនការ ស្ថិតិ និងផ្សព្វផ្សាយព័ត៌មានពាណិជ្ជកម្ម ........................................................... ១៧

៣.៤. ការអនុវត្តគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច(AIMS) ...................................................... ១៨

**៤. ការងារពាណិជ្ជកម្មអន្តរជាតិ និងសមាហរណកម្មសេដ្ឋកិច្ច** ..................................................................... ២០

៤.១. ការធ្វើសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម ទ្វេភាគី អនុតំបន់ និងសមាហរណកម្មសេដ្ឋកិច្ច...២០

៤.២. ការធ្វើសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មជាមួយអឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិក................. ២០

៤.៣. កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មជាមួយទ្វីបអាម៉េរិក ............................................................... ២១

៤.៤. ការងារសមាហរណកម្មពាណិជ្ជកម្មពិភពលោក ........................................................................ ២២

៤.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងជំនួយ .................................................................. ២៣

**៥. ការងារជំរុញពាណិជ្ជកម្ម** ..................................................................................................................... ២៣

៥.១. ការរៀបចំ និងចូលរួមពិព័រណ៍ពាណិជ្ជកម្ម .............................................................................. ២៣

៥.២. ការអភិវឌ្ឍទីផ្សារ ............................................................................................................... ២៥

៥.៣. ការអភិវឌ្ឍគោលនយោបាយពាណិជ្ជកម្ម ................................................................................. ២៧

៥.៤. ការងារស្ថានតំណាងពាណិជ្ជកម្មក្រៅប្រទេស ........................................................................... ២៩

**៦. កិច្ចការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ** ................................................. ៣១

៦.១. ការងារពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពផលិតផលទំនិញ ......................................................... ៣១

៦.២. ការងារពាក់ព័ន្ធនឹងកិច្ចការពារអ្នកប្រើប្រាស់ និងបង្ក្រាបការក្លែងបន្លំ ........................................ ៣២

៦.៣. កិច្ចការទទួល និងដោះស្រាយពាក្យបណ្តឹង ............................................................................. ៣៣

៦.៤. ការងារពាក់ព័ន្ធនឹងការវិភាគគុណភាពទំនិញ ........................................................................... ៣៣

៦.៥. ការងារកំណត់បទល្មើស និងការអនុវត្តទណ្ឌកម្ម ......................................................... ៣៣
៦.៦. ការងារវិញ្ញាបនបត្រកម្ម ផលិតផលហាឡាល ......................................................... ៣៣
៦.៧. ការងារស្រាវជ្រាវសេចក្តីជូនដំណឹង ពីអនាម័យ និងភូតគាមអនាម័យ ......................... ៣៣
៦.៨. ការងារលើកកម្ពស់ការយល់ដឹងសាធារណៈ......................................................... ៣៣
៦.៩. ការងារបង្កើនសមត្ថភាពជំនាញដល់មន្ត្រី......................................................... ៣៤
៦.១០.ការចូលរួមកិច្ចប្រជុំក្នុងក្របខ័ណ្ឌជាតិ តំបន់ និងអន្តរជាតិ......................................... ៣៤
**៧. ការងារគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ** ......................................................... ៣៤
៧.១. ការគ្រប់គ្រងរដ្ឋបាលទូទៅ......................................................... ៣៤
៧.២. ការងារហិរញ្ញវត្ថុ ......................................................... ៣៤
៧.៣. ការងារបុគ្គលិក ......................................................... ៣៥
៧.៤. ការងារបណ្តុះបណ្តាល ស្រាវជ្រាវ និងភាពជាដៃគូ......................................................... ៣៧
**៨. ក្រុមហ៊ុនហ្វ្រីនគ្រេដ** ......................................................... ៤១
**៩. ការងារយេនឌ័រ** ......................................................... ៤២
**១០. ការងារអគ្គាធិការដ្ឋាន**......................................................... ៤៤
**១១. ការងារសវនកម្មផ្ទៃក្នុង** ......................................................... ៤៥
**១២. សកម្មភាពការងារមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត**......................................................... ៤៥
**១៣. ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន រាជធានី ខេត្ត** ......................................................... ៤៥
**១៤. ការងារឆ្លើយតបសភាពការណ៍ចំពោះមុខ** ......................................................... ៤៦

## ជំពូក ២
## ទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ២០២២

១. អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម......................................................... ៤៩
២. អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស......................................................... ៥១
៣. អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ ......................................................... ៥៣
៤. អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម......................................................... ៥៦
៥. អគ្គនាយកដ្ឋានកិច្ចការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ "ក.ប.ប" ............ ៥៩
៦. អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ......................................................... ៥៩
៧. ក្រុមហ៊ុនហ្វ្រីនគ្រេដ......................................................... ៦១
៨. អគ្គាធិការដ្ឋាន ......................................................... ៦១
៩. នាយកដ្ឋានសវនកម្មផ្ទៃក្នុង......................................................... ៦២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

# របាយការណ៍
## បូកសរុបលទ្ធផលការងារពាណិជ្ជកម្ម ឆ្នាំ២០២១
## និងទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ២០២២

### សេចក្តីផ្តើម

ការអភិវឌ្ឍវិស័យពាណិជ្ជកម្ម នៅតែជាអាទិភាពរបស់រាជរដ្ឋាភិបាល នៅក្នុងអភិក្រមសេដ្ឋកិច្ចទីផ្សារ ហើយមានតួនាទីគន្លឹះក្នុងការជំរុញកំណើន និងអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម។ ក្រសួងពាណិជ្ជកម្មដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលបានរៀបចំពិនិត្យ និងវាយតម្លៃលើសមិទ្ធផលការងារដែលក្រសួងសម្រេចបាន ក្នុងរយៈពេលមួយឆ្នាំកន្លងទៅ ក៏ដូចជាពិភាក្សាពីបញ្ហាប្រឈម សំណូមពរនានា និងលើកទិសដៅសម្រាប់ឆ្នាំបន្ទាប់ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦នៃរដ្ឋសភា ក្នុងបុព្វហេតុចូលរួមអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ បច្ចុប្បន្នទោះក្នុងកាលៈទេសៈដែលប្រទេសជាតិយើង និងពិភពលោកទាំងមូល នៅកំពុងជួបប្រឈមនឹងបញ្ហាពីការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលបានបង្កផលប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ និងជីវភាពរស់នៅរបស់ប្រជាជនយើងក៏ដោយ ក៏មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ រួមទាំងមន្ត្រីជាតំណាងពាណិជ្ជកម្មប្រចាំនៅក្រៅប្រទេសបានចូលរួមពិភាក្សាដោយផ្ទាល់ និងតាមរយៈប្រព័ន្ធវីដេអូ ក្នុងគោលបំណងផ្លាស់ប្តូរបទពិសោធន៍ ចែករំលែកចំណេះដឹង និងទទួលយកនូវអនុសាសន៍ល្អៗដើម្បីធ្វើជាមូលដ្ឋានក្នុងការអនុវត្តភារកិច្ចរៀងៗខ្លួនឱ្យទទួលបានប្រសិទ្ធផលនិងប្រសិទ្ធភាពខ្ពស់ និងសម្រេចបាននូវជោគជ័យតាមទិសដៅ ដែលបានគ្រោងទុកនៅក្នុងឆ្នាំ២០២១នេះ។ យោងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយក រដ្ឋមន្ត្រី** ក្នុងការប្រែក្លាយការគំរាមកំហែងពីជំងឺកូវីដ-១៩ ទៅជាឱកាសសម្រាប់ការកែទម្រង់មុតស្រួច និងស៊ីជម្រៅ ក្រសួងពាណិជ្ជកម្មបានខិតខំធ្វើការកែទម្រង់ និងបានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យពាណិជ្ជកម្ម ជាអាទិ៍ការពង្រឹងលើកស្ទួយផលិតកម្មដើម្បីផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងការនាំចេញតាមរយៈការធ្វើពិពិធកម្មទីផ្សារ សំដៅជំរុញកំណើន និងបង្កើនល្បឿនសមាហរណកម្មសេដ្ឋកិច្ច ពាណិជ្ជកម្មតំបន់ និងពិភពលោក។

ក្រោមការដឹកនាំដ៏ឈ្លាសវៃនិងប្រកបដោយគតិបណ្ឌិត របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** យើងនៅតែអាចរក្សាបាននូវកំណើននៃការនាំចេញប្រកបដោយបរិយាប័ន្ន ដោយសារតែការដាក់ចេញនូវវិធានការឆ្លើយតបជាបន្តបន្ទាប់របស់ប្រមុខរាជរដ្ឋាភិបាល ជួយដល់សហគ្រាសធុនតូចនិងមធ្យម ដើម្បីរក្សាបាននូវដំណើរការខ្សែច្រវាក់ផលិតកម្ម ផ្គត់ផ្គង់ បង្កលក្ខណៈងាយស្រួលដល់សកម្មភាពវិនិយោគ ក៏ដូចជារក្សាបាននូវការងារជូនបងប្អូនកម្មករ-កម្មការិនីរបស់យើង។

ក្នុងរយៈពេលមួយឆ្នាំកន្លងទៅនេះ ក្រសួងពាណិជ្ជកម្ម បានប្តេជ្ញាបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការជំរុញវិស័យពាណិជ្ជកម្មឱ្យកាន់តែរីកចម្រើន តាមរយៈការធ្វើកំណែទម្រង់ស៊ីជម្រៅ ការកាត់បន្ថយចំណាយ និងការពង្រឹងភាពប្រកួតប្រជែងនៃទំនិញនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ ដោយបង្កលក្ខណៈងាយស្រួល និងបង្កើតបរិយាកាសអំណោយផលដល់ការធ្វើធុរកិច្ច និងការវិនិយោគនៅក្នុងប្រទេសកម្ពុជា។ ទន្ទឹមនឹងការរក្សាបាននូវកំណើននៃការនាំចេញ តាមរយៈការប្រើប្រាស់ទីផ្សារអនុគ្រោះដែលមានស្រាប់ ក្រសួងពាណិជ្ជកម្មបានធ្វើពិពិធកម្មទីផ្សារបន្ថែមដូចជា ការចរចាបង្កើតតំបន់ពាណិជ្ជកម្មសេរីទ្វេភាគីនិងពហុភាគី ដើម្បីឱ្យទីផ្សារទំនិញ សេវាកម្ម និងវិនិយោគកម្ពុជាកាន់តែមានភាពទូលំទូលាយ។ លើសពីនេះ ការការពារកម្មសិទ្ធិបញ្ញា កិច្ចការពារអ្នកប្រើប្រាស់ ការត្រួតពិនិត្យ និងការបង្ក្រាបការក្លែងបន្លំនូវផលិតផលទំនិញ និងសេវាកម្មគ្រប់ប្រភេទ ក៏ត្រូវបានអនុវត្តដោយយកចិត្តទុកដាក់និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត។ ម៉្យាងវិញទៀត ការផ្តល់សេវាសាធារណៈជូនដល់វិស័យឯកជនក៏ត្រូវបានកែលម្អជាបន្តបន្ទាប់ឱ្យកាន់តែប្រសើរជាងមុន តាមរយៈការដាក់ឲ្យប្រើប្រាស់ទាំងស្រុងនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាទំនើប ដែលក្នុងនោះ ថ្លៃសេវា ពេលវេលា និងបែបបទដែលបង្កការលំបាកស្មុគស្មាញ ក៏ត្រូវបានកាត់បន្ថយផងដែរ ដែលនេះជាមោទកភាពមួយសម្រាប់ក្រសួងពាណិជ្ជកម្មទាំងមូល។

ក្នុងគោលដៅដើម្បីចូលរួមប្រកួតប្រជែងក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក ក្រសួងពាណិជ្ជកម្ម បាននិងកំពុងខិតខំពង្រឹងសមត្ថភាព និងប្រសិទ្ធភាពការងាររបស់មន្ត្រីរាជការបន្ថែមទៀត តាមរយៈការបន្តកសាងពង្រឹងធនធានមនុស្ស ការធ្វើកំណែទម្រង់រចនាសម្ព័ន្ធរដ្ឋបាលនិងគ្រប់គ្រង ការអភិវឌ្ឍស្ថាប័ន រួមទាំងការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្មមួយចំនួនផងដែរ។

សមិទ្ធផលសំខាន់ៗដែលសម្រេចបានក្នុងឆ្នាំ២០២១ និងទិសដៅសកម្មភាពការងារសម្រាប់ឆ្នាំ ២០២២ របស់ក្រសួងពាណិជ្ជកម្ម មានដូចខាងក្រោម៖

# ជំពូកទី១

# សកម្មភាព និង
# លទ្ធផលការងារពាណិជ្ជកម្ម
# ឆ្នាំ២០២១

## ១. ការងារកំណែទម្រង់

### ១.១. រដ្ឋបាលសាធារណៈ

#### ក. ការអភិវឌ្ឍន៍ធនធានមនុស្ស និងស្ថាប័ន

- បានចាត់បញ្ជូនមន្ត្រីឱ្យចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងវែង ទាំងក្នុង និងក្រៅប្រទេស តាមប្រព័ន្ធអនឡាញដូចជា សាលាភូមិន្ទរដ្ឋបាល វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ ប្រទេសសឹង្ហបុរី ប្រទេសចិន ប្រទេសកូរ៉េខាងត្បូង ប្រទេសជប៉ុន ប្រទេសអូស្ត្រាលី ប្រទេសឥណ្ឌា ប្រទេសអង់គ្លេស និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន
- បានបណ្តុះបណ្តាលផ្នែកបច្ចេកទេស និងរដ្ឋបាលទូទៅស្របតាមតម្រូវការរបស់អង្គភាពនីមួយៗ ដើម្បីពង្រឹងសមត្ថភាព
- បានកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្របតាមស្ថានភាពវិវត្តន៍ប្រែប្រួលជាក់ស្តែងនៃវិស័យពាណិជ្ជកម្ម។

#### ខ. ការគ្រប់គ្រងធនធានមនុស្ស និងបៀវត្ស

- បានធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការ និងស្ថានភាពក្របខ័ណ្ឌមន្ត្រីរាជការតាមស្ថានភាពជាក់ស្តែង
- បានអនុវត្តការបើកប្រាក់បៀវត្សជូនមន្ត្រីរាជការពីរដងក្នុងមួយខែតាមប្រព័ន្ធធនាគារ បានទាន់ពេលវេលា
- បានរៀបចំគ្រប់គ្រងទិន្នន័យមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យា
- បានបញ្ចូលប្រាក់បេសកកម្ម (ប្រាក់ហោប៉ៅ ហូបចុក ស្នាក់នៅ និងប្រាក់លើមធ្យោបាយធ្វើដំណើរ) ទៅក្នុងគណនេយ្យផ្ទាល់របស់ថ្នាក់ដឹកនាំ ឬមន្ត្រីរាជការសម្រាប់ការចុះបេសកកម្មក្នុងប្រទេស។

#### គ. ការបង្កើនគុណភាពសេវាសាធារណៈ

- បានចូលរួមរៀបចំប្រកាសអន្តរក្រសួងលេខ ៣១៥ សហវ.ប្រក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ស្តីពីកម្រងសេវាសាធារណៈ របស់ក្រសួងពាណិជ្ជកម្មក្នុងការកាត់បន្ថយតម្លៃសេវាសាធារណៈសំដៅជំរុញកិច្ចសម្រួលពាណិជ្ជកម្ម
- បានធ្វើប្រតិភូកម្មក្នុងការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ឌី (D) សម្រាប់ទំនិញកសិផលដល់គ្រប់មន្ទីរពាណិជ្ជកម្មខេត្តជាប់ព្រំដែន
- បានដាក់ឱ្យអនុវត្តប្រតិវេទន៍ស្វ័យបញ្ជាក់ដើមកំណើតទំនិញទូទាំងតំបន់អាស៊ាន (ASEAN-Wide Self Certification-AWSC) ដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្មក្នុងតំបន់អាស៊ាន
- បានចូលរួមអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ សម្រាប់ការចេញអាជ្ញាបណ្ណនាំចេញ-នាំចូល និងវិញ្ញាបនបត្រគីមប័រលើប្រូសេស ក្រោមប្រព័ន្ធបញ្ជរតែមួយជាតិ (National Single Window-NSW)
- បានភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ (ATIGA e-Form D) ទៅក្នុងបញ្ជរតែមួយជាតិ និងភ្ជាប់ទៅបញ្ជរតែមួយអាស៊ាន
- បានអនុវត្តគម្រោងចុះបញ្ជីអ្នកនាំចេញ (Registered Exporter System-REX) សម្រាប់ធ្វើការនាំចេញទៅកាន់សហភាពអឺរ៉ុប ប្រទេសស្វីស ណ័រវែស និងតួកគី
- បានបន្ថែម CO ទម្រង់ផ្សេងៗទៀត ស្របតាមវិធានដើមកំណើតទំនិញនៃប្រទេសនាំចូលទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម រួមមាន៖ Form ANNEX សម្រាប់នាំចេញទៅប្រទេស Japan, Form Chile សម្រាប់នាំចេញទៅប្រទេស Chile និងForm AHK សម្រាប់នាំចេញទៅហុងកុង
- បានតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញជាមួយធនាគារ សម្រាប់ទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក(E-payment)
- បានតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញគ្រប់ទម្រង់ ទៅតាមគ្រប់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស
- បានដំឡើងប្រព័ន្ធរក្សាទុកទិន្នន័យដោយស្វ័យប្រវត្ត (Install Automation Backup Server) សម្រាប់

រក្សាទុកទិន្នន័យ CO ដើម្បីការពារក្នុងករណីមានការបាត់បង់ទិន្នន័យនៅពេលម៉ាស៊ីនមេខូច

- បានកែសម្រួលលិខិតផ្សេងៗពាក់ព័ន្ធនឹងការចុះបញ្ជីម៉ាក និងកែសម្រួលកម្រៃសេវាសាធារណៈពាក់ព័ន្ធកិច្ចការចុះបញ្ជីម៉ាក
- បានរៀបចំកិច្ចប្រជុំពិភាក្សាពាក់ព័ន្ធនឹងបញ្ជីមុខទំនិញគ្រឿងបន្លាស់ ឬវត្ថុធាតុដើមពីវៀតណាមដែលត្រូវការវិធាន Extended Cumulation សម្រាប់យកមកផលិត និងនាំចេញបន្តទៅកាន់ទីផ្សារសហភាពអឺរ៉ុប
- បានរៀបចំកិច្ចប្រជុំអន្តរក្រសួង, វិស័យឯកជន, និងសង្គមស៊ីវិល ដើម្បីត្រៀមផ្សព្វផ្សាយពីយន្តការអនុគ្រោះពន្ធទូទៅថ្មីរបស់ចក្រភពអង់គ្លេស និងការបំពេញកម្រងសំណួរ ស្តីពី Consultation on the UK Trade Preference Scheme
- បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយវិស័យឯកជន ទាក់ទងនឹងវិធានដើមកំណើតទំនិញក្រោមក្របខ័ណ្ឌប្រព័ន្ធអនុគ្រោះពន្ធទូទៅរបស់ជប៉ុន (Japan's GSP)
- បានរៀបចំកិច្ចប្រជុំពិភាក្សា និងឆ្លើយកម្រងសំណួររបស់ធនាគារពិភពលោក ពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មឆ្លងកាត់ព្រំដែននៃការសម្រួលបរិយាកាសធុរកិច្ចសម្រាប់ឆ្នាំ២០២២
- បានរៀបចំកិច្ចប្រជុំពិភាក្សា លើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជាជនទីក្រុងហូជីមិញនៃប្រទេសវៀតណាម ស្តីពីការអនុវត្តកំណត់ការប្រមូលកម្រៃប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធកំពង់ផែសមុទ្រ និងសេវាកម្មចាំបាច់នានានៅច្រកព្រំដែនសមុទ្រនៅទីក្រុងហូជីមិញ
- បានរៀបចំកិច្ចប្រជុំជាមួយវិស័យឯកជនដើម្បីពិភាក្សាលើឯកសារយុទ្ធសាស្ត្រទាញយកអត្ថប្រយោជន៍ជាអតិបរមាពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី
- បានរៀបចំកិច្ចប្រជុំជាមួយគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិភាក្សាលើឯកសារយុទ្ធសាស្ត្រទាញយកអត្ថប្រយោជន៍ជាអតិបរមាពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី
- បានរៀបចំកិច្ចប្រជុំអន្តរក្រសួងដើម្បីពិនិត្យ និងផ្តល់យោបល់ លើសេចក្តីព្រាងពិធីសាររវាងសេវាកម្មសហព័ន្ធនៃសហព័ន្ធរុស្ស៊ី និងក្រសួងពាណិជ្ជកម្ម ស្តីពីកិច្ចសហប្រតិបត្តិការរដ្ឋបាល ការផ្លាស់ប្តូរព័ត៌មាន និងជំនួយទៅវិញទៅមក។

### ១.២. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

#### ក. ការរៀបចំផែនការ និងថវិកា

- បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤ ដោយផ្អែកលើគោលការណ៍ថវិកាតាមកម្មវិធី
- បានរៀបចំបញ្ជីសារពើភណ្ឌ កើនឡើង ថយចុះឆ្នាំ២០២០ និងបានបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានរៀបចំរបាយការណ៍សមិទ្ធកម្មឆ្នាំ២០២០ របាយការណ៍សមិទ្ធកម្មពាក់កណ្តាលឆ្នាំ២០២១ និងការគ្រោងលទ្ធផលរំពឹងទុកសម្រាប់ឆ្នាំ២០២២
- បានរៀបចំរបាយការណ៍ការត្រួតពិនិត្យ ដោយរំលេចនូវវឌ្ឍនភាព បញ្ហាប្រឈម និងសំណូមពរ
- បានរៀបចំរបាយការណ៍វាយតម្លៃលើការបង្កើតអង្គភាពថវិកា
- បានដាក់បញ្ចូលថវិកាដៃគូ និងថវិការបស់ក្រុមហ៊ុនហ្វ្រីនត្រេដទៅក្នុងឧបសម្ព័ន្ធនៃថវិកាប្រចាំឆ្នាំ
- បានរៀបចំកម្មវិធីចំណូល និងការព្យាករណ៍ចំណូលប្រចាំត្រីមាសទី៣ ធៀបទៅនឹងការអនុវត្តក្នុងរង្វង់ +/-៥%
- បានរៀបចំរបាយការណ៍ប្រៀបធៀបផែនការចំណាយ តាមកម្មវិធីប្រចាំត្រីមាស និងការអនុវត្តជាក់ស្តែងដោយឆ្លុះបញ្ចាំងអំពីការកំណត់គោលដៅចំណាយមិនឱ្យតិចជាង ៦៧%។

#### ខ. ការអនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS)

- បានរៀបចំរបាយការណ៍ស្តីពី "ការពិនិត្យលទ្ធភាពក្នុងការដាក់ឱ្យអនុវត្តFMISសម្រាប់ថវិកាដៃគូ និងជំនួយ"
- បានអនុវត្តចំណាយដែលមានហានិភ័យទាបដូចជាចំណាយបន្ទុកបុគ្គលិក ចំណាយទឹក ភ្លើង រាជកិច្ចពន្ធរថយន្ត និងអាករប្រៃសនីយ៍សម្រាប់ការទូទាត់ត្រង់តាមប្រព័ន្ធFMIS

- បានអនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈពេញលេញលើចំណូល និងចំណាយ
- បានអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ដើម្បីគ្រប់គ្រងចំណូល ដូចជា ចំណូលកម្រៃសេវាសាធារណៈ និងចំណូលកិច្ចសន្យា
- បានធ្វើរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជូន អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**គ. ការងារលទ្ធកម្ម**

បានកែសម្រួលការអនុវត្តផែនការលទ្ធកម្មឆ្នាំ២០២១ និងរៀបចំផែនការលទ្ធកម្មឆ្នាំ២០២២។

**១.៣. វិមជ្ឈការ និងវិសហមជ្ឈការ**

- បានចូលរួមរៀបចំជាមួយអគ្គលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងការផ្ទេរមុខងារវិស័យពាណិជ្ជកម្មទៅឱ្យថ្នាក់ក្រោមជាតិ ក្រុង ស្រុក ខណ្ឌ
- បានរៀបចំសេចក្តីសម្រេចក្នុងការផ្ទេរមន្រ្តីរាជការថ្នាក់ក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេសទៅឱ្យថ្នាក់ក្រោមជាតិ
- បានរៀបចំកែសម្រួលកម្រងសេវាសាធារណៈជាមួយក្រសួងមហាផ្ទៃ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម
- បានរៀបចំវគ្គបណ្ដុះបណ្ដាលបច្ចេកទេស ស្តីពីនីតិវិធីការអនុវត្តមុខងារវិស័យពាណិជ្ជកម្មដែលផ្ទេរទៅឱ្យថ្នាក់ក្រោមជាតិ ក្រុង ស្រុក ខណ្ឌ
- បានពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួងពាណិជ្ជកម្ម និងមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត
- បានកំពុងរៀបចំផ្ទេរបៀវត្សមន្រ្តីថ្នាក់ក្រោមជាតិចំនួន៣ខេត្ត មានដូចជា រាជធានីភ្នំពេញ ខេត្តបាត់ដំបង និងខេត្តមណ្ឌលគិរី
- បានកំពុងរៀបចំបែបបទបណ្តុះបណ្តាលមន្រ្តីថ្នាក់ក្រោមជាតិ
- បានចូលរួមកែសម្រួលប្រកាសអន្តរក្រសួង ស្តីពីការផ្តល់ប្រាក់រង្វាន់នៅថ្នាក់ក្រោមជាតិ។

**២. ការងារផ្តល់សេវាពាណិជ្ជកម្ម** [1]

**២.១. ការនាំចេញ-នាំចូល**

**ក. ការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ពាក់ព័ន្ធនឹងវិធានដើមកំណើតទំនិញ និង កិច្ចប្រជុំពាក់ព័ន្ធ**

- បានចូលរួមចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ទ្វេភាគី តំបន់ ពហុភាគី និងកិច្ចប្រជុំនានាដែលពាក់ព័ន្ធនឹងវិធានដើមកំណើតទំនិញ ក្នុងនោះរួមមាន៖ ការចរចាកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់(RCEP) ការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-ចិន(CCFTA) ការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-កូរ៉េ(CKFTA)
- បានចរចាបន្តសុពលភាពនៃកិច្ចសម្របសម្រួលជំរុញពាណិជ្ជកម្ម ទ្វេភាគីកម្ពុជា-វៀតណាម និងបន្តការចរចា និងតាមដានការអនុវត្តក្រោមក្របខ័ណ្ឌអាស៊ាន និងដៃគូអាស៊ាន ជាដើម។ល។
- បានចូលរួមកិច្ចប្រជុំពាក់ព័ន្ធនឹងវិធានដើមកំណើតទំនិញក្រោមក្របខ័ណ្ឌអាស៊ាន ដៃគូអាស៊ាន និងអាសិប រួមមាន៖
    - កិច្ចប្រជុំអនុក្រុមការងារវិធានដើមកំណើតទំនិញនៃកិច្ចព្រមព្រៀងអាសិប (The 3rd Interim RCEP SWGROO)
    - កិច្ចប្រជុំអនុគណៈកម្មាធិការវិធានដើមកំណើតទំនិញ (Sub Committee on Rule of Origin-SCROO) នៃកិច្ចព្រមព្រៀងភាពជាដៃគូគ្រប់ជ្រុងជ្រោយអាស៊ាន-ជប៉ុន (ASEAN-JAPAN

[1] ប្រភព៖ អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម

Comprehensive Partnership-AJCEP )

- កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន ( Implementation ASEAN Trade Coordinating Committee on the in Goods Agreement )
- កិច្ចប្រជុំអនុគណៈកម្មាធិការវិធានដើមកំណើតទំនិញ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន ( Commitee on ATIGA Rules of Origin-Sub )
- កិច្ចប្រជុំអនុគណៈកម្មាធិការវិធានដើមកំណើតទំនិញ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន អូស្ត្រាលី ណូវែលហ្សេឡង់ ( AANZFTA SCROO )
- បន្តកិច្ចពិភាក្សាទ្វេភាគីរវាង កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងថៃ លើបញ្ហាពោត ( Bilateral Discussion between CLM and Thai on Maize issue ) ។

**ខ. ចូលរួមវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលាពាក់ព័ន្ធការផ្ដល់សេវាពាណិជ្ជកម្ម**

- វគ្គបណ្ដុះបណ្ដាល ស្ដីពី "Rule of Origin for least Developped Countries"
- សិក្ខាសាលាផ្ទៀងផ្ទាត់លើការស្ទង់មតិ ស្ដីពី សូចនាករកិច្ចសម្រួលពាណិជ្ជកម្មអាស៊ាន និងចំណាយចម្លងការពាណិជ្ជកម្មលើកទី២ Asean Seamless Trade Facilitation Indicator – Trade Transaction Cost ( ASTFI-TTC II ) ក្រោមក្របខណ្ឌកិច្ចសម្រួលពាណិជ្ជកម្ម
- សិក្ខាសាលា ស្ដីពី ប្រធានបទ "Unlocking the Lockdowns: Alignment of Domestic and Regional Policies Post-Covid-19"
- សិក្ខាសាលាស្ដីពី ការចរចាលើទំនិញវេទិយិត និងពាណិជ្ជកម្មសេវាកម្ម
- សិក្ខាសាលាកសាងសមត្ថភាព លើប្រធានបទ" Advanced Training for End Game Preparation and Negotiation"
- សិក្ខាសាលាកសាងសមត្ថភាព លើប្រធានបទ" Rules of Origin under Cambodia-China Free Trade Agreement"
- សិក្ខាសាលាលើកកម្ពស់ការយល់ដឹង និងការផ្លាស់ប្ដូរបច្ចេកទេស ស្ដីពីស្ថិតិទំនិញពាណិជ្ជកម្មអន្តរជាតិ
- សិក្ខាសាលាពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ លើសេចក្ដីព្រាងផែនការការងារអាស៊ាន ដើម្បីសម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀងអាស៊ាន ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- សិក្ខាសាលាកសាងសមត្ថភាពសម្រាប់កម្ពុជា ស្ដីពីការផ្ទេរបន្ទាត់ពន្ធគយក្រោម RCEP ពី AHTN2012 ទៅ AHTN2017
- សិក្ខាសាលា ស្ដីពីការអភិវឌ្ឍវិស័យវាយនភ័ណ្ឌ និងស្បែកជើងរៀបចំដោយអង្គការ UNIDO
- សិក្ខាសាលា ស្ដីពីកិច្ចសម្រួលពាណិជ្ជកម្មឆ្លងកាត់ព្រំដែនកម្ពុជា «Cross-Border Trade Facilitation in Cambodia»។

**គ. ការងារផ្ដល់សេវាសាធារណៈ**

- ក្នុងរយៈពេល១០ខែឆ្នាំ២០២១ ទំហំពាណិជ្ជកម្មកម្ពុជាសម្រេចបានទឹកប្រាក់ចំនួន **៣៧ ៣៤៦**លានដុល្លារអាម៉េរិក កើនឡើង **២៨%** ក្នុងនោះការនាំចេញសម្រេចបានទឹកប្រាក់ចំនួន **១៤ ២៨៦**លានដុល្លារអាម៉េរិក ថយចុះ **២%** និងការនាំចូលសម្រេចបានទឹកប្រាក់ចំនួន **២៣ ០៦០**លានដុល្លារអាម៉េរិក កើនឡើង **៥៨%** បើប្រៀបធៀបនឹងរយៈដូចគ្នាក្នុងឆ្នាំ២០២០
- បានផ្ដល់អាជ្ញាបណ្ណនាំចេញចំនួន ៥១ច្បាប់ គិតជាទឹកប្រាក់ចំនួនប្រមាណ **៦**លានដុល្លារអាម៉េរិក
- បានពន្យារអាជ្ញាបណ្ណនាំចេញចំនួន ២២ច្បាប់ និងផ្ដល់លិខិតជូនដំណឹងទំនិញឆ្លងកាត់ចំនួន **២៨**ច្បាប់
- បានផ្ដល់អាជ្ញាបណ្ណនាំចូលចំនួន ៩ច្បាប់ គិតជាទឹកប្រាក់ចំនួនប្រមាណ **១** លានដុល្លារអាម៉េរិក

- បានពន្យារអោជ្ញាបណ្ណនាំចូលចំនួន **៥ច្បាប់**
- បានផ្តល់លិខិតបញ្ជាក់ការនាំចេញ នាំចូល ត្បូងពេជ្រមិនទាន់កែច្នៃ និងសល់ពីការកែច្នៃ៖
  - នាំចូលចំនួន ១៥ច្បាប់ មានទឹកប្រាក់ ១៥លានដុល្លារអាមេរិក
  - នាំចេញចំនួន ២១ច្បាប់ មានទឹកប្រាក់ ៩លានដុល្លារអាមេរិក។
- បានចុះបញ្ជីសុំសិទ្ធិនាំចេញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ជូនរោងចក្រ និងក្រុមហ៊ុនសរុបចំនួន ១៩៣ រួមមាន៖
  - រោងចក្រកាត់ដេរសម្លៀកបំពាក់ ចំនួន ៤១ មានកម្មករ ១៥ ៧៣០នាក់
  - រោងចក្រកាត់ដេរស្បែកជើង ចំនួន ១១ មានកម្មករ ៦ ១៨៩នាក់
  - រោងចក្រផលិតកាបូប ចំនួន ១៥ មានកម្មករ ៣ ៧៨៤នាក់
  - រោងចក្រផ្សេងៗ ចំនួន ៤៧ មានកម្មករ ៥ ២០៥នាក់
  - ក្រុមហ៊ុនផ្សេងៗ ចំនួន ៧៩
- បានចុះបញ្ជីស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញតាមប្រព័ន្ធអេឡិចត្រូនិកថ្មីបានចំនួន **១៤៨**
- បានចុះបញ្ជីស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញតាមប្រព័ន្ធអេឡិចត្រូនិកសាឡើងវិញចំនួន **៥១៧**
- បានឆ្លើយបំភ្លឺចំពោះការស្នើសុំបញ្ជាក់ភាពត្រឹមត្រូវ នៃវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទៅកាន់គយនៃប្រទេសនាំចូលបានចំនួន **៤០ច្បាប់**។

### ស្ថិតិពាណិជ្ជកម្មកម្ពុជាជាមួយដៃគូសំខាន់ៗ រយៈពេល១០ខែដើម ឆ្នាំ២០២១ (ឯកតា៖ លានដុល្លារអាមេរិក)

| លរ. | ទិសដៅនាំចេញ | រយៈពេល១០ខែដើម ឆ្នាំ២០២០ | | | រយៈពេល១០ខែដើម ឆ្នាំ២០២១ | | | បម្រែបម្រួល (%) | | |
|---|---|---|---|---|---|---|---|---|---|---|
| | | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម |
| ១ | ពិភពលោក | ១៤ ៥៥០ | ១៤ ៦២៤ | ២៩ ១៧៤ | ១៤ ២៨៦ | ២៣ ០៦០ | ៣៧ ៣៤៦ | ▼ ២% | ▲ ៥៨% | ▲ ២៨% |
| ២ | អាមេរិក | ៤ ៣២៨ | ១៩៦ | ៤ ៥២៣ | ៦ ០៧៥ | ២៧៨ | ៦ ៣៥៣ | ▲ ៤០% | ▲ ៤២% | ▲ ៤០% |
| ៣ | ជប៉ុន | ៨៧៤ | ៥២៤ | ១ ៣៩៨ | ៩២០ | ៥២៩ | ១ ៤៤៩ | ▲ ៥% | ▲ ១% | ▲ ៤% |
| ៤ | ចិន | ៨២០ | ៥ ៦២៦ | ៦ ៤៤៦ | ១ ២២២ | ៧ ៧៦០ | ៨ ៩៨២ | ▲ ៤៩% | ▲ ៣៨% | ▲ ៣៩% |
| ៥ | ចក្រភពអង់គ្លេស | ៧០០ | ៤២ | ៧៤២ | ៥៩៩ | ៤៧ | ៦៤៥ | ▼ ១៥% | ▲ ១១% | ▼ ១៣% |
| ៦ | កាណាដា | ៦០៤ | ៤៨ | ៦៥២ | ៧៩០ | ៣២ | ៨២២ | ▲ ៣១% | ▼ ៣៣% | ▲ ២៦% |
| ៧ | កូរ៉េ | ១៥២ | ៤២៦ | ៥៧៨ | ១៥៧ | ៤៨១ | ៦៣៨ | ▲ ៣% | ▲ ១៣% | ▲ ១០% |
| ៨ | អូស្ត្រាលី | ១១៣ | ៦៣ | ១៧៦ | ១៥១ | ៨៩ | ២៣៩ | ▲ ៣៤% | ▲ ៤០% | ▲ ៣៦% |
| ៩ | ឥណ្ឌា | ៥២ | ១០៦ | ១៥៧ | ១០០ | ១៤៤ | ២៤៤ | ▲ ៩៣% | ▲ ៣៧% | ▲ ៥៥% |
| ១០ | នូវែលសេឡង់ | ១១ | ១២ | ២៣ | ១៣ | ១២ | ២៥ | ▲ ២០% | ▲ ១% | ▲ ១០% |
| ១១ | អាស៊ាន | ៣ ៤៩៦ | ៥ ៨០៨ | ៩ ៣០៤ | ៩៦០ | ១០ ៣៨៩ | ១១ ៣៤៩ | ▼ ៧៣% | ▲ ៧៩% | ▲ ២២% |
| | ថៃ | ៥៩១ | ២ ៣២០ | ២ ៩១១ | ២៨៩ | ២ ៧៤២ | ៣ ០៣១ | ▼ ៥១% | ▲ ១៨% | ▲ ៤% |
| | វៀតណាម | ២៨០ | ២ ១៣០ | ២ ៤១១ | ៤០៩ | ២ ៥៣០ | ២ ៩៣៩ | ▲ ៤៦% | ▲ ១៩% | ▲ ២២% |
| ១២ | សហភាពអឺរ៉ុប (EU) | ២ ៥៨៥ | ៥៦២ | ៣ ១៤៨ | ២ ៦១៩ | ៨៦៤ | ៣ ៤៨២ | ▲ ១% | ▲ ៥៤% | ▲ ១១% |
| ១៣ | សហភាពសេដ្ឋកិច្ចអឺរ៉ុបអាស៊ី- (EAEU) | ៤៣ | ១១ | ៥៤ | ៤៦ | ៣៩ | ៨៤ | ▲ ៦% | ▲ ២៤៦% | ▲ ៥៦% |
| ១៤ | ប្រទេសផ្សេងៗ | ៧៧២ | ១ ១៩៩ | ១ ៩៧១ | ៦៣៥ | ២ ៣៩៥ | ៣ ០៣១ | ▼ ១៨% | ▲ ១០០% | ▲ ៥៤% |

## ស្ថិតិនាំចេញមុខទំនិញសំខាន់ៗ (ឯកតា៖ លានដុល្លារអាម៉េរិក)

| លរ. | មុខទំនិញផ្សេងទៀត | រយៈពេល១០ខែដើម ឆ្នាំ២០២០ | រយៈពេល១០ខែដើម ឆ្នាំ២០២១ | បម្រែបម្រួល | |
|---|---|---|---|---|---|
| | | | | ទឹកប្រាក់ | (%) |
| ១ | សម្លៀកបំពាក់ | ៦ ០៩៩ | ៦ ៥៣៨ | ▲ ៤៣៩ | ▲ ៧% |
| ២ | ស្បែកជើង | ៩២២ | ១ ១១៤ | ▲ ១៩១ | ▲ ២១% |
| ៣ | សម្ភារៈធ្វើដំណើរ | ៧៧៥ | ១ ១៧៩ | ▲ ៤០៤ | ▲ ៥២% |
| ៤ | ម៉ាស៊ីនបរិធាន និងសម្ភារៈអគ្គិសនី | ៦០១ | ៨៥០ | ▲ ២៤៩ | ▲ ៤១% |
| ៥ | កង់ | ៤២៦ | ៥១៤ | ▲ ៨៧ | ▲ ២១% |
| ៦ | អង្ករ | ៣៦៥ | ៣២៦ | ▼ ៣៩ | ▼ ១១% |
| ៧ | គ្រឿងសង្ហារឹមនិងបរិធានបំភ្លឺ | ៥៥៥ | ៧៧៦ | ▲ ២២១ | ▲ ៤០% |
| ៨ | កៅស៊ូក្រែប | ១៩៥ | ៣២៩ | ▲ ១៣៤ | ▲ ៦៩% |
| ៩ | ស្ករអំពៅ | ៣២ | ៤២ | ▲ ១០ | ▲ ៣២% |
| ១០ | បន្លែនិងផ្លែឈើ | ១១០ | ១៦៧ | ▲ ៥៧ | ▲ ៥១% |
| ១១ | មុខទំនិញផ្សេងទៀត | ៤ ៤៧០ | ២ ៤៥៣ | ▼ ២ ០១៦ | ▼ ៤៥% |
| **សរុប៖** | | **១៤ ៥៥០** | **១៤ ២៨៦** | ▼ **២៦៤** | ▼ **២%** |

## ស្ថិតិនាំចូលមុខទំនិញសំខាន់ៗ (ឯកតា៖ លានដុល្លារអាម៉េរិក)

| លរ. | មុខទំនិញផ្សេងទៀត | រយៈពេល១០ខែដើម ឆ្នាំ២០២០ | រយៈពេល១០ខែដើម ឆ្នាំ២០២១ | បម្រែបម្រួល | |
|---|---|---|---|---|---|
| | | | | ទឹកប្រាក់ | (%) |
| ១ | វាយនភ័ណ្ឌ | ៣ ៥៣៣ | ៤ ៤១២ | ▲ ៨៨០ | ▲ ២៥% |
| ២ | សម្ភារៈសំណង់ | ៨០២ | ១ ០៦៣ | ▲ ២៦១ | ▲ ៣៣% |
| ៣ | ដែក | ៣២១ | ៣២៦ | ▲ ៤ | ▲ ១% |
| ៤ | ស៊ីម៉ង់ត៍ | ៥៩ | ៤០ | ▼ ១៩ | ▼ ៣៣% |
| ៥ | ទឹកបរិសុទ្ធ | ២៦០ | ២២៥ | ▼ ៣៥ | ▼ ១៣% |
| ៦ | ស្រាបៀរ និងស្រាចំរុះ | ១៤ | ៨ | ▼ ៦ | ▼ ៤២% |
| ៧ | រថយន្ត | ៩០១ | ៩៧៧ | ▲ ៧៦ | ▲ ៨% |
| ៨ | ផលិតផលឱសថ | ៣១៩ | ៦១៤ | ▲ ២៩៥ | ▲ ៩២% |
| ៩ | ជីកសិកម្ម និងថ្នាំ | ២៧៦ | ៣៩០ | ▲ ១១៤ | ▲ ៤១% |
| ១០ | គ្រឿងអេឡិចត្រូនិច និងសម្ភារៈអគ្គិសនី | ១ ៩០៧ | ២ ០១៤ | ▲ ១០៨ | ▲ ៦% |
| ១១ | មុខទំនិញផ្សេងទៀត | ៦ ២៣២ | ១២ ៩៩១ | ▲ ៦ ៧៥៩ | ▲ ១០៨% |
| **សរុប៖** | | **១៤ ៦២៤** | **២៣ ០៦០** | ▲ **៨ ៤៣៦** | ▲ **៥៨%** |







## ២.២. ការងារកម្មសិទ្ធិបញ្ញា

### ក. ការចុះបញ្ជីម៉ាក

- ចុះបញ្ជីម៉ាកក្នុងស្រុក និងក្រៅស្រុក រួមទាំងការចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិតាមប្រព័ន្ធម៉ាឌ្រីដ គិតត្រឹមថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ សរុបចំនួន **៨ ៤១២** ម៉ាក កើនឡើង **៥,១%** ធៀបនឹងឆ្នាំ២០២០
- ចុះបញ្ជីម៉ាកក្នុងស្រុក និងក្រៅស្រុក (តាមប្រព័ន្ធជាតិ) ចំនួនបាន **៦ ៦៣០** ម៉ាក កើនឡើង **១៧,៨%**
- ចុះបញ្ជីម៉ាកអន្តរជាតិតាមប្រព័ន្ធម៉ាឌ្រីដ (Madrid System) បានចំនួន **១ ៧៨២** ម៉ាក ថយចុះ **២៤,៧%**
- បានដោះស្រាយទាំងស្រុងនូវបញ្ហាកកស្ទះម៉ាកដែលបានដាក់ពាក្យស្នើសុំមុនឆ្នាំ២០២០
- សម្រុះសម្រួលការរំលោភបំពានម៉ាកចំនួន **៥**ករណី និងលុបចោលចំនួន **១១**ម៉ាក។

**ការចុះបញ្ជីម៉ាក និងសេវាពាក់ព័ន្ធ**

| សកម្មភាពការងារ | ឆ្នាំ២០២០ (១មករា - ៣១ធ្នូ) | ២០២១ (១មករា - ២៥វិច្ឆិកា) | កំណើន (%) |
|---|---|---|---|
| **១. ការងារចុះបញ្ជីម៉ាក** | | | |
| បានទទួលពាក្យស្នើសុំចុះបញ្ជីម៉ាក<br>- ក្នុងស្រុក<br>- ក្រៅស្រុក | **៦ ១១៦**<br>៣ ៥៨៨<br>២ ៥២៨ | **៥ ២៧៨**<br>៣ ០១៥<br>២ ២៦៤ | ▼ ១៣,៦ |
| បានចុះបញ្ជីម៉ាក (តាមប្រព័ន្ធជាតិ)<br>- ក្នុងស្រុក<br>- ក្រៅស្រុក | **៥ ៦២៨**<br>២ ៦៣៥<br>២ ៩៩៣ | **៦ ៦៣០**<br>៣ ២៦២<br>៣ ៣៦៨ | ▲ ១៧,៨ |
| **២. ការងារចុះបញ្ជីម៉ាកតាមប្រព័ន្ធអន្តរជាតិ (Madrid System)** | | | |
| ពាក្យស្នើសុំដែលបានដាក់នៅការិយាល័យដើមនៅកម្ពុជា (Office of Origin) ដើម្បីចុះបញ្ជីម៉ាកតាមប្រព័ន្ធអន្តរជាតិ | ៩ | ៤ | ▼ ៥៥,៥ |

| | | | |
|---|---|---|---|
| ការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកអន្តរជាតិ | ២ ៩៧៨ | ២ ៦១០ | ▼១២,៣ |
| ការចុះបញ្ជីម៉ាកតាមប្រព័ន្ធអន្តរជាតិ | **២ ៣៦៩** | **១ ៧៨២** | **▼២៤,៧** |
| **សរុបការចុះបញ្ជីម៉ាក** | **៧ ៩៩៧** | **៨ ៤១២** | **▲៥,១** |
| **៣. ការងារក្រោយចុះបញ្ជីម៉ាក** | | | |
| បានបញ្ជាក់ពីការប្រើប្រាស់ ឬមិនប្រើប្រាស់ម៉ាក | ៣ ៦៧៨ | ៣ ៣៣៩ | ▼ ៩,២ |
| បានចុះបញ្ជីម៉ាកសាជាថ្មី | ២ ៥៤៩ | ២ ១២៩ | ▼១៦,៤ |
| បានកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការនាំចូល | ១០៦ | ៧២ | ▼៣២ |
| បានកត់ត្រាកិច្ចសន្យាអាជ្ញាបណ្ណ ឬកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម | ១១១ | ៣៥ | ▼៦៨,៤ |
| បានផ្លាស់ប្តូរផ្សេងៗ | ១ ៥៩៦ | ២ ៣៥៦ | ▲៤៧,៦ |
| ការធ្វើទុតិយតាវិញ្ញាបនបត្រ | ៥៨៦ | ៦១៥ | ▲ ៤,៩ |
| បានផាកពិន័យចំពោះការស្នើសុំចុះបញ្ជីម៉ាកសាជាថ្មីយឺត | ២៦២ | ១៤៦ | ▼៤៤,២ |
| **៤. ការងារចុះបញ្ជីម៉ាកផ្សេងៗ** | | | |
| បានចុះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ | ០១ | ០១ | ០ |
| **៥. កិច្ចការវិវាទម៉ាក** | | | |
| ទទួលពាក្យស្នើសុំទប់ស្កាត់ការរំលោភបំពានម៉ាក | ២៨ ករណី | ១០ករណី | ▼៦៤,២ |
| ទទួលពាក្យស្នើសុំលុបម៉ាក | ៣១ ករណី | ៦៧ករណី | ▲១១៦,១ |
| លទ្ធផលសម្រុះសម្រួលការរំលោភបំពានម៉ាក | ២៣ ករណី | ៥ករណី | ▼៧៨,២ |
| លទ្ធផលលុបម៉ាក | ៣៧ ម៉ាក | ៨ករណី | ▼ ៧៨,៣ |

## ខ. ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

- បានចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ "ទឹកឃ្មុំព្រៃមណ្ឌលគិរី"
- បាន និងកំពុងរៀបចំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ "អំបិល និងផ្កាអំបិលកំពត"
- បាននិងកំពុងរៀបចំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ "បង្កងតាកែវ" និង "ទឹកត្រីកំពត-កែប" ក្រោមជំនួយបច្ចេកទេសរបស់អង្គការអន្តរជាតិ
- បានអនុវត្តគម្រោងកសាងកេរ្តិ៍ឈ្មោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម្រេចកំពត ស្ករត្នោតកំពង់ស្ពឺ ទឹកឃ្មុំព្រៃមណ្ឌលគិរី និងក្រូចថ្លុងកោះទ្រង់
- បានដាក់ពាក្យស្នើសុំកែតម្រូវសៀវភៅបន្ទុក "**ស្ករត្នោតកំពង់ស្ពឺ**" និងឯកសារពាក់ព័ន្ធនៅសហគមន៍អឺរ៉ុប
- បានរៀបចំកែសម្រួលសៀវភៅបន្ទុក**ម្រេចកំពត** ដោយបន្ថែមទំនិញសម្គាល់ភូមិសាស្ត្រ
- បាន និងកំពុងបណ្តុះបណ្តាលសមាគមម៉ាកសម្គាល់ភូមិសាស្ត្រម្រេចកំពត ពីវិធីសាស្ត្រទប់ស្កាត់ការរំលោភបំពាននៅទីផ្សារជាតិ និងអន្តរជាតិ។

## គ. ម៉ាកសមូហភាព

- បានចុះបញ្ជីម៉ាកសមូហភាព "អំបុកកំពង់ធំ" និងម៉ាកសមូហភាព "អង្ករព្រះវិហារ"
- បាននិងកំពុងរៀបចំចុះបញ្ជីម៉ាកសមូហភាពចំនួន៣ រួមមាន៖ "ចម្លាក់ប្រាក់ស្ពាន់ខេត្តកណ្តាល" "ក្រូចពោធិ៍សាត់" និង "នំបញ្ចុកសៀមរាប"
- បានអនុវត្តគម្រោងកសាងកេរ្តិ៍ឈ្មោះម៉ាកសមូហភាពគុយទាវភ្នំពេញ។

## ឃ. ការធ្វើទំនើបកម្មកិច្ចការចុះបញ្ជីម៉ាក

- រៀបចំប្រព័ន្ធស្វ័យប្រវត្តកម្មពេញលេញសម្រាប់កិច្ចការចុះបញ្ជីម៉ាក និងការបង់កម្រៃសេវាសាធារណៈ តាមប្រព័ន្ធអនឡាញ
- កំពុងរៀបចំប្រព័ន្ធជូនដំណឹងជាស្វ័យប្រវត្តិពីដំណើរការ និងស្ថានភាពនៃការចុះបញ្ជីម៉ាកទៅអ្នកដាក់ពាក្យស្នើសុំ និងភ្នាក់ងារស្របច្បាប់

- បានរៀបចំប្រព័ន្ធ Cloud សម្រាប់គ្រងគ្រងទិន្នន័យ និងឯកសារនៃការចុះបញ្ជីម៉ាក
- បានរៀបចំកែសម្រួល និងកែលំអហេដ្ឋារចនាសម្ព័ន្ធក្នុងកិច្ចការចុះបញ្ជីម៉ាក។

## ខ. ការងារកិច្ចសហប្រតិបត្តិការ និងការចូលជាសមាជិកសន្ធិសញ្ញាអន្តរជាតិ

- **ក្របខ័ណ្ឌអង្គការ** WIPO៖
  (១)បានចូលជាសមាជិកនៃគណៈកម្មការសម្របសម្រួល(COCO) កាលពីថ្ងៃទី៤ ខែតុលា ឆ្នាំ២០២១
  (២)បានតម្កល់លិខិតតូបករណ៍នៃការចូលជាភាគីនៃសន្ធិសញ្ញាទីក្រុងប៉ែនកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១
  (៣)បានរៀបចំផែនការរបស់ព្រះរាជាណាចក្រកម្ពុជា សម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេស
  (៤)បានចុះអនុស្សរណៈនៃការយោគយល់គ្នា រវាងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញានៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការអនុវត្តផែនការរបស់ព្រះរាជាណាចក្រកម្ពុជាសម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេស នាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១
  (៥)បានកំពុងរៀបចំធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងរដ្ឋបាលកម្មសិទ្ធិឧស្សាហកម្ម(IPAS) ជំនាន់ទី៤ ដើម្បីសម្រួលការងារចុះបញ្ជីម៉ាក និងផ្តល់សេវាជូនសាធារណជនឱ្យបានពេញលេញតាមប្រព័ន្ធអនឡាញ
  (៦)បានរៀបចំសំណើគម្រោងក្រោមជំនួយបច្ចេកទេសរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក
- **ក្របខ័ណ្ឌអាស៊ាន៖** កម្ពុជាបន្តជាអ្នកដឹកនាំការអនុវត្តគម្រោងចំនួន ២ រួមមាន៖
  ទី១.មជ្ឈមណ្ឌលបណ្តុះបណ្តាលកម្មសិទ្ធិបញ្ញា
  ទី២.មជ្ឈមណ្ឌលគាំទ្រ និងផ្តល់ព័ត៌មានកម្មសិទ្ធិបញ្ញា ព្រមទាំងចូលរួមអនុវត្តសកម្មភាពផ្សេងទៀតក្រោមផែនការសកម្មភាពកម្មសិទ្ធិបញ្ញាអាស៊ានឆ្នាំ ២០១៦-២០២៥ និងចូលរួមកិច្ចប្រជុំក្រុមការងារសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ានចំនួន ៣លើក
- បានរៀបចំផែនការសកម្មភាពរបស់គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ឆ្នាំ២០២១-២០២៣
- បានបញ្ចប់សេចក្តីព្រាងគោលនយោបាយជាតិកម្មសិទ្ធិបញ្ញា និងផែនការយុទ្ធសាស្រ្តកម្មសិទ្ធិបញ្ញាឆ្នាំ ២០២២-២០២៧
- បានចុះអនុស្សរណៈយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា រវាងក្រសួងពាណិជ្ជកម្ម និងសមាគមម៉ាកអន្តរជាតិ (INTA)
- កំពុងអនុវត្តគម្រោងក្រោមក្របខ័ណ្ឌ៖ អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ អង្គភាពកម្មសិទ្ធិបញ្ញាអឺរ៉ុប កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន អូស្រ្តាលី ណូវែលហ្សេឡង់និងគម្រោងក្រោមក្របខ័ណ្ឌអាស៊ាន ជាមួយចិន និងជាមួយអង្គភាពកម្មសិទ្ធិបញ្ញាផ្សេងទៀតទាក់ទងនឹងម៉ាក ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម ប្រកាសនីយបត្រតក្កកម្ម ការកសាង សមត្ថភាព ការពង្រឹងស្ថាប័ន ការកសាងច្បាប់ និងបទប្បញ្ញត្តិនានា ការអនុវត្តច្បាប់ និងសកម្មភាពផ្សេងទៀតទាក់ទងនឹងកម្មសិទ្ធិបញ្ញា។

## ច. ការលើកកម្ពស់ចំណេះដឹងសាធារណៈពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា

- រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងសមត្ថភាពមន្រ្តីត្រួតពិនិត្យម៉ាក និងមន្រ្តីពាក់ព័ន្ធរយៈពេល ៥ខែ ដែលមានអ្នកចូលរួមចំនួន ៤០នាក់
- រៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងដើម្បីពង្រឹងសមត្ថភាពមន្រ្តីកម្មសិទ្ធិបញ្ញារយៈពេល៣ខែ បានចំនួន ៤៥នាក់
- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងគុណភាពនៃការចុះបញ្ជីម៉ាក និងសិក្សាលទ្ធភាពក្នុងការឈានទៅរកស្តង់ដារ ISO
- បានចាត់បញ្ជូនមន្រ្តីចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សេងៗទាំងក្នុង និងក្រៅប្រទេសបានចំនួន ៥៦លើក សរុបស្មើនឹង ៣០៤នាក់

- បានសហការរៀបចំផ្សព្វផ្សាយកម្មសិទ្ធិបញ្ញាជាមួយដៃគូអភិវឌ្ឍន៍នានា
- បានកំពុងរៀបចំមជ្ឈមណ្ឌលផ្តល់ព័ត៌មានកម្មសិទ្ធិបញ្ញា
- បានរៀបចំខិត្តប័ណ្ណផ្សព្វផ្សាយ ស្តីពីការអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញានៅកម្ពុជា
- បានរៀបចំកម្មវិធីសិក្សានិងប្រព័ន្ធកម្មវិធីModel សម្រាប់ការបណ្តុះបណ្តាលកម្មសិទ្ធិបញ្ញាតាមប្រព័ន្ធអនឡាញ
- បានកំពុងកែសម្រួលគេហទំព័ររបស់កម្មសិទ្ធិបញ្ញា
- បានកំពុងរៀបចំកម្មវិធីសិក្សាកម្មសិទ្ធិបញ្ញាសម្រាប់សកលវិទ្យាល័យ
- កំពុងរៀបចំ IP Academy
- បានទទួលកម្មសិក្សាសិស្សមន្ត្រីជាន់ខ្ពស់ និងសិស្សមន្ត្រីក្រមការនៃសាលាភូមិន្ទរដ្ឋបាលចំនួន ៤នាក់
- បានកំពុងរៀបចំវីដេអូផ្សព្វផ្សាយ ពីកម្មសិទ្ធិបញ្ញា ដើម្បីលើកកម្ពស់ការយល់ដឹងដល់សាធារណជន
- បានបណ្តុះបណ្តាលជំនាញជាភ្នាក់ងារកម្មសិទ្ធិបញ្ញា និងជំនាញកម្មសិទ្ធិបញ្ញាដល់មន្ត្រីអនុវត្តច្បាប់ដើម្បីសម្រួលការផ្តល់ប្រឹក្សាយោបល់ និងលើកកម្ពស់ការយល់ដឹងទូលំទូលាយពីវិស័យកម្មសិទ្ធិបញ្ញា
- បានជំរុញសហគ្រាសធុនតូច និងមធ្យមឱ្យប្រើប្រាស់កម្មសិទ្ធិបញ្ញាជាទ្រព្យសកម្មនៃអាជីវកម្ម ដើម្បីកសាងកេរ្តិ៍ឈ្មោះម៉ាក បង្កើនការផ្តល់អាជ្ញាបណ្ណ និងសិទ្ធិប្រកបអាជីវកម្ម បង្កើតគំនិតច្នៃប្រឌិត ការផ្ទេរបច្ចេកវិទ្យា និងអភិវឌ្ឍផលិតផល រួមចំណែកបង្កើតឱកាសការងារ បង្កើនភាពប្រកួតប្រជែង និងជំរុញកំណើនសេដ្ឋកិច្ចជាតិ។

## ២.៣. ការចុះបញ្ជីពាណិជ្ជកម្ម

- ការស្នើចុះបញ្ជីពាណិជ្ជកម្ម (ថ្មី) ក្រុមហ៊ុន និងសហគ្រាសឯកបុគ្គល បានចំនួន **៧ ១២៧** កើនឡើង **0.៣%**
- ការស្នើសុំចុះបញ្ជីកែប្រែសម្រាប់ក្រុមហ៊ុន និងសហគ្រាសឯកបុគ្គលបានចំនួន **១១ ៥៨៣** ថយចុះ **៨,៤១%**
- លុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្មក្រុមហ៊ុននិងសហគ្រាសឯកបុគ្គលបានចំនួន**៥៨៥** កើនឡើង **៣៧,៣២%**

**តួលេខចុះបញ្ជីពាណិជ្ជកម្ម ១១ខែ (គិតត្រឹមថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២១)**

| ល.រ | ប្រភេទនៃការចុះបញ្ជីពាណិជ្ជកម្ម | ប្រៀបធៀប | | កំណើន (%) |
|---|---|---|---|---|
| | | ១១ខែឆ្នាំ២០២០ | ១១ខែឆ្នាំ២០២១ | |
| **ក. ករណីស្នើសុំចុះបញ្ជីពាណិជ្ជកម្ម (ថ្មី)** | | ៧ ១០៥ | ៧ ១២៧ | ▲ 0,៣0 |
| **ខ. ករណីស្នើសុំលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម** | | ៤២៦ | ៥៨៥ | ▲ ៣៧,៣២ |
| **គ. ករណីស្នើសុំចុះបញ្ជីកែប្រែ** | | | | |
| ១ | ការកែប្រែផ្លាស់ប្តូរភាគហ៊ុន | ២ ១៧៧ | ១ ៩៩0 | ▼ ៨,៥៨ |
| ២ | ការបង្កើតសាខាក្រុមហ៊ុនក្នុងស្រុក | ៦២៩ | ៤0៨ | ▼ ៣៥,១៣ |
| ៣ | ការកែប្រែផ្សេងៗ (អភិបាល នាមករណ៍...) | ៩ ៣៦0 | ៨ ៩៣៧ | ▼ ៤,៥១ |
| ៤ | ពិន័យការមិនបានបំពេញបែបបទក្នុងការផ្លាស់ប្តូរកែប្រែផ្សេងៗ | ៣៤៧ | ៧៤ | ▼ ៧៨,៦៧ |
| ៥ | ការកែប្រែសហគ្រាសឯកបុគ្គល | ១៣៤ | ១៧៤ | ▲ ២៩,៨៥ |
| **ឃ. ករណីតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ** | | | | |
| ១ | ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ | ២0 ១៤៨ | ២0 ៣0៧ | ▲ 0,៧៨ |
| ២ | ការពិន័យលើការមិនតម្កល់ប្រតិវេទន៍តាមកាលកំណត់ | ១ ៩0២ | ១ ១៣៥ | ▼ ៤0,៣២ |
| **ង. ករណីថតចម្លងឯកសារចុះបញ្ជីពាណិជ្ជកម្ម** | | 0 | 0 | 0 |
| **ច. ការប្តូរវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម** | | 0 | 0 | 0 |

| | | | | |
|---|---|---|---|---|
| ឆ. ករណីស្នើសុំបម្រុងទុកនាមករណ៍ | | | | |
| ១ | ការបម្រុងទុកនាមករណ៍ក្រុមហ៊ុនមូលធន | ៦ ៦១៧ | ៦ ៤៩៦ | ▼ ១,៨២ |
| ២ | ពន្យារការបម្រុងទុកនាមករណ៍ក្រុមហ៊ុនមូលធន | ១៦៩ | ៤៦៣ | ▲ ១៧៣,៩ |
| ៣ | ការបម្រុងទុកនាមករណ៍សហគ្រាសឯកបុគ្គល | ១ ៩៧១ | ៣ ០១៧ | ▲ ៥៣,០៦ |
| ៤ | ពន្យារការបម្រុងទុកនាមករណ៍សហគ្រាសឯកបុគ្គល | ១៥ | ៥៨ | ▲ ២៨៦,៦ |
| ជ. ការពិន័យលើការក្លែងបន្លំឯកសារតម្រូវការចុះបញ្ជី | | ០ | ០ | ០ |
| ឈ. ការងារពិគ្រោះយោបល់ផ្សេងៗ | | ០ | ០ | ០ |

<u>**សកម្មភាពផ្សេងៗ៖**</u>

- បានធ្វើការតភ្ជាប់ប្រព័ន្ធចុះបញ្ជីជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងទេសចរណ៍ និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ តាមរយៈថ្នាលបច្ចេកវិទ្យា(CAMDX)
- បានបញ្ចប់ការងារដំឡើងមជ្ឈមណ្ឌលទិន្នន័យ (DATA CENTER) របស់ក្រសួងពាណិជ្ជកម្ម
- បានបញ្ចប់សេចក្តីព្រាងវិសោធនកម្មច្បាប់ ស្តីពីច្បាប់សហគ្រាសពាណិជ្ជកម្ម និងច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម សម្រាប់ដាក់ក្នុងរបៀបវារៈនៃកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅក្នុងខែធ្នូ ឆ្នាំ២០២១
- បានចូលរួមរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិតជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានចេញប្រកាសលេខ០១៦៩ ព.ណ ចបព.ប្រក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ ស្តីពីការដាក់ពាក្យសម្គាល់ទ្រង់ទ្រាយក្រុមហ៊ុន
- បានចេញសេចក្តីជូនដំណឹងស្តីពីការស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណពាណិជ្ជកម្មតាប្រព័ន្ធអេឡិចត្រូនិក
- បានបំពេញសកម្មភាពក្នុងក្រុមការងារបច្ចេកទេសអន្តរក្រសួង ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលនៅក្រោមគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលក្នុងនោះក្រសួងពាណិជ្ជកម្ម មានភារកិច្ចត្រូវធ្វើក្នុងរយៈពេលខ្លី ដើម្បីឆ្លើយតបទៅនឹងរបាយការណ៍ការត្រួតពិនិត្យរបស់ក្រុមការងារត្រួតពិនិត្យរួមគ្នានៃប្រទេសអាស៊ីប៉ាស៊ីហ្វិក អំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ (ICRG's Asia/Pacific Joint Group) ដោយបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីកាតព្វកិច្ចរបស់វិស័យឯកជន និងមន្ត្រីជំនាញនៃក្រសួងពាណិជ្ជកម្មក្នុងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ក្រោមកិច្ចសម្របសម្រួលបកស្រាយពីអ្នកជំនាញ នៃក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌។

## ២.៤. តំណាងពាណិជ្ជកម្មប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស

- បានផ្សព្វផ្សាយពីវិធានដើមកំណើតទំនិញការប្រើប្រាស់ប្រព័ន្ធចុះបញ្ជីអ្នកនាំចេញ(Registered Exporter System-REX)និងណែនាំពីបែបបទស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញគ្រប់ទម្រង់ តាមប្រព័ន្ធស្វ័យប្រវត្តកម្ម និងផ្សព្វផ្សាយអំពីលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងការនាំចេញទំនិញ
- បានចុះត្រួតពិនិត្យ និងវាយតម្លៃអនុលោមភាព និងធ្វើការអង្កេតលើដើមកំណើតទំនិញ ដើម្បីទទួលបានភាពអនុគ្រោះពាណិជ្ជកម្មនិងណែនាំអំពីនីតិវិធី និងឯកសារពាក់ព័ន្ធក្នុងការស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម
- បានសហការនិងចូលរួមជាមួយតំណាងការិយាល័យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងការិយាល័យតំណាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ចុះធ្វើអធិការកិច្ចរោងចក្រ ត្រួតពិនិត្យការនាំចូលវត្ថុធាតុដើម និងពិនិត្យទំនិញមុនធ្វើការនាំចេញ
- បានសហការជាមួយនឹងរោងចក្រ ដើម្បីផ្តល់ឯកសារសេក្តីកម្មនៅពេលដែលមានការស្នើសុំផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃវិធានដើមទំនិញពីប្រទេសនាំចូល

- បានចូលរួមសហការ ជាមួយការិយាល័យតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ពាក់ព័ន្ធនឹងវិវាទកម្មករនិងម្ចាស់រោងចក្រ
- បានចូលរួមកិច្ចប្រជុំប្រចាំខែ ដែលរៀបចំដោយការិយាល័យតំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ពាក់ព័ន្ធនឹងដំណើរការនៃរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ច្បាប់ នីតិវិធី បែបបទ និងបញ្ហាផ្សេងៗទៀត
- បានចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ និងឯកសារឧបសម្ព័ន្ធជូនដល់អ្នកនាំចេញ តាមការស្នើសុំ។

## ៣. ការងារពាណិជ្ជកម្មក្នុងប្រទេស [2]

### ៣.១. ការកសាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា

#### ក. ការកសាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត

- ច្បាប់ស្តីពី ការប្រកួតប្រជែង៖ ត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខាប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០២១/០១៣ កាលពីថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១
- សេចក្តីព្រាងច្បាប់ ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម៖ បានបញ្ចប់សេចក្តីព្រាងទាំងស្រុង និងត្រៀមបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីជាថ្មី ដើម្បីបន្តនីតិវិធី
- សេចក្តីព្រាងច្បាប់ភ្នាក់ងារពាណិជ្ជកម្ម៖ បានទទួលសេចក្តីព្រាងជាភាសាបរទេសពីជំនាញការអន្តរជាតិក្រោមជំនួយបច្ចេកទេស ពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងកំពុងបន្តនីតិវិធីពិនិត្យផ្ទៃក្នុង
- បានបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពី ការសម្ងាត់ពាណិជ្ជកម្ម និងព័ត៌មានមិនបង្ហាញ
- បានផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ពាណិជ្ជកម្មដល់ពាណិជ្ជករចំនួន ១០លើក
- បានរៀបចំសេចក្តីសម្រេចលេខ១២២ ព.ណ.នច.ប្រក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ ស្តីពី ការបង្កើតក្រុមការងារអន្តរក្រសួងរៀបចំសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិនានា ស្តីពីវិធានដើមកំណើតទំនិញ
- បាននឹងកំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីវិធានដើមកំណើតទំនិញដែលមាន ៩ជំពូក និង៣៦មាត្រា ដោយបានប្រជុំជាមួយក្រុមការងារអន្តរក្រសួង ជាមួយជំនាញការ UNCTAD និង WTO សរុបចំនួន១៩លើក
- បានរៀបចំអនុក្រឹត្យ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា
- ផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម ដើម្បីបញ្ចូលជំពូកកម្មសិទ្ធិបញ្ញាពាក់ព័ន្ធនឹងកិច្ចសន្យាអាជ្ញាបណ្ណ កិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម និងកិច្ចសន្យាប្រគល់សិទ្ធិផ្តាច់មុខលើម៉ាក
- បានបញ្ចប់សេចក្តីព្រាងអនុក្រឹត្យ ស្តីពីនីតិវិធីរដ្ឋបាលនៃការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា
- រៀបចំប្រកាសស្តីពីនីតិវិធីសម្រាប់ការបញ្ជាក់ និងការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក
- បានកសាង និងចូលរួមប្រជុំពិភាក្សាបន្ត លើសេចក្តីព្រាងច្បាប់ចំនួន ២ គឺច្បាប់ស្តីពីការប្រកួតប្រជែង និងច្បាប់ស្តីពី សុវត្ថិភាពម្ហូបអាហារ អនុក្រឹត្យចំនួន៥ សេចក្តីសម្រេចចំនួន១ ប្រកាសអន្តរក្រសួងចំនួន២ប្រកាសចំនួន១១ និងគោលការណ៍ណែនាំចំនួន១ ដែលក្នុងនោះមានសេចក្តីព្រាងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តមួយចំនួនត្រូវបានឡាយព្រះហស្តលេខា និងចុះហត្ថលេខាដាក់ឱ្យប្រើប្រាស់ សេចក្តីព្រាងមួយចំនួនកំពុងស្ថិតក្នុងកិច្ចពិភាក្សានិងផ្តល់យោបល់នៅទីស្តីការគណៈរដ្ឋមន្ត្រី និងសេចក្តីព្រាងមួយចំនួនទៀតកំពុងស្ថិតក្នុងការពិនិត្យនិងកែសម្រួលរបស់ក្រុមការងារនៃអគ្គនាយកដ្ឋានក.ប.ប.។

#### ខ. ការងារតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា

បានទទួលការតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានាចំនួន **៨ ២៤៧**លិខិត និងប្រមូលកម្រៃសេវាសាធារណៈបានចំនួន **៤១០ ៨២៨ ០០០**រៀល។ តាមរយៈយន្តការប្រតិបត្តិការដែលមានកិច្ចធានា (ការ

[2] ប្រភព៖ អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស

ទទួលបានកម្ចី/ហិរញ្ញប្បទានតាមរយៈការប្រើប្រាស់ចលនវត្ថុជាទ្រព្យធានា) ឥណទាន សរុបប្រមាណជាង **៥២,៥** លានដុល្លារអាម៉េរិក ត្រូវបានផ្តល់ជូនអតិថិជនដោយគ្រឹះស្ថានធនាគារមីក្រូហិរញ្ញវត្ថុ និងប្រភពនានា ដើម្បីទ្រទ្រង់ និងពង្រីកសកម្មភាពអាជីវកម្ម

## ៣.២. ការអភិវឌ្ឍវិស័យឯកជន

### ក. ការងារឃ្លាំមើល និងតាមដានសកម្មភាពពាណិជ្ជកម្ម

- បានចេញសេចក្តីជូនដំណឹង ស្តីពីថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ៍ចំនួន ២២លើក
- បានតាមដាន និងបូកសរុបរបាយការណ៍ នៃការអនុវត្តចេញលិខិតអនុញ្ញាតធ្វើអាជីវកម្ម ពាណិជ្ជកម្ម និងសេវាកម្ម ការបិទស្លាកថ្លៃលើមុខទំនិញ និងសេវាគ្រប់ប្រភេទ និងលិខិតអនុញ្ញាតធ្វើអាជីវកម្មត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ របស់មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត និងច្រកចេញ-ចូលតែមួយ
- បានរៀបចំរបាយការណ៍ ស្តីពីថ្លៃទំនិញចាំបាច់ប្រចាំជីវភាពចំនួន ១១៩មុខ និងការស្តុកស្រូវ-អង្ករ តាមបណ្តាខេត្ត ថ្លៃប្រេងឥន្ធនៈនិងសន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារនៅរាជធានីភ្នំពេញ
- បានរៀបចំរបាយការណ៍វឌ្ឍនភាព ស្តីពីបញ្ហាទំនិញកសិផលដែលកកស្ទះ និងស្ថានភាពទំនិញចេញចូលក្នុងកំឡុងពេលបិទព្រំដែនកម្ពុជា-ថៃ និងកម្ពុជា-វៀតណាម ៤ដងក្នុងមួយខែ
- បានរៀបចំរបាយការណ៍ស្តុកផលិតផលក្នុងស្រុកចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃ ២៩មុខ។

### ខ. ការងារអភិវឌ្ឍន៍ស្ថាប័នពាណិជ្ជកម្ម

- បានរៀបចំសេចក្តីព្រាងប្រកាស ស្តីពីការបង្កើតក្រុមការងាររៀបចំការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាភិបាល នៃសមាគមលើកកម្ពស់ម្រេចកំពត(ស.ល.ម.ក)
- បានរៀបចំសេចក្តីព្រាងណែនាំ ស្តីពីការរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល និងប្រធានគណៈកម្មាធិការប្រតិបត្តិ សេចក្តីព្រាងលក្ខន្តិកៈសមាគម រួមទាំងបញ្ជីឈ្មោះអ្នកចូលរួមបោះឆ្នោត ប្រវត្តិរូបរបស់បេក្ខជន ប័ណ្ណបោះឆ្នោត ពាក្យសុំចុះឈ្មោះបេក្ខជនឈរឈ្មោះក្រុមប្រឹក្សាភិបាល និងប្រធាន គណៈកម្មាធិការប្រតិបត្តិរបស់សមាគមលើកកម្ពស់ម្រេចកំពត
- បានចុះសម្របសម្រួលរៀបចំបោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានសមាគមអាជីវកម្មស្វាយត្រពាំងក្រញូង ខេត្តតាកែវ
- បានរៀបចំប្រកាសទទួលស្គាល់ សមាសភាពសមាជិកទីប្រឹក្សាសភាពាណិជ្ជកម្មខេត្តតាកែវ និងសភាពាណិជ្ជកម្មមណ្ឌល ខេត្តកំពង់ចាម-មណ្ឌលគិរី
- បានចូលរួមក្នុងកិច្ចប្រជុំ និងរៀបចំកំណត់ហេតុ ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាលបង្គ្រប់ចំនួន ៧រូប អនុប្រធានទី២ និងការបញ្ឈប់សមាជិកក្រុមប្រឹក្សាភិបាលរបស់សហព័ន្ធចម្លាក់ប្រាក់-ស្ពាន់កម្ពុជា អាណត្តិទី១
- បានរៀបចំកិច្ចប្រជុំជាមួយសភាពាណិជ្ជកម្មកម្ពុជា ស្តីពីការបើកការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជាប្រចាំប្រទេសជប៉ុន និងកិច្ចប្រជុំស្តីពីការបង្កើតយន្តការភាពជាដៃគូរវាងរដ្ឋបាលរាជធានី-ខេត្ត និងសភាពាណិជ្ជកម្មមណ្ឌលរាជធានី-ខេត្ត និងការរៀបចំបោះឆ្នោតជ្រើសរើសប្រធានសភាពាណិជ្ជកម្មខេត្តបន្ទាយមានជ័យ
- បានរៀបចំកិច្ចប្រជុំទ្វេភាគីជាមួយលោក Hiroyuki តំណាងភាគីជប៉ុនតាមរយៈប្រព័ន្ធវីដេអូ (Zoom Meeting) ដើម្បីសិក្សាពីនីតិវិធីនៃការរៀបចំការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជានៅតំបន់សេនដៃ ទីក្រុងតូក្យូ ប្រទេសជប៉ុន និងបានរៀបចំលិខិតគោរពជូន**សម្តេចតេជោនាយករដ្ឋមន្ត្រី** ដើម្បីស្នើសុំពិនិត្យ និងចុះហត្ថលេខា លើសេចក្តីសម្រេចស្តីពីការបង្កើតការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជា

នៅតំបន់សេនដៃ ទីក្រុងតូក្យូ ប្រទេសជប៉ុននេះ
- បានទំនាក់ទំនងទៅកាន់មន្ទីរពាណិជ្ជកម្មខេត្តចំនួន ៧រួមមាន៖ ខេត្តព្រះវិហារ ឧត្តរមានជ័យ រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង កែប និងខេត្តកំពង់ឆ្នាំង ដើម្បីសិក្សា និងផ្តល់ព័ត៌មានបឋមលើលទ្ធភាពនៃបង្កើតសភាពាណិជ្ជកម្មថ្មី ប្រចាំខេត្ត
- បានរៀបចំរបាយការណ៍តម្លៃលក់ត្រីប្រចាំថ្ងៃ នៅលើទីផ្សារទូទាំង២៥ រាជធានី-ខេត្ត
- បានរៀបចំរបាយការណ៍ ស្តីពីស្ថានភាពនៃការនាំចេញកសិផលស្រូវទៅកាន់ប្រទេសវៀតណាមតាមច្រកព្រំដែនអន្តរជាតិបន្ទាយចក្រីខេត្តព្រៃវែង។

## គ. ការងារអភិវឌ្ឍន៍ផលិតផល

- បានរៀបចំប្រកាសស្តីពីការបង្កើតក្រុមការងារបច្ចេកទេសសិក្សាលើការអភិវឌ្ឍខ្សែច្រវាក់តម្លៃកសិ-ពាណិជ្ជកម្មរវាងក្រសួងពាណិជ្ជកម្ម និងក្រុមហ៊ុនយ៉ាម៉ាតុហ្គ្រីន
- បានរៀបចំរបាយការណ៍សន្ទស្សន៍ថ្លៃទំនិញចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃក្នុងទីផ្សារភ្នំពេញ និងខេត្តកណ្តាល (២០ មុខ និង៤០មុខ)
- បានរៀបចំរបាយការណ៍ស្តីពីតម្លៃ ផលិតផលសាច់ជ្រូក និងត្រីនៅតាមផ្សារធំៗទាំង៥ នៅរាជធានីភ្នំពេញ និងទិន្នន័យនាំចេញ-នាំចូលផលិតផលសាច់ជ្រូក និងត្រីនៅឆ្នាំ២០១៩ និងឆ្នាំ២០២០
- រៀបចំរបាយការណ៍កិច្ចប្រជុំក្រុមការងារបច្ចេកទេសសិក្សាថ្លៃដើម និងជំរុញការធ្វើពាណិជ្ជកម្ម "ស្វាយ"
- បានរៀបចំតារាងទិន្នន័យផលិតផលសក្តានុពលតាមខេត្តនីមួយៗ និងសម្រង់សំណួរសម្រាប់វគ្គបណ្តុះបណ្តាល ស្តីពីការអភិវឌ្ឍខ្សែច្រវាក់តម្លៃដល់ភាគីពាក់ព័ន្ធ
- បានរៀបចំរបាយការណ៍ ស្តីពីការសិក្សាស្រាវជ្រាវ និងចងក្រងនូវថ្លៃដើម បញ្ហាប្រឈម នៃផលិតផលសក្តានុពលមៀនប៉ៃលិន និងស្វាយកែវរមៀត
- រៀបចំជារបាយការណ៍ ស្តីពីបច្ចុប្បន្នភាពទិន្នន័យផលិតផលសក្តានុពលក្នុងយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជាDTIS (លើផលិតផលស្រូវ និងដំឡូងមី) និងសិក្សាពីផលិតផលសក្តានុពលមាននៅតាមបណ្តាខេត្តគោលដៅរួមមាន៖ ខេត្តកំពត(ម្រេច ស្រូវ អំបិល ចេកអំបូងលឿង ស្វាយ ធុរេន ទឹកត្រីកំពត) ខេត្តព្រៃវែង(ហូល ផាមួង ក្រមា ផ្កៅ រំពាក់ ពោតក្រហម សណ្តែកបាយ ល្ង អំពៅ សិប្បកម្មកែច្នៃជ័រប្រើប្រាស់), ខេត្តសៀមរាប(ប្រហុក ក្រពើ ត្រសក់ផ្អែម រំពាក់ ផ្កៅ កំប្លោក សណ្តែកបាយ) ខេត្តស្ទឹងត្រែង(ទឹកឃ្មុំ ចេកអំបូងលឿង ស្វាយចន្ទី កៅស៊ូ ស្វាយ) ខេត្តកំពង់ធំ(ស្វាយចន្ទី អំបុកសាន់គរ កៅស៊ូ), ខេត្តតាកែវ(ពងទាកូនស្រែននោង ត្បូងថ្ម សូត្រធៅ និងផលិតផលសម្រេចពីសូត្រ) ខេត្តរតនគិរី(ប៉័រ ក្រូចវល្លិ៍ កៅស៊ូ ស្វាយចន្ទី ប្រេងដូង សណ្តែកសៀង) ខេត្តប៉ៃលិន(មៀនប៉ៃលិន ពោតក្រហម ធុរេន ស្វាយចន្ទី) និងខេត្តមណ្ឌលគិរី(កាការ៉ាវ ប៉័រ ទឹកឃ្មុំ កាហ្វេ និងក្រូចវល្លិ៍)
- បានរៀបចំជារបាយការណ៍ ស្តីពីបច្ចុប្បន្នភាពទិន្នន័យសូត្ររបស់ ខេត្តតាកែវ កំពង់ចាម បាត់ដំបង បន្ទាយមានជ័យ កោះដាច់ កោះឧកញ៉ាតី និងខេត្តសៀមរាប(Golden Silk Pheach)។

## ៣.៣. ការងារផែនការ ស្ថិតិ និងផ្សព្វផ្សាយព័ត៌មានពាណិជ្ជកម្ម

- បានរៀបចំកិច្ចការគ្រប់គ្រងឯកសារ និងសកម្មភាពការងារតាមប្រព័ន្ធអេឡិចត្រូនិក (Confluence and Jira Work Management)
- បានប្រមូល ចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ចាំបាច់ប្រចាំជីវភាព នៅលើទីផ្សាររាជធានី-ខេត្ត ការចេញ លិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម និងត្បូងថ្មមានតម្លៃ, ថ្លៃលក់ដុំទំនិញកសិផល

សំខាន់ៗ ការចុះបញ្ជីពាណិជ្ជសញ្ញា ព្រមទាំងស្ថិតិ និងព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មដទៃទៀត

- បានចងក្រងឯកសារចូលសំខាន់ៗរបស់ក្រសួង សម្រាប់បញ្ចូលក្នុង៖ របាយការណ៍ពាក់កណ្តាលអាណត្តិនៃការអនុវត្ត "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ឆ្នាំ២០១៩-២០២៣" វឌ្ឍនភាពនៃការអនុវត្ត "គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា(គ.អ.ច.ក.)២០១៦-២០៣០" តារាងម៉ាទ្រីសនៃផែនការសកម្មភាព ២០២២-២០២៤ នៃ "គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០" "កម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ឆ្នាំ២០២២-២០២៤" និង "របាយការណ៍ វឌ្ឍនភាពប្រចាំឆ្នាំរបស់ក្រសួងពាណិជ្ជកម្មនៃការអនុវត្តតាមផែនការយុទ្ធសាស្ត្រគោលដៅ និងកម្មវិធីពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល"
- បានសិក្សាស្រាវជ្រាវឯកសារយុទ្ធសាស្ត្រ គោលនយោបាយ ផែនការ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម ដើម្បីជាមូលដ្ឋានបន្ថែមក្នុងការចងក្រង "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ពាណិជ្ជកម្ម"
- បានរៀបចំ និងបញ្ចូលស្ថិតិពាណិជ្ជកម្មទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យស្ថិតិនាំចេញ នាំចូល ដើម្បីជាមូលដ្ឋានក្នុងការវិភាគ ផ្សព្វផ្សាយ និងផ្តល់ស្ថិតិ និងព័ត៌មានពាណិជ្ជកម្មជូនថ្នាក់ដឹកនាំ អង្គភាព ស្ថាប័ន និងអ្នកពាក់ព័ន្ធដើម្បីប្រើប្រាស់តាមការចាំបាច់
- បានប្រមូលព័ត៌មាន និងតួលេខពីអង្គភាពពាក់ព័ន្ធ ដើម្បីរៀបចំចងក្រងស្ថិតិ និងព័ត៌មានពាណិជ្ជកម្មសំខាន់ៗ សម្រាប់បោះពុម្ពចុះផ្សាយក្នុងសៀវភៅព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្មចំនួន ២លេខក្នុងមួយខែ
- បានអភិវឌ្ឍគេហទំព័រថ្មីរបស់ក្រសួងពាណិជ្ជកម្ម www.moc.gov.kh ៖ បញ្ចូលស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម បង្កើតប្រព័ន្ធថ្លៃទំនិញប្រចាំថ្ងៃ រចនាទំព័រចូលរបស់គេហទំព័រ និងបង្កើត API សម្រាប់បញ្ចូល និងទាញទិន្នន័យសម្រាប់គ្រប់គ្រង និងប្រើប្រាស់
- បានធ្វើបច្ចុប្បន្នភាពម៉ាស៊ីនមេ Servers នៅក្នុងមជ្ឈមណ្ឌលព័ត៌មានរបស់ក្រសួងតាមរយៈ Upgrade Hard Disk និងRAM និងកែលម្អម៉ាស៊ីនមេចាស់ៗយកមកប្រើប្រាស់ទៅតាមតម្រូវការជាក់ស្តែង
- បានដំឡើង Mail Server និងបង្កើតគណនី Mail និងពិនិត្យមើលជាប្រចាំនូវរាល់ការផ្ញើ Mail និងSpam
- បានប្រើប្រាស់ Firewall របស់មជ្ឈមណ្ឌលទិន្នន័យថ្មីជំនួសឱ្យ Firewall ចាស់ដែលត្រូវចំណាយខ្ពស់ក្នុងការបន្តសុពលភាពអាជ្ញាប័ណ្ណក្នុងមួយឆ្នាំៗ
- បានចរចាបង្កើនល្បឿនអ៊ីនធឺណិត(Upgrade Internet Speed)ពី50Mbps ទៅ100Mbps របស់ក្រុមហ៊ុន EZECOM ដោយមិនចំណាយកម្រៃបន្ថែម
- បានចូលរួមសម្របសម្រួលក្នុងកិច្ចប្រជុំវេទិកាសេដ្ឋកិច្ច និងធុរកិច្ចអាស៊ី-អឺរ៉ុបលើកទី១ ដោយបានបម្រុងទុកល្បឿនអ៊ីនធឺណិតពី500 ទៅ 600Mbps និងតាមដានដំណើរការឧបករណ៍ព័ត៌មានវិទ្យា និងឧបករណ៍ពាក់ព័ន្ធដទៃទៀត ដើម្បីធានាឱ្យកិច្ចប្រជុំប្រព្រឹត្តទៅដោយរលូន និងជោគជ័យគួរជាទីមោទនៈ
- បានតាមដាន ត្រួតពិនិត្យ ថែទាំ និងសម្របសម្រួលលើការដំឡើង និងជួសជុលឧបករណ៍ព័ត៌មានវិទ្យា និងឧបករណ៍ពាក់ព័ន្ធ ដើម្បីឱ្យការប្រើប្រាស់ មានដំណើរការល្អជាប្រចាំ។

### ៣.៤. ការអនុវត្តគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច(AIMS)

- បានកៀរគរកសិករខ្នាតតូច ដើម្បីរៀបចំចងក្រងជាចង្កោមក្រុមផលិតចំនួន ៧៦៣ចង្កោម និងក្រុមកសិករផលិតបានចំនួន ១ ៩០៣ក្រុម ដែលមានកសិករជាសមាជិកសរុបចំនួន ៧៧ ០៤២គ្រួសារ ស្មើនឹង១០២,៧២% លើផែនការគម្រោងសរុបចំនួន ៧៥ ០០០គ្រួសារ ក្នុងនោះកសិករមានជីវភាពក្នុងកម្រិតក្រ១ ចំនួន ៣ ៦៣០គ្រួសារ ក្រ២ ចំនួន ៨ ៩៦២គ្រួសារ ជិតក្រមានចំនួន ៥៩ ៨៥៦គ្រួសារ

និងលើមធ្យមមានចំនួន ៤ ៥៩៤គ្រួសារ។ ផលិតផលកសិពាណិជ្ជកម្ម ដែលត្រូវបានជ្រើសរើស និង កំណត់ជាអាទិភាពសម្រាប់ការគាំទ្រ និងអន្តរាគមន៍ពីគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច (AIMS) មានចំនួន ៥ប្រភេទ គឺបន្លែ មាន់ស្រែ ស្រូវ ដំឡូងមី និងសូត្រធៅ

- បានសម្របសម្រួលឱ្យមានការប្រជុំក្រុម វេទិកា កម្មវិធីទស្សនៈកិច្ច និងវគ្គបណ្តុះបណ្តាលជាច្រើន ជាអាទិ៍ បានរៀបចំការប្រជុំក្រុមចំនួន ២ ៨៤៣កិច្ចប្រជុំ វេទិកាពហុភាគីអ្នកពាក់ព័ន្ធចំនួន ១ ៤៧០វេទិកា និងវគ្គ បណ្តុះបណ្តាលអាជីវកម្មចំនួនប្រមាណ ១ ៦៨០វគ្គ ដែលមួយវគ្គមានយ៉ាងតិច៣មេរៀនធំៗ
- បានរៀបចំសម្របសម្រួលឱ្យមានការចាប់ដៃគូរវាងក្រុមកសិករផលិត និងកសិ-ពាណិជ្ជករ(ឈ្មួញ) តាម រយៈការចុះកិច្ចសន្យាទិញ-លក់បានចំនួន ១ ៥៥៣កិច្ចសន្យា ក្នុងនោះបន្លែមានចំនួន ៣៦២កិច្ចសន្យា មាន់ស្រែ៦២៤ ដំឡូងមី១៧៦ និងស្រូវ ៣៩១កិច្ចសន្យា ដែលមានបរិមាណសរុបចំនួន ៣២៥ ២៣៣តោន
- បានសម្របសម្រួលផ្សាភ្ជាប់អាជីវកម្មរវាងផ្សារអាហារសុវត្ថិភាពរបស់ក្រុមហ៊ុនខេ.ស៊ី.ស៊ី.វី ផ្លេនថេសិន (KCCV) ក្រុមហ៊ុនម៉ាក្រូ (ខេមបូឌា) ឯ.ក(ផ្សារម៉ាក្រូ) ក្រុមហ៊ុន Yamato Green Co.,LtD. LyLy, Agrion, CJ Agro Business, Mala, REMIC, NAV, KOC, Lala Garden, ASPIRE, Samaritan Purse, Home Food។ល។
- បានគាំទ្រខ្សែច្រវាក់តម្លៃលើផ្នែកផលិតកម្ម ដោយប្រើប្រាស់មូលនិធិអភិវឌ្ឍន៍តាមវិស័យ (SDF) ឆ្នាំ ២០២១ ដើម្បីបង្កើនផលិតភាពតាមរយៈការផ្តល់ក្រុមផលិតឱ្យទទួលបាននូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែល មាន៦ប្រភេទ ជាអាទិ៍ អណ្តូងស្រោចស្រពបំពាក់ប្រព័ន្ធពន្លឺព្រះអាទិត្យចំនួន ៥៦អណ្តូង សត្តឃាតដ្ឋាន ចំនួន ១៥កន្លែង កន្លែងប្រមូលផ្តុំបន្លែចំនួន ២៧កន្លែង, ប្រមូលផ្តុំមាន់ស្រែចំនួន ៣២កន្លែង កន្លែងលាង សម្អាត និងវេចខ្ចប់បន្លែចំនួន ១៦កន្លែង និងកន្លែងប្រមូលផ្តុំពហុផលិតផលចំនួន ៤កន្លែង
- បានអនុម័តសំណើមូលនិធិនវានុវត្តន៍ VCIF សម្រាប់ឆ្នាំ២០២១ ជូនកសិករ ក្នុងខេត្តទាំង១៨ ក្រោម គម្រោងលើពីរផលិតផលសំខាន់ៗគឺការវិនិយោគលើផលិតផលកសិ-ពាណិជ្ជកម្មបន្លែនិងមាន់ស្រែ ដែល មានចំនួនសរុប ១ ៤៤៤សំណើ ស្មើនឹងទឹកប្រាក់សរុបចំនួន ១ ១៥៣ ៨៧ពាន់ដុល្លារអាម៉េរិក។ ការគាំទ្រ លើសំណើវិនិយោគទាំងនោះនឹងឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធ ប្រឆាំងជំងឺកូវីដ-១៩ ដោយផ្តល់អាទិភាពខ្ពស់ជូនដល់គ្រួសារកសិករ ដែលមានជីវភាពស្ថិតក្នុងស្ថានភាព ក្រ១ និងក្រ២ គ្រួសារកសិករងាយរងគ្រោះ និងគ្រួសារដែលទទួលផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់
- បានចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការពង្រឹកកិច្ចសហប្រតិបត្តិការលើការអនុវត្តគម្រោងជំរុញ ទីផ្សារសម្រាប់កសិកម្មខ្នាតតូច AIMS រវាងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) និងគម្រោង AIMS និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី (AMK) ដោយហេតុថា ARDB បានទទួល មូលនិធិហិរញ្ញប្បទាន ជាប្រាក់កម្ចីមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD) តាមរយៈរាជ រដ្ឋាភិបាលកម្ពុជា យោងលើកិច្ចព្រមព្រៀងហិរញ្ញប្បទាន(IFAD Loan No.2000001751)
- បានធ្វើការគាំទ្រ និងពង្រឹងបច្ចេកទេសដល់ក្រុមកសិករផលិត តាមរយៈការផ្សព្វផ្សាយការបណ្តុះបណ្តាល បច្ចេកទេស ទស្សនកិច្ចសិក្សា និងការរៀបចំទិវាស្រែ/ចំការបង្ហាញ ដោយមានបានចុះកិច្ចព្រមព្រៀងជាមួយ ដៃគូផ្តល់សេវាបច្ចេកទសចំនួន ៣ ក្នុងការជំរុញ និងលើកកម្ពស់ពិពិធកម្មកសិកម្ម សម្រាប់ក្រុមកសិករ ផលិតតាមរយៈការផ្សព្វផ្សាយ ការបណ្តុះបណ្តាល ការធ្វើការបង្ហាញគំរូអាជីវកម្ម ទស្សនកិច្ចសិក្សា និង ការរៀបចំទិវាស្រែ/ចំការបង្ហាញដែលអនុវត្តន៍ដោយដៃគូបច្ចេកទេសទាំងនោះរួមមាន៖ អគ្គនាយកដ្ឋាន កសិកម្មនៃក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ (GDA) លើផលិផលដំឡូងមី ក្រុមហ៊ុន ជី អាយ ស៊ី

(GIC) លើផលិផលមាន់ស្រែ និងក្រុមហ៊ុនកសិដ្ឋានលាស់ថ្មី(KLT) លើផលិផលបន្លែ

- បានរៀបចំអភិវឌ្ឍន៍វេបសាយ (Website) របស់គម្រោងផ្ទាល់ និងតំណភ្ជាប់ជាមួយគម្រោងផ្សេងៗដែលផ្តល់ដោយមូលនិធិIFAD និងរាជរដ្ឋាភិបាល(aimsmoc.com) ដូចជា កម្មវិធីASPIRE និងគម្រោងSAAMBAT រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ(MIS) និងការប្រមូលទិន្នន័យតាមរយៈTablet សម្រាប់ការគ្រប់គ្រងគម្រោង និងរៀបចំបោះពុម្ព ផលិតឯកសារបច្ចេកទេស ករណីសិក្សា និងឯកសារសម្រាប់ផ្សព្វផ្សាយផ្សេងទៀត

យោងតាមបេសកកម្មត្រួតពិនិត្យ និងការវាយតម្លៃពាក់កណ្តាលគម្រោងរបស់ក្រុមការងារ IFAD គម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូចAIMS ទទួលបានការវាយតម្លៃល្អពេញចិត្ត (Satisfactory) គឺពិន្ទុ៥លើពិន្ទុសរុបចំនួន ៦។

## ៤. ការងារពាណិជ្ជកម្ម អន្តរជាតិ និងសមាហរណកម្មសេដ្ឋកិច្ច[3]

### ៤.១. ការធ្វើសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម ទ្វេភាគី អនុតំបន់ និងសមាហរណកម្មសេដ្ឋកិច្ច

- ទទួលបានការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) ក្រោយពីបានចុះហត្ថលេខាកាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២០។ កិច្ចព្រមព្រៀងនេះនឹងគ្របដណ្តប់លើៈ (១)ប្រជាជនប្រមាណ ២,២ពាន់លាននាក់ ឬ៣០% នៃចំនួនប្រជាជនពិភពលោក (២) ផលិតផលក្នុងស្រុកសរុបប្រមាណ ២៦,២ទ្រីលានដុល្លារអាម៉េរិក ឬ៣០% នៃផលិតផលក្នុងស្រុកសរុប របស់ពិភពលោក និង (៣)ទំហំពាណិជ្ជកម្មចំនួនប្រមាណ ២៨%នៃទំហំពាណិជ្ជកម្មពិភពលោកទាំងមូល
- បានចូលរួមការពារសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី១ នៃវិសោធនកម្មកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋាភិបាល នៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងជប៉ុន(AJCEP)
- បានទទួលការអនុម័តយល់ព្រមផ្តល់សច្ចាប័នពីរដ្ឋសភាជាតិ លើពិធីសារសម្រាប់អនុវត្តន៍កញ្ចប់សន្យាទី១០ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ានស្តីពីសេវាកម្ម(ATISA)
- កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-ចិន ត្រូវបានបញ្ចប់នីតិវិធីផ្ទៃក្នុង១០០% និងឡាយព្រះហស្តលេខាប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០២១/០០៩ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-ចិនCCFTA នៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១
- បានបញ្ចប់ការចរចា និងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-កូរ៉េ CKFTA ជាបីភាសា គឺភាសាខ្មែរ ភាសាកូរ៉េ និងភាសាអង់គ្លេស កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១
- បានចូលរួមចរចាលើឯកសារយោងសម្រាប់បង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា
- បានធ្វើបច្ចុប្បន្នភាពលើប្រតិទិនកិច្ចប្រជុំក្រោមសសរស្តម្ភសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២២ កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ និងបានធ្វើជូនលេខាធិការដ្ឋានអាស៊ាន ដើម្បីពិនិត្យនិងផ្តល់យោបល់បន្ថែម។ ចំពោះបញ្ជីបឋមនៃសមិទ្ធផលអាទិភាពសេដ្ឋកិច្ច(PEDs) ក្រោមភាពជាប្រធានអាស៊ានរបស់កម្ពុជាក្នុងឆ្នាំ២០២២ បានប្រមូលធាតុចូលពីអន្តរក្រសួង-ស្ថាប័នពាក់ព័ន្ធ
- បានរៀបចំកិច្ចប្រជុំក្រុមការងារជាន់ខ្ពស់ ដើម្បីជំរុញគម្រោងវិនិយោគអាទិភាពរួមកម្ពុជា-រុស្សី។

### ៤.២. ការធ្វើសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មជាមួយអឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិក

- បានរៀបចំ និងចូលរួមក្នុងជំនួបជាមួយប្រធានផ្នែកកិច្ចសហប្រតិបត្តិការនៃប្រតិភូសហភាពអឺរ៉ុបប្រចាំនៅ

[3] ប្រភព៖ អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ

កម្ពុជា ដោយបានពិភាក្សាពីកម្មវិធីណែនាំពហុឆ្នាំសម្រាប់ឆ្នាំ២០២១-២០២៧ របស់សហភាពអឺរ៉ុបដើម្បីជួយគាំទ្រដល់ការតភ្ជាប់ និងការធ្វើសមាហរណកម្មរបស់កម្ពុជា នៅក្នុងតំបន់អាស៊ានដែលឈានដល់ការសម្រេចបាននូវការស្តារសេដ្ឋកិច្ចឡើងវិញ ប្រកបដោយចីរភាព និងបរិយាប័ន្ន

- បានចូលរួមឆ្លើយកម្រងសំណួរ និងផ្សព្វផ្សាយដល់ស្ថាប័នរដ្ឋ និងវិស័យឯកជនពាក់ព័ន្ធ ពីយន្តការប្រព័ន្ធអនុគ្រោះពន្ធទូទៅថ្មី របស់ចក្រភពអង់គ្លេស ដែលគ្រោងនឹងចូលជាធរមាននៅពេលខាងមុខ
- បានសហការរៀបចំយ៉ាងជោគជ័យនូវវេទិកាសេដ្ឋកិច្ច និងធុរកិច្ចអាស៊ី-អឺរ៉ុបលើកទី១ ក្រោមមូលបទ «ការផ្លាស់ប្តូរទៅរកគន្លងប្រក្រតីភាពថ្មី៖ ការធ្វើអានុភាវូបនីយកម្មខ្សែច្រវាក់តម្លៃសកល ពហុភាគីនិយម និងបដិវត្តឧស្សាហកម្មជំនាន់ទី៤»
- បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ចរវាងកម្ពុជា-ហុងគ្រី ដែលនឹងជួយជំរុញលើវិស័យសំខាន់ៗមួយចំនួនរួមមាន៖ វិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគ កសិកម្ម ទេសចរណ៍ និងឧស្សាហកម្ម
- បានរៀបចំកិច្ចប្រជុំលើកទី៣ នៃក្រុមការងាររួម ស្តីពីកិច្ចសហប្រតិបត្តិការកម្ពុជា-គណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី(EAEU) ដើម្បីពិនិត្យ និងតាមដាន លើវឌ្ឍនភាពការអនុវត្តលើវិស័យអាទិភាពមួយចំនួនរួមមាន៖
    - ក. កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងវិនិយោគ នីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្មរបាំងបច្ចេកទេសពាណិជ្ជកម្ម បទប្បញ្ញត្តិបច្ចេកទេសអនាម័យ និងភូតគាមអនាម័យ និងកម្មសិទ្ធិបញ្ញា
    - ខ. បានរៀបចំកិច្ចប្រជុំទ្វេភាគីលើកទី២ នៃក្រុមការងារជាន់ខ្ពស់កម្ពុជា-រុស្ស៊ី ដោយផ្តោតលើគម្រោងអាទិភាពចំនួន ៥រួមមាន៖ គម្រោងផលិតកម្មជំបូលស៊ីប្រូ គម្រោងវិនិយោគបង្កើតផលិតកម្មដំឡើងយានយន្តម៉ាក KAMAZ គម្រោងវិនិយោគបំពាក់ឡដុតសំណល់រឹង សម្រាប់រាជធានីភ្នំពេញ គម្រោងសាងសង់ឡសម្ងួត ឬដុតកាកសំណល់កសិកម្ម អង្កាម ឬចំបើង និងគម្រោងផ្គត់ផ្គង់ឧបករណ៍បណ្តាញ Network សម្រាប់ប្រព័ន្ធអ៊ីនធឺណិតរហ័ស ដែលគម្រោងទាំងអស់នេះនឹងជំរុញឱ្យមានការវិនិយោគបន្ថែមទៀតពីភាគីរុស្ស៊ី
    - គ. រៀបចំប្រជុំទ្វេភាគី ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម បច្ចេកវិទ្យាព័ត៌មាន ទូរគមនាគមន៍ អប់រំ និងវិនិយោគជាមួយប្រទេសអារ៉ាប់រួមអេមីរ៉ាត់ គុយវែត និងម៉ូរ៉ុក។

## ៤.៣. កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មជាមួយទ្វីបអាម៉េរិក

- រៀបចំកិច្ចប្រជុំជាមួយភាគីអាម៉េរិក ផ្តោតលើការជំរុញធុរកិច្ច និងការវិនិយោគរបស់ក្រុមហ៊ុនអាម៉េរិកនៅកម្ពុជា ការដោះស្រាយបញ្ហាពលកម្ម ការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យឌីជីថល ក៏ដូចជាបរិស្ថាន ដោយទទួលបានលទ្ធផលគួរជាទីគាប់ចិត្ត ហើយបានពិភាក្សាពីលទ្ធភាពក្នុងការពង្រីកទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរ និងការងារអាទិភាពផ្សេងទៀតពាក់ព័ន្ធនឹងការត្រៀមខ្លួនធ្វើជាប្រធានអាស៊ានឆ្នាំ២០២២ របស់កម្ពុជា ដែលភាគីអាម៉េរិកសន្យាគាំទ្រ
- រៀបចំលិខិតឆ្លើយតប និងឯកសារជំនួយស្មារតី ស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មកម្ពុជា-សហរដ្ឋអាម៉េរិកក្រោមក្របខណ្ឌពាណិជ្ជកម្មជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាធាតុចូលដើម្បីរៀបចំឯកសារជំនួយស្មារតីជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំជំនួបពិភាក្សាការងារជាមួយគណៈប្រតិភូក្រុមប្រឹក្សាធុរកិច្ច សហរដ្ឋអាម៉េរិក-អាស៊ាន (US-ABC) ក្រោមបេសកកម្ម US-ABC to the 53rd ASEAN Economic Ministers' Meeting តាមប្រព័ន្ធវីដេអូ

- បានសហការជាមួយទីប្រឹក្សាពាណិជ្ជកម្មកម្ពុជាប្រចាំសហរដ្ឋអាមេរិក ចូលរួមជាភាគីក្នុងប្រទេស Alliance of GSP Countries ស្នើសុំសភាសហរដ្ឋអាមេរិកឱ្យពិចារណាលើសុពលភាពនៃប្រព័ន្ធអនុគ្រោះពន្ធទូទៅ (GSP) របស់សហរដ្ឋអាមេរិក
- បានជួបពិភាក្សាជាមួយភាគីកាណាដា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម ដោយស្នើឱ្យកាណាដាផ្តល់ជំនួយបច្ចេកទេស ដើម្បីជួយគាំទ្រដល់ផលិតផលខ្មែរ និងការនាំចេញទៅកាន់ទីផ្សារកាណាដា ព្រមទាំងស្នើភាគីកាណាដាផ្តល់ជំនួយបច្ចេកទេសផ្សេងៗទៀត ដល់សហគ្រាសធុនតូច និងមធ្យម ដើម្បីពង្រឹងសមត្ថភាព ផលិតភាព និងបញ្ជ្រាបខ្លួនឱ្យកាន់តែទូលំទូលាយទៅក្នុងខ្សែប្រវាក់តម្លៃនិងផ្គត់ផ្គង់សកល
- បានរៀបចំឯកសារជំនួយស្មារតី ស្តីពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការកម្ពុជា-ប្រេស៊ីល ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្រាប់កិច្ចប្រជុំពិគ្រោះយោបល់ទ្វេភាគី ជាមួយក្រសួងការបរទេសប្រេស៊ីល។

## ៤.៤. ការងារសមាហរណកម្មពាណិជ្ជកម្មពិភពលោក

- បានរៀបចំ និងចូលរួមកិច្ចប្រជុំស្តីពីការធ្វើកំណែទម្រង់អង្គការ WTO៖ ដំណើរឆ្ពោះទៅកាន់ប្រព័ន្ធពាណិជ្ជកម្មពហុភាគីប្រកបដោយចីរភាព និងប្រសិទ្ធភាព ជាមួយគណៈប្រតិភូសហភាពអឺរ៉ុប(EU) និងប្រធានផ្នែកពាណិជ្ជកម្ម និងសេដ្ឋកិច្ចសហភាពអឺរ៉ុបនៃប្រតិភូEU ប្រចាំប្រទេសថៃ ដោយពិភាក្សាលើយន្តការរបស់សហភាពអឺរ៉ុបដែលបានដាក់ចេញដើម្បីធ្វើកំណែទម្រង់អង្គការ WTO
- បានជួបប្រជុំពិភាក្សាកម្រិតបច្ចេកទេស ជាមួយតំណាងក្រុមការងារ ARISE Plus Cambodia និងក្រុមហ៊ុនមេធាវី Bun & Associates ដើម្បីផ្លាស់ប្តូរយោបល់ទៅលើឯកសារ Baseline Study and Monitoring Recommendations ពាក់ព័ន្ធនឹងការសន្យា(Commitment) របស់កម្ពុជាក្រោមក្របខ័ណ្ឌ WTO និង ASEAN តាមរយៈប្រព័ន្ធវីដេអូ
- បានរៀបចំឯកសារពាក់ព័ន្ធ និងចូលរួមការពារការស្នើសុំផ្តល់សច្ចាប័នលើពិធីសារអាស៊ាន ស្តីពីការពង្រឹងយន្តការដោះស្រាយវិវាទ(EDSM)ជាមួយគណៈកម្មការជំនាញនៃរដ្ឋសភា និងព្រឹទ្ធសភាដោយជោគជ័យ និងបានទទួលការអនុម័តយល់ព្រមទាំងស្រុងក្នុងកិច្ចប្រជុំពេញអង្គរដ្ឋសភានិងព្រឹទ្ធសភា ដែលពិធីសារនេះនឹងបង្កើនប្រសិទ្ធភាពយន្តការដោះស្រាយវិវាទក្នុងក្របខ័ណ្ឌអាស៊ាន និងផ្តល់នីតិវិធីពិសេសសម្រាប់ដោះស្រាយវិវាទពាក់ព័ន្ធនឹងប្រទេសអភិវឌ្ឍតិចតួច
- បានសហការរៀបចំឯកសារពាក់ព័ន្ធសម្រាប់គោរពជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចូលរួមនៅវេទិកាសេដ្ឋកិច្ចពិភពលោកនៅខែមករា ឆ្នាំ២០២២(World Economic Forum 2021)
- ដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី១២ (MC12) និងកិច្ចប្រជុំតុមូលចិនលើកទី១០ ស្តីពីការចូលជាសមាជិក WTO (10th China Round Table on WTO Accessions)
- បានសហការរៀបចំកិច្ចប្រជុំទ្វេភាគីជាមួយប្រទេសដៃគូពាណិជ្ជកម្ម និងអង្គការអន្តរជាតិមួយចំនួន ក្នុងអំឡុងពេលចូលរួមកិច្ចប្រជុំសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី១២ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ដោយផ្តោតសំខាន់លើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម
- បានពិនិត្យ និងផ្តល់ព័ត៌មានជូនអង្គការWTO ស្តីពីការឧបត្ថម្ភធននិងវិធានការប៉ះប៉ូវ ការប្រឆាំងនឹងការលក់បង្ខូចថ្លៃ ទិន្នន័យពាក់ព័ន្ធនឹងអត្រាពន្ធគយ និងពន្ធអាករផ្សេងៗ នីតិវិធីរឹតត្បិតបរិមាណទំនិញនាំចេញ-នាំចូល វិធានការពាណិជ្ជកម្ម និងវិធានការដែលបានដាក់ចេញក្នុងអំឡុងពេលជំងឺឆ្លងកូវីដ-១៩។

## ៤.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងជំនួយ

- អនុវត្តគម្រោងGo4eCam ស្របតាមផែនការការងារ និងផែនការថវិកា ដែលក្នុងគម្រោងនេះបានបង្កើតផ្សារអេឡិចត្រូនិកឈ្មោះថាផ្សារខេមបូឌាត្រេដធ្វើប្រតិបត្តិការតាមរយៈគេហទំព័រCambodiatrade.com ដើម្បីជួយដល់សហគ្រាសធុនតូច និងមធ្យម លក់ផលិតផលខ្មែរសម្រាប់ទីផ្សារក្នុងស្រុក និងអន្តរជាតិ
- បានសហការជាមួយអង្គការ UNDP និងសហគ្រិនខ្មែរ ក្នុងការរៀបចំកម្មវិធីចំនួនពីរ គឺកម្មវិធីបណ្តុះបណ្តាល និងកម្មវិធីប្រកួតប្រជែងភាពច្នៃប្រឌិត ដើម្បីផ្តល់ជំនាញឌីជីថល និងសហគ្រិនភាពដល់បណ្តាសហគ្រាសកម្ពុជា
- បានធ្វើការផ្សព្វផ្សាយ ស្តីពីយុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកចំនួន ៣លើក គឺផ្សព្វផ្សាយទៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាគមធុរកិច្ចស៊ីសនៅកម្ពុជា និងសហគ្រិនខ្មែរ
- បានសហការរៀបចំសិក្ខាសាលា ស្តីពីការកសាងសមត្ថភាពអ្នកចរចាចំនួន ៦លើក និងរៀបចំកិច្ចប្រជុំគណៈកម្មាធិការតម្រង់ទិសគម្រោងចំនួន ២លើក ដើម្បីអនុម័តគម្រោងស្រាវជ្រាវចំនួនពីរ គឺការសិក្សាពីសក្តានុពលនៃកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងការសិក្សាលទ្ធភាពបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី
- បានចូលរួមកិច្ចប្រជុំទ្វេភាគីជាមួយស្ថានទូតអូស្ត្រាលី (DFAT Australia) ដើម្បីពិភាក្សារកជាតុចូលសំខាន់ៗក្នុងការស្នើសុំគម្រោងពីកម្មវិធីអភិបាលកិច្ចសេដ្ឋកិច្ច និងគោលនយោបាយហេដ្ឋារចនាសម្ព័ន្ធ
- បានចូលរួមផ្តល់យោបល់លើជំនួយឯកសារបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពី "Enabling a Conductive Environment for the Digital Economy (TA 6618-REF)"
- បានលើកសំណើទៅធនាគារអភិវឌ្ឍន៍អាស៊ី និងអូស្ត្រាលី ដើម្បីស្នើសុំការគាំទ្រការអនុវត្តម៉ាទ្រីសសកម្មភាពក្នុងឯកសារយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា(CTIS) 2019-2023 ដែលក្នុងនោះធនាគារអភិវឌ្ឍន៍អាស៊ីបានចាប់អារម្មណ៍ចំពោះការជួយគាំទ្រផ្នែកបច្ចេកទេសចំពោះការវិភាគលើ FTA Utilization Strategy ដែលផ្តួចផ្តើមដោយក្រសួងពាណិជ្ជកម្ម
- បានរៀបចំសំណើគម្រោងថ្មីឈ្មោះថា "Institutional Reform of Trade Training and Research Institute (TTRI) and Development of an FTA Knowledge and National Trade Negotiation Secretariat" សម្រាប់ការអនុវត្តរយៈពេល ១២ខែ ក្រោមថវិកាជំនួយរបស់ GIZ។

# ៥. ការងារជំរុញពាណិជ្ជកម្ម [4]

## ៥.១. ការរៀបចំ និងចូលរួមពិព័រណ៍ពាណិជ្ជកម្ម

### ក. ពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេស

- បានសម្របសម្រួលជូនវិស័យឯកជន និងសភាពាណិជ្ជកម្មបារាំងប្រចាំនៅកម្ពុជា ក្នុងការជ្រើសរើសផលិតផលសិប្បកម្មល្អៗ "ផលិតផលសៀមរាប / Made in Siem Reap" មកដាក់តាំងបង្ហាញ និងធ្វើជំនួបពាណិជ្ជកម្ម នៅរាជធានីភ្នំពេញកាលពីថ្ងៃទី៣០និង៣១ ខែមករា ឆ្នាំ២០២១
- បានសម្របសម្រួលជូនអង្គការ JETRO ជប៉ុន និងសភាពាណិជ្ជកម្មកម្ពុជា និងចូលរួមពិធីសម្ពោធពិព័រណ៍ទំនិញនាំចូលជប៉ុនគុណភាពខ្ពស់ "Good Goods Japan 2021" និងកម្មវិធីជំនួបពាណិជ្ជកម្មដែលបានប្រព្រឹត្តទៅ នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២១ នៅរាជធានីភ្នំពេញ
- បានរៀបចំដាក់តាំងបង្ហាញផលិតផលខ្មែរ និងផលិតផលដែលផលិតក្នុងស្រុក នៅទីស្តីការក្រសួងពាណិជ្ជកម្ម ដើម្បីបង្ហាញជូនភ្ញៀវជាតិ និងអន្តរជាតិ ដែលចូលមកទីស្តីការក្រសួងស្វែងយល់ពីសក្តានុពល និងការអភិវឌ្ឍផលិតផលខ្មែរ សំដៅជំរុញការស្វែងរកដៃគូធុរកិច្ច និងការវិនិយោគ

---

[4] ប្រភព៖ អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម

- ដើម្បីចូលរួមអនុវត្តវិធានការសុខាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងមិនបានរៀបចំសកម្មភាពពិព័រណ៍ក្នុងប្រទេសទេ។ ទន្ទឹមនឹងនេះក្រសួងបានសេចក្តីជូនដំណឹងដល់មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងពាណិជ្ជករ ស្តីពីការផ្អាកជាបណ្តោះអាសន្ន នូវរាល់ការចេញលិខិតអនុញ្ញាតរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ចាប់ពីចុងខែកុម្ភៈ ២០២១ រហូតមកដល់បច្ចុប្បន្ន។

## ខ. ពិព័រណ៍ពាណិជ្ជកម្មនៅក្រៅប្រទេស

- ក្រសួងបានសម្របសម្រួលបញ្ជូនក្រុមហ៊ុន និងសហគ្រាសកម្ពុជាចំនួន ៧ ចូលរួមលក់ផលិតផលក្នុង Web Portal តាមអនឡាញអាស៊ាន «ASEAN Online Sale Day» ដែលត្រូវបានរៀបចំឡើងដោយប្រទេសប្រ៊ុយណេ ក្នុងឋានៈជាប្រធានអាស៊ានឆ្នាំ២០២១ ដោយបានសហការជាមួយប្រទេសសិង្ហបុរី និងវៀតណាម ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី៨-១០ ខែសីហា ឆ្នាំ២០២១
- បានចូលរួមរៀបចំពិព័រណ៍ចិន-អាស៊ាន លើកទី១៨ ឆ្នាំ២០២១ តាមរយៈការចូលរួមដោយផ្ទាល់ផង និងតាមអនឡាញផង ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី១០-១៣ ខែកញ្ញា ២០២១ នៅទីក្រុងណាននីង នៃ តំបន់ស្វយ័តក្វាងស៊ី ប្រទេសចិន។ ក្រសួងបានសម្របសម្រួលបញ្ជូនក្រុមហ៊ុនចំនួន១៨ ក្នុងនោះក្រុមហ៊ុនចូលរួមផ្ទាល់ មានចំនួន ៧ក្រុមហ៊ុន និងតាមអនឡាញមានចំនួន ១១ក្រុមហ៊ុន ដែលមានស្តង់សរុបចំនួន ៥៣ស្តង់។ ក្រសួងក៏បានរៀបចំផ្ទះរួមមួយទំហំ ៨១ម៉ែត្រការ៉េ ដើម្បីដាក់តាំងផ្សព្វផ្សាយផលិតផល សេវាគម្រោងវិនិយោគ និងវិស័យទេសចរណ៍ និងសមិទ្ធផលនានារបស់រាជរដ្ឋាភិបាលក្នុងព្រឹត្តិការណ៍ពិព័រណ៍នេះផងដែរ
- បានចូលរួមពិព័រណ៍ "Guangdong 21st Century Maritime Silk Road International Expo 2021" ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៤-២៦កញ្ញា ឆ្នាំ២០២១ នៅទីក្រុងក្វាងចូវ ខេត្តក្វាងទុង ប្រទេសចិន។ ក្រសួងបានសហការជាមួយស្ថានកុងស៊ុលកម្ពុជានៅទីក្រុងក្វាងចូវ បញ្ជូនក្រុមហ៊ុនកម្ពុជាដែលមានសាខានៅប្រទេសចិន១ក្រុមហ៊ុន ចូលរួមដោយផ្ទាល់ និងបានរៀបចំផ្ទះរួមមួយទំហំ ៣៦ម៉ែត្រការ៉េ ដោយមានដាក់តាំងផ្សព្វផ្សាយផលិតផលសក្តានុពលមួយចំនួនដូចជាៈ គ្រាប់ស្វាយចន្ទី អង្ករ ម្រេច នំបញ្ចុកក្រៀម ស្ករត្នោត កាហ្វេ មីកញ្ចប់ នំកញ្ចប់ វត្ថុអនុស្សាវរីយ៍ធ្វើពីប្រាក់ ឈើ ស្រាបៀរកំប៉ុង ក្រៅពីនោះមានដាក់តាំង និងចែកជូននូវសៀវភៅព័ត៌មានពាក់ព័ន្ធវិស័យពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ វប្បធម៌ក្នុងពន្លាជាតិផងដែរ
- បានចូលរួមពិព័រណ៍វិនិយោគ និងធុរកិច្ចចិនអន្តរជាតិ លើកទី២១ ឆ្នាំ២០២១ "21st China International fair for Investment and Trade" បានប្រព្រឹត្តទៅចាប់ពីថ្ងៃទី៨-១១ ខែកញ្ញា ឆ្នាំ២០២១ នៅទីក្រុងXiamen ខេត្ត Fujian ប្រទេសចិន ដោយបានចាត់តាំងមជ្ឈមណ្ឌលពាណិជ្ជកម្មកម្ពុជាប្រចាំទីក្រុង Xiamen នាំយកផលិតផលខ្មែរមួយចំនួន និងឯកសារពាក់ព័ន្ធពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ វប្បធម៌ ទៅផ្សព្វផ្សាយផងដែរ
- បានជ្រើសរើសក្រុមហ៊ុនចំនួន៥ បញ្ជូនគំរូផលិតផលចំនួន២៨មុខ ទៅចូលរួមពិព័រណ៍ "ASEAN Trade Fair 2021" ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១០-១៣ ខែវិច្ឆិកា ឆ្នាំ២០២១ នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ
- បានរៀបចំ និងចូលរួមពិព័រណ៍ទំនិញនាំចូលអន្តរជាតិចិន លើកទី៤ ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី៥-១០ ខែវិច្ឆិកា ២០២១ នៅទីក្រុងសៀងហៃ ប្រទេសចិន។ ក្រសួងបានចាត់បញ្ជូនក្រុមហ៊ុនវិនិយោគ The Union Group ដែលមានសាខាតំណាងនៅប្រទេសចិនស្រាប់ ចូលរួមដោយផ្ទាល់ ហើយក្រសួងបានរៀបចំពន្លាជាតិមួយតាមរចនាបថខ្មែរជាទម្រង់ 3D និងបានចាត់បញ្ជូនក្រុមហ៊ុនកម្ពុជាចំនួន ៦ ក្រុមហ៊ុន ចូលរួមពីចម្ងាយតាមប្រព័ន្ធអនឡាញផងដែរ

- បានចូលរួមពិធីបើកកិច្ចប្រជុំ INDO-ASEAN Business Summit and Expo តាមប្រព័ន្ធវីដេអូ(Zoom) ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១ នៅទីស្តីការក្រសួងពាណិជ្ជកម្ម
- បានចូលរួមពិធីបើកសម្ពោធពិព័រណ៍ The 130th China Import Export Fair តាមប្រព័ន្ធវីដេអូ (Zoom) ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ នៅទីស្តីការក្រសួងពាណិជ្ជកម្ម
- បានរៀបចំ និងកំពុងចូលរួមពិព័រណ៍ពិភពលោក ២០២០ ឌុយបៃ មានរយៈពេល៦ខែ ចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២។ ក្រសួងបានរៀបចំពន្លាជាតិកម្ពុជា ប្រកបដោយភាពទាក់ទាញ ដែលមានផ្ទៃក្រឡាទំហំ ៣៨៥ម៉ែត្រការ៉េ តាមរចនាបទការប្រេបាច់បញ្ចូលគ្នា នូវសម័យកាលជាប្រវត្តិសាស្ត្រចំនួន ៤ គឺសម័យមុនអង្គរ សម័យអង្គរ សម័យលង្វែក និងសម័យចតុមុខ ឬសម័យភ្នំពេញបច្ចុប្បន្ន។ ក្រសួងក៏ដាក់តាំងបង្ហាញផលិតផលសក្តានុពលខ្មែរ និងផ្សព្វផ្សាយឯកសារពីទេសចរណ៍ វប្បធម៌ ការជំរុញវិនិយោគ និងពាណិជ្ជកម្មក្នុងពន្លាជាតិផងដែរ
- បានរៀបចំសេចក្តីជូនដំណឹង និងផ្សព្វផ្សាយស្វែងរកក្រុមហ៊ុន/សហគ្រាសកម្ពុជា ចូលរួមពិព័រណ៍ អនឡាញនៅក្រៅប្រទេសបានចំនួន ២៣ព្រឹត្តិការណ៍តាមប្រធានបទផ្សេងៗ ដូចជាពិព័រណ៍ ឧស្សាហកម្ម អេឡិកត្រូនិក កាហ្វេ គ្រឿងឧបភោគបរិភោគ និងសម្ភារៈប្រើប្រាស់ក្នុងគេហដ្ឋានជាដើម។ ពិព័រណ៍ទាំងនេះរៀបចំនៅប្រទេសកូរ៉េ ឥណ្ឌា វៀតណាម សិង្ហបុរី និងនៅប្រទេសចិន។

### គ. ការគ្រប់គ្រងព្រឹត្តិការណ៍ និងការកៀរគរចំណូល

**ការចេញច្បាប់អនុញ្ញាត និងពន្យារពេលនៃការរៀបចំពិព័រណ៍៖**

- បានចេញលិខិតអនុញ្ញាតរៀបចំពិព័រណ៍ឧស្សាហកម្មសំណង់កម្ពុជា-អន្តរជាតិ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២-៤ ខែធ្នូ ឆ្នាំ២០២១ នៅមជ្ឈមណ្ឌលពិព័រណ៍ និងសន្និបាតកោះពេជ្រ
- បានចេញលិខិតអនុញ្ញាតរៀបចំពិព័រណ៍ពាណិជ្ជកម្មផលិតផលថៃ (Mini Thailand Week 2021) ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៦-២៩ ខែសីហា ឆ្នាំ២០២១ នៅផ្សាររភ្ជុយ ខេត្តបាត់ដំបង
- បានចេញលិខិតអនុញ្ញាតពន្យារពេលរៀបចំពិព័រណ៍ពាណិជ្ជកម្មចំនួន ៩ច្បាប់។

**ចំណូលពីការចេញលិខិតអនុញ្ញាត៖**

- ចំណូលពីការចេញច្បាប់អនុញ្ញាតចំនួន ២ ច្បាប់ x ១ ៤០០ ០០០ រៀល = ២ ៨០០ ០០០ រៀល

**ចំណូលសរុប = ២ ៨០០ ០០០ រៀល**

- ចំណូលពីការគ្រប់គ្រងព្រឹត្តិការណ៍៖ គ្មាន (អត់មានសកម្មភាពរៀបចំពិព័រណ៍)

## ៥.២. ការងារអភិវឌ្ឍន៍ទីផ្សារ

### ក. ការបណ្តុះបណ្តាលធនធានមនុស្ស និងចូលរួមកិច្ចប្រជុំក្នុងការងារជំរុញពាណិជ្ជកម្ម

- បានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាចំនួន ១៣លើកតាមប្រព័ន្ធអនឡាញ
- បានចូលរួមកិច្ចប្រជុំស្តីពីការកែសម្រួលសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នារវាង ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងក្រុមហ៊ុន Cambodia (Xi'an) Commercial Center Co., Ltd
- បានចូលរួមកិច្ចប្រជុំដើម្បីត្រៀមរៀបចំកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធឆ្នាំ២០២២ ចំនួន ៤លើក
- បានចូលរួមកិច្ចប្រជុំដើម្បីរៀបចំកិច្ចប្រជុំវេទិកាសេដ្ឋកិច្ច និងធុរកិច្ចអាស៊ីអឺរ៉ុប-AEEBF1 ចំនួន ៤៣លើក
- បានចូលរួមកិច្ចប្រជុំកែសម្រួល សេចក្តីព្រាងអនុស្សរណៈយោគយល់គ្នារវាងក្រសួងពាណិជ្ជកម្ម និងក្រុមហ៊ុន Quangxi Dongbo International Economic and Trade Investment Co., Ltd. និង "កែសម្រួលសេចក្តីព្រាងអនុស្សរណៈយោគយល់គ្នា លើសំណង់អគាររបស់តំណាងពាណិជ្ជកម្ម នៅទីក្រុងណាននីង ប្រទេសចិន"

- បានចូលរួមកិច្ចប្រជុំកែសម្រួលប្រកាសស្តីពី "ការកំណត់នីតិវិធីសម្រាប់ផ្តល់ការអនុញ្ញាតឱ្យបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជានៅក្រៅប្រទេស" និងកិច្ចប្រជុំកំពូល INDO-ASEAN Business Summit and Expo។

## ខ. ការសហប្រតិបត្តិការដៃគូពាណិជ្ជកម្ម

- បានសហការជាមួយមជ្ឈមណ្ឌលអាស៊ាន-ជប៉ុន រៀបចំសិក្ខាសាលា ស្តីពី "ការផ្លាស់ប្តូរខ្សែច្រវាក់ផ្គត់ផ្គង់កសិពាណិជ្ជកម្មកម្ពុជា (Cambodia Agribusiness Supply Chain Transformation)" តាមប្រព័ន្ធវីដេអូ
- បានរៀបចំលិខិតជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្តីពីសំណើសុំអន្តរាគមន៍ជួយបញ្ជូនគម្រោងផែនការសកម្មភាពជាតិ (ASEAN National Activities) សម្រាប់ជំរុញវិស័យពាណិជ្ជកម្ម ដើម្បីឆ្លើយតបតាមគម្រោងសកម្មភាពជាតិប្រចាំឆ្នាំមជ្ឈមណ្ឌលអាស៊ាន-ជប៉ុន
- ដោយបានទទួលគោលការណ៍ពី ឯកឧត្តមរដ្ឋមន្ត្រី ក្រុមការងារបានធ្វើជាសាក្សីក្នុងពិធីចុះហត្ថលេខា និងប្រថាប់ត្រារបស់តំណាងពាណិជ្ជកម្មកម្ពុជា អមស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន លើកិច្ចព្រមព្រៀងក្របខ័ណ្ឌសហប្រតិបត្តិការ រវាងទីក្រុងចឹងចូវ ខេត្តហឺណាន និងក្រុមហ៊ុនកម្ពុជា អង្គរអ៊ែរ
- បានធ្វើសំណើសុំរៀបចំចងក្រង និងបោះពុម្ពសៀវភៅគំរូផលិតផលសក្តានុពលផលិតនៅកម្ពុជាសម្រាប់ផ្សព្វផ្សាយផលិតផលខ្មែរទៅទីផ្សារអន្តរជាតិ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់មជ្ឈមណ្ឌលអាស៊ាន-ជប៉ុន។

## គ. យុទ្ធសាស្ត្រជំរុញទីផ្សារ និងផ្តល់សេវាព័ត៌មានទីផ្សារ និងផ្សព្វផ្សាយ

- បានរៀបចំគេហទំព័រផ្លូវការ សម្រាប់ផ្សព្វផ្សាយឯកសារជំរុញពាណិជ្ជកម្ម និងព័ត៌មានថ្មីៗពីសកម្មភាពការងារក្នុងវិស័យពាណិជ្ជកម្ម និងការតាំងបង្ហាញផលិតផលសក្តានុពលខ្មែរក្នុងគេហទំព័រផ្លូវការនេះ
- បានកែសម្រួលប្រកាស ស្តីពី "ការកំណត់នីតិវិធីសម្រាប់ផ្តល់ការអនុញ្ញាតឱ្យបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជានៅក្រៅប្រទេស"
- បានរៀបចំកិច្ចប្រជុំ តាមប្រព័ន្ធវីដេអូអនឡាញ ជាមួយតំណាងផ្សារទំនើប ដើម្បីពិភាក្សា ជួយសម្របសម្រួល រកដំណោះស្រាយ ចំពោះផលវិបាកក្នុងការធ្វើអាជីវកម្មក្នុងពេលបិទខ្ទប់នៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅ
- បានរៀបចំបូកសរុបទិន្នន័យតម្លៃទំនិញដែលជាតម្រូវការចាំបាច់ ដែលមានក្នុងផ្សារទំនើបចំនួន ៦ក្នុងរាជធានីភ្នំពេញដូចជា៖ ផ្សារទំនើបអេអនម៉ល ផ្សារទំនើបម៉ាក្រូ ផ្សារទំនើបឡាក់គី ផ្សារទំនើបស៊ូភើស្ទ័រ ផ្សារទំនើបបាយ័ន និងផ្សារទំនើបជីបម៉ុង
- បានរៀបចំជំនួយស្មារតី និងឯកសារពាក់ព័ន្ធ ស្តីពី Silk Road E-Commerce Cooperation សម្រាប់ការចូលរួមវេទិកាតុមូល "2021 Silk Road E-Commerce Cooperation (Xi'an) Roundtable" ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានរៀបចំលិខិតអញ្ជើញសភាពាណិជ្ជកម្មកម្ពុជា ទាក់ទងនឹងការចូលរួមវេទិកាធុរកិច្ចសាកល ស្តីពីអាស៊ានឆ្នាំ២០២១ (Global Business Forum on ASEAN) នៅទីក្រុងឌុយបៃ ប្រទេសអារ៉ាប់រួម
- ចូលរួមជាវាគ្មិនក្នុងកិច្ចប្រជុំកំពូល "6th Belt and Road Summit" ដែលរៀបចំដោយតំបន់រដ្ឋបាលពិសេសហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន
- បានបំពេញកិច្ចការជាក្រុមការងារលេខាធិការដ្ឋានរៀបចំវេទិកាសេដ្ឋកិច្ច និងធុរកិច្ច អាស៊ី-អឺរ៉ុបលើកទី១ នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១។

**ឃ. ការងារទំនាក់ទំនងតំណាងពាណិជ្ជកម្មក្រៅប្រទេស**

- បានរៀបចំកំណត់បង្ហាញស្តីពីសំណើសុំបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជា នៅទីក្រុងAtsugi ខេត្ត Kanagawa ប្រទេសជប៉ុន
- បានរៀបចំគោលការណ៍គោរពជូន **ឯកឧត្តមរដ្ឋមន្ត្រី** ពិនិត្យ និងសម្រេចលើករណីសំណើសុំសិក្សាលទ្ធភាពផ្លាស់ប្តូរទីតាំងការិយាល័យពាណិជ្ជកម្មកម្ពុជាប្រចាំក្រុងណាននី ឬបន្ថែមជាការិយាល័យតំណាងពាណិជ្ជកម្មកម្ពុជា (Representative Office) នៅអគារមជ្ឈមណ្ឌលពាណិជ្ជកម្មចិនអាស៊ាន នៃទីក្រុងណាននីង របស់Mr. Wang Lei, Director General of Guangxi Expo Bureau
- បានរៀបចំសំណើសុំរៀបចំអាណត្តិថ្មី សម្រាប់អនុព័ន្ធពាណិជ្ជកម្មអមស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន ដែលមានការិយាល័យតំណាងពាណិជ្ជកម្ម នៅទីក្រុងណាននីង នៅឆ្នាំ២០២១
- បានរៀបចំលិខិតឆ្លើយតបទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទាក់ទងនឹងករណីសំណើសុំបង្កើតការិយាល័យពាណិជ្ជកម្មរបស់សាធារណរដ្ឋវ៉ានូទូ នៅរាជធានីភ្នំពេញ
- បានសម្របសម្រួលលើការរៀបចំស្ថានតំណាងពាណិជ្ជកម្ម ប្រចាំនៅក្រៅប្រទេសមានចំនួន ១៩ទីតាំង (ប្រទេសចិនមាន៤ទីតាំង) មានមន្ត្រី១៩រូប (ស្ត្រី៣រូប) ដូចជា៖ ១-អូស្ត្រាលី និងណូវែលហ្សេឡង់ ២-ឥណ្ឌូនេស៊ី ៣-សហរដ្ឋអាមេរិក ៤-ម៉ាឡេស៊ី ៥-សិង្ហបុរី ៦-ទីក្រុងណាននីង(ចិន) ៧-សាធារណៈរដ្ឋកូរ៉េ ៨-សហពន្ធ័ស្វីស ៩-វៀតណាម ១០-បែលហ្សិក ១១-ថៃ ១២-ទីក្រុងប៉េកាំង(ចិន) ១៣-ជប៉ុន ១៤-សហព័ន្ធរុស្ស៊ី ១៥-ចក្រភពអង់គ្លេស ១៦-ហ្វីលីពីន ១៧-សធារណរដ្ឋតួកគី ១៨-ទីក្រុងក្វាងចូវ(ចិន) ១៩-ទីក្រុងសៀងហៃ(ចិន)។ ដោយឡែកក្នុងឆ្នាំ២០២១ មិនមានការបើកបន្ថែមទេ
- បានបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជានៅក្រៅប្រទេស ចំនួន ៩ ទីតាំង រួមមាន៖ ទីក្រុងហាយនីង ទីក្រុងក្វាងចូវ ទីក្រុងស៊ីអាន ទីក្រុងហុងកុង ទីក្រុងយានថាយ ទីក្រុងគុនមិញ ទីក្រុងសៀវមិន ទីក្រុងធឹងទូ និងទីក្រុងហៃគូ (ក្នុងឆ្នាំ២០២១បាន ចំនួន ៣៖ (១).ទីក្រុងសៀវមិន ខេត្តហ្វូជៀន (២). ទីក្រុងធឹងទូ ខេត្តស៊ីឈួន (៣).ទីក្រុងហៃគូ ខេត្តហៃណាម)។

## ៥.៣. ការងារអភិវឌ្ឍគោលនយោបាយពាណិជ្ជកម្ម

### ក. គោលនយោបាយជាតិស្តីពីជំឡុងមី ២០២០-២០២៥

- បានរៀបចំ "ពិធីប្រកាសផ្សព្វផ្សាយជាផ្លូវការគោលនយោបាយជាតិស្តីពីជំឡូងមី ២០២០-២០២៥" នៅថ្ងៃទី១៤ ខែមករា ២០២១ បន្ទាប់ពីបានឯកភាពក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១៤ ខែសីហា ២០២០
- បានរៀបចំប្រកាសលេខ១៩៣ ពណ.គនព ចុះថ្ងៃទី២៧ កញ្ញា ២០២១ ស្តីពីការបង្កើតក្រុមការងារអន្តរស្ថាប័ន សម្រាប់ពិនិត្យតាមដាន វាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីជំឡូងមី២០២០-២០២៥។

### ខ. គោលនយោបាយជាតិស្វាយចន្ទីកម្ពុជា

- បានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ បញ្ចប់សេចក្តីព្រាងគោលនយោបាយជាតិស្តីពីស្វាយចន្ទី ២០២២-២០២៧ កម្រិតបច្ចេកទេស ដោយឆ្លងកាត់កិច្ចប្រជុំកម្រិតបច្ចេកទេស កិច្ចប្រជុំផ្ទៃក្នុង និងកិច្ចប្រជុំអន្តរក្រសួងដោយផ្ទាល់ និងតាមប្រព័ន្ធវីដេអូចំនួន ១៤លើក
- បាន និងកំពុងប្រមូលធាតុចូលបំពេញបន្ថែម លើសេចក្តីព្រាងគោលនយោបាយជាតិស្តីពីស្វាយចន្ទីនេះពីក្រសួង-ស្ថាប័ន និងសមាគម-ក្រុមហ៊ុនឯកជនពាក់ព័ន្ធ មុននឹងដាក់ឆ្លងទីស្តីការគណៈរដ្ឋមន្ត្រី បន្ទាប់ពីបានរៀបចំកិច្ចប្រជុំក្រុមការងារចម្រុះចុងក្រោយ កាលពីថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូ។

**គ. ការអនុវត្តគោលនយោបាយជាតិ ជំរុញចលនាភូមិ១ផលិតផល១ ក្នុងវិស័យពាណិជ្ជកម្ម**

- រៀបចំ និងបញ្ជូនរបាយការណ៍ការងារចលនាភូមិ១ផលិតផល១ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំជូនអគ្គលេខាធិការដ្ឋានក្រុមការងារជំរុញចលនាភូមិ១ផលិតផល១ នៃទីស្តីការគណៈរដ្ឋមន្ត្រី
- ចូលរួមកិច្ចប្រជុំ ស្តីពីការពិភាក្សា និងវាយតម្លៃការស្នើសុំបញ្ចូលផលិតផលជាសមាជិកចលនា ភូមិ១ផលិតផល១ ឆ្នាំ២០២០-២០២១ ជាមួយគណៈកម្មាធិការជាតិជំរុញចលនា ភូមិ១ផលិតផល១ ក្រុមការងារបច្ចេកទេស និងលេខាធិការដ្ឋាន របស់ខេត្តគោលដៅចំនួន ១០ តាមប្រព័ន្ធវីដេអូចំនួន ៤លើក។

**ឃ. ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា** (IDP) **២០១៥-២០២៥**

- បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយប្រកាស ស្តីពីការកែសម្រួលសមាសភាពក្រុមការងារបច្ចេកទេស សម្រាប់តាមដានគោលនយោបាយ IDP ២០១៥-២០២៥ របស់ក្រសួងពាណិជ្ជកម្ម និងបានកែសម្រួលទម្រង់របាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ IDP តាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រៀបចំរបាយការណ៍រួម ស្តីពីវឌ្ឍនភាពពាក់កណ្តាលអាណត្តិនៃការអនុវត្តគោលនយោបាយ IDP ២០១៥-២០២៥ ក្នុងក្របខ័ណ្ឌក្រសួងពាណិជ្ជកម្ម ផ្ញើជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានចូលរួមកិច្ចប្រជុំអន្តរក្រសួងតាមប្រព័ន្ធវីដេអូ ស្តីពី"ការពិនិត្យ និងពិភាក្សាលើការរៀបចំរបាយការណ៍បឋម វាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្ត IDP ឆ្នាំ២០១៥-២០២៥" ដែលរៀបចំដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ៤លើក។

**ង. ការអនុវត្តយុទ្ធសាស្ត្រអាជីវកម្មបរិយាប័ន្នសម្រាប់កម្ពុជា** (IBeeC)

- បានរៀបចំលិខិតឆ្លើយតបទៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្តីពីការចាត់តាំងសមាសភាពថ្នាក់ឧត្តមមន្ត្រី ១រូប ចូលរួមជាសមាជិកគណៈកម្មាធិការ
- បានពិនិត្យ និងកែសម្រួលលើសេចក្តីព្រាងផែនការសកម្មភាព ៣ឆ្នាំរំកិល ស្តីពីការជំរុញអាជីវកម្ម បរិយាប័ន្នសម្រាប់កម្ពុជា ដែលរៀបចំដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ច. ការងារអភិវឌ្ឍន៍ផលិតផលម្រេច**

បានសហការជាមួយដៃគូអភិវឌ្ឍន៍ ក្នុងការរៀបចំសេចក្តីព្រាងបឋមគោលនយោបាយម្រេចកម្ពុជាជាភាសាអង់គ្លេស និងបានដាក់ឆ្លងកិច្ចប្រជុំចំនួន ៣លើក គឺនៅខេត្តកំពង់ចាម បាត់ដំបង និងភ្នំពេញ។

**ឆ. ការរៀបចំមជ្ឈមណ្ឌលជំរុញអភិវឌ្ឍន៍វិស័យស្ករដីកម្ពុជានៅខេត្តកំពង់ឆ្នាំង**

- បាន និងកំពុងសម្របសម្រួលរៀបចំបង្កើតមជ្ឈមណ្ឌលជំរុញអភិវឌ្ឍវិស័យស្ករដីកម្ពុជា នៅភូមិបាញ់ឆ្កោល ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង
- បានសហការ និងរៀបចំផែនការសកម្មភាព តាមរយៈអនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាងក្រសួងពាណិជ្ជកម្មជាមួយក្រុមហ៊ុន Beyond Retail Business (BRB) ដើម្បីជួយជំរុញ និងបណ្តុះបណ្តាលផ្នែកបច្ចេកទេសលើវិស័យស្ករដីនៅកម្ពុជា និងកំពុងពិនិត្យលទ្ធភាពស្នើសុំពន្យាសុពលភាពនៃ MOU សំដៅអាចបន្តអនុវត្តសកម្មភាពសេសសល់ ក្នុងការងារគាំទ្រលើវិស័យស្ករដីនៅចុងឆ្នាំ២០២២។

**ជ. ការរៀបចំមជ្ឈមណ្ឌលជំរុញអភិវឌ្ឍន៍វិស័យចម្លាក់ប្រាក់-ស្ពាន់កម្ពុជានៅខេត្តកណ្តាល**

ត្រៀមរៀបចំបង្កើត (១)សមាគម សហព័ន្ធចម្លាក់ប្រាក់-ស្ពាន់កម្ពុជា និង(២) មជ្ឈមណ្ឌលជំរុញអភិវឌ្ឍ

វិស័យចម្លាក់ប្រាក់-ស្ពាន់កម្ពុជា ដោយបានចងក្រងក្រុមអ្នកផលិតចម្លាក់ប្រាក់-ស្ពាន់ នៅឃុំកោះចិន និងឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្ដាល។

**ឈ. ការរៀបចំមជ្ឈមណ្ឌលជំរុញអភិវឌ្ឍន៍វិស័យចម្លាក់ថ្មកម្ពុជា នៅខេត្តពោធិ៍សាត់**

បានចុះសិក្សាលើវិស័យចម្លាក់ថ្ម នៅខេត្តពោធិ៍សាត់ចំនួន ១លើក ដើម្បីពិនិត្យលទ្ធភាពក្នុងការបង្កើតមជ្ឈមណ្ឌលជំរុញអភិវឌ្ឍន៍វិស័យចម្លាក់ថ្មកម្ពុជា។

**ញ. ការងារផ្សព្វផ្សាយកិច្ចប្រជុំការបណ្ដុះបណ្ដាល និងកិច្ចការផ្សេងៗ**

- បានសហការជាមួយកម្មវិធីខ្សែច្រវាក់តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី (CAVAC) និងបានរៀបចំរបាយការណ៍សិក្សាទីផ្សារ ស្ដីពីទំនិញកសិកម្មដែលមានតម្លៃខ្ពស់របស់កម្ពុជា ដែលមានដំណាំសក្ដានុពលចំនួន ៩មុខ រួមមាន៖ ផ្លែស្វាយ មៀន ស្វាយចន្ទី ម្ទេស ដំឡូងជ្វា ផ្លែបឺរ ល្ង ស្ករត្នោត និងចេកក្រៀម
- បានរៀបចំពិធីប្រកាសដាក់ឱ្យប្រើប្រាស់ "របាយការណ៍សិក្សាទីផ្សារ ស្ដីពីទំនិញកសិកម្មដែលមានតម្លៃខ្ពស់របស់កម្ពុជា" តាមរយៈប្រព័ន្ធវីដេអូ កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១
- បានចូលរួមកិច្ចប្រជុំលើកទី១នៃគណៈកម្មាធិការអន្តរក្រសួង ស្ដីពីសុខភាពសិក្សា (គ.អ.ស.ស) ដឹកនាំដោយ **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** តាមប្រព័ន្ធវីដេអូ
- រៀបចំលិខិតឆ្លើយតបទៅក្រសួងអប់រំ យុវជន និងកីឡា លើការផ្ដល់យោបល់ពាក់ព័ន្ធនឹងសេចក្ដីព្រាងឯកសារក្នុងកិច្ចប្រជុំលើកទី១ នៃគណៈកម្មាធិការអន្តរក្រសួង ស្ដីពីសុខភាពសិក្សា (គ.អ.ស.ស)
- បានចូលរួមកិច្ចប្រជុំ និងបានរៀបចំលិខិតឆ្លើយតបទៅក្រសួងរ៉ែ និងថាមពល ស្ដីពីការផ្ដល់យោបល់លើសេចក្ដីព្រាងគោលនយោបាយជាតិ ស្ដីពីប្រសិទ្ធភាពថាមពល ២០២១-២០៣០
- បានចូលរួមសិក្ខាសាលា វគ្គបណ្ដុះបណ្ដាលក្នុងប្រទេសចំនួន ២៧លើក និងក្រៅប្រទេស ចំនួន ៤លើក។

**៥.៤. ការងារស្ថានតំណាងពាណិជ្ជកម្មក្រៅប្រទេស**

- បានចូលរួមពិភាក្សាជាមួយទូតសំខាន់ៗ លើសំណើរបស់ប្រទេសឥណ្ឌា និងអាហ្វ្រិកខាងត្បូង ស្ដីពីការលើកលែងក្នុងការអនុវត្តប៉ាតង់ និងបទប្បញ្ញត្តិមួយចំនួន នៃកិច្ចព្រមព្រៀងទាក់ទងនឹងពាណិជ្ជកម្មកម្មសិទ្ធិបញ្ញាក្នុងពេលរីករាលដាលនៃជំងឺកូវីដ១៩
- បានធ្វើការសម្របសម្រួលកិច្ចប្រជុំរវាង ឯកឧត្តមរដ្ឋមន្ត្រី និងលេខាធិការដ្ឋានរបស់WEF និងតាមដានស្ដាប់ការធ្វើបទបង្ហាញទាក់ទងនឹងគំនិតផ្ដួចផ្ដើមផែនទីបង្ហាញផ្លូវហិរញ្ញប្បទានដែលរៀបចំឡើងដោយ WEF
- បានចូលរួមកិច្ចប្រជុំគណៈកម្មការ ស្ដីពី វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអភិវឌ្ឍ ២០២០-២០២១ និងតាមដានស្ដាប់ការធ្វើបទបង្ហាញជុំវិញប្រធានបទ "ការប្រើប្រាស់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ដើម្បីបញ្ចប់គម្លាត និងសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៣ ស្ដីពីសុខភាព និងសុខមាលភាព"
- បានចូលរួមតាមដានស្ដាប់កិច្ចប្រជុំពិភាក្សាគំនិតផ្ដួចផ្ដើមសេចក្ដីថ្លែងការណ៍រួម ស្ដីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ កន្លងមកកិច្ចប្រជុំបានរៀបចំកិច្ចពិភាក្សាជាក្រុមតូចលើបញ្ហា (១)Spam (២)Open Government Data (៣)Online Consumer protection និង(៤)Paperless Trading។ កម្មវិធីបន្ទាប់អង្គប្រជុំបានពិភាក្សាលើបញ្ហា៤ចំនុចក្នុង Group A: Facilitating Electronic Transaction រួមមាន (1)Electronic Transaction Frameworks (2)Electronic Contracts (3)Electronic Invoicing (4)Electronic Payments Services។
- បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការអាស៊ាននៅហ្សឺណែវ (ACG) ថ្នាក់ទូត ជាមួយនឹងលោកជំទាវបណ្ឌិត

Ngozi Okonjo -Iweala ដែលជាអគ្គនាយកថ្មីនៃអង្គការ WTO ដើម្បីធ្វើការសំណេះសំណាល ផ្លាស់ប្តូរមតិយោបល់ផ្សេងៗ និងពង្រឹងកិច្ចសហប្រតិបត្តិការ

- បានចូលរួមកិច្ចប្រជុំថ្នាក់ទូតនៃគណៈកម្មាធិការអាស៊ាននៅទីក្រុងហ្សឺណែវ (ACG) ដើម្បីពិភាក្សាលើការងារចាំបាច់មួយចំនួនដូចជា ការត្រៀមរៀបចំសម្រាប់កិច្ចប្រជុំត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មលើកទី២ របស់មីយ៉ាន់ម៉ា ការរៀបចំជំហរចរចា និងតួនាទីរបស់ប្រធានអាស៊ានជាដើម
- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់តាមប្រព័ន្ធអនឡាញ ទាក់ទងនឹងរបាយការណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក ស្តីពីគោលនយោលបាយនានារបស់រដ្ឋាភិបាល ដើម្បីលើកកម្ពស់ការច្នៃប្រឌិតនៅក្នុងយុគសម័យឌីជីថល (Government policies to promote innovation in the digital age)
- បានចូលរួមសិក្ខាសាលាស្តីពីជំនួយសម្រាប់ពាណិជ្ជកម្ម ដោយធ្វើការពិភាក្សាអំពីផលប៉ះពាល់នៃការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច (LDC Graduation) និងពីតួនាទីរបស់ជំនួយសម្រាប់ពាណិជ្ជកម្មលើបញ្ហាប្រឈមនានាដែលបង្កឡើងដោយជំងឺរាតត្បាតកូវីដ១៩ ពិសេសតួនាទីក្នុងការជួយប្រទេសដែលចាកចេញពីក្រុមLDCs។ ប្រទេសជាដៃគូអភិវឌ្ឍន៍ ក៏មានតួនាទីសំខាន់ក្នុងការគាំទ្រដល់ការខិតខំប្រឹងប្រែងក្នុងការចាកចេញពីក្រុមប្រទេស LDCs ផងដែរ
- បានចូលរួមកិច្ចប្រជុំអគ្គក្រុមប្រឹក្សា ដោយបានតាមដានស្តាប់ និងពិភាក្សាទៅលើបញ្ហាសំខាន់ៗ ដូចជាការស្នើសុំចូលជាសមាជិកអង្គការWTO បញ្ហាក្រុមប្រឹក្សាTRIPS ការបញ្ចប់ការចរចាឧបត្ថម្ភធនជលផល ការរឹតត្បិតការនាំចេញវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩
- បានចូលរួមកិច្ចប្រជុំកម្រិតជំនាញនៃG77 បូកចិន ដែលរៀបចំឡើងដោយ UNCTAD និងបានតាមដានស្តាប់កិច្ចពិភាក្សា ពិសេសការរាយការណ៍អំពីកិច្ចប្រជុំកន្លងមករបស់ Extended Bureau និងដំណើរការពិគ្រោះយោបល់ក្រៅផ្លូវការក្នុងចំណោមអ្នកសម្របសម្រួលក្នុងតំបន់ ទៅលើសេចក្តីព្រាងខ្លឹមសារអត្ថបទសម្រាប់ប្រធានអង្គប្រជុំ UNCTAD 15
- បានចូលរួមកិច្ចប្រជុំគំនិតផ្តួចផ្តើមសេចក្តីថ្លែងការណ៍រួមស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក ដែលប្រធានសម្របសម្រួលបានស្នើឲ្យសមាជិកធ្វើបច្ចុប្បន្នភាព ទៅលើកិច្ចពិភាក្សាក្រៅផ្លូវការ ធ្វើការផ្លាស់ប្តូរ យោបល់ ទស្សនៈវិស័យ និងចោទជាសំណួរចម្លើយទៅលើលទ្ធផលនៃការពិភាក្សានេះ
- បានចូលរួមព្រឹត្តិការណ៍ជំនួយសម្រាប់ពាណិជ្ជកម្ម ស្តីពី "ការច្នៃប្រឌិត ការស្តារឡើងវិញ និងអន្តរកាលនៃប្រព័ន្ធឌីជីថល ដើម្បីឆ្ពោះទៅរកពាណិជ្ជកម្មប្រកបដោយចីរភាព: តើជំនួយសម្រាប់ពាណិជ្ជកម្មជួយពន្លឿន អន្តរកាលនៃប្រព័ន្ធឌីជីថលនៅក្នុងប្រទេសកម្ពុជាបានយ៉ាងដូចម្តេចខ្លះ?"
- បានចូលរួមកិច្ចប្រជុំថ្នាក់ជំនាញនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (APG) ដែលកិច្ចប្រជុំនេះគឺដើម្បីពិភាក្សាពីបញ្ហាពាក់ព័ន្ធនឹងគណៈកម្មាធិការអភិវឌ្ឍន៍ និងកម្មសិទ្ធិបញ្ញា លើការផ្តល់ជំនួយលើគម្រោងនានា
- បានចូលរួមកិច្ចប្រជុំពិភាក្សារចនាសម្ព័ន្ធស្តីពីការសម្របសម្រួល ការវិនិយោគសម្រាប់ការអភិវឌ្ឍ (JSI) ដោយមានការអញ្ជើញចូលរួមពីគណៈប្រតិភូក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ដើម្បីពិភាក្សា និងតាមដានអំពីវឌ្ឍនភាពនៃកិច្ចពិភាក្សាលើរចនាសម្ព័ន្ធខាងលើនេះ
- បានចូលរួមសិក្ខាសាលា "ហេដ្ឋារចនាសម្ព័ន្ធឌីជីថលជាមូលដ្ឋានគ្រឹះសម្រាប់សេដ្ឋកិច្ចឌីជីថលរួមបញ្ចូល" ដែលរៀបចំឡើងដោយសិង្ហបុរី និងមានការអញ្ជើញចូលរួមពីវាគ្មិនចំនួន៤រូប មកពីប៉ែកអាស៊ី និងអាហ្វ្រិក តំណាងឲ្យធនាគារកណ្តាលរួមមាន ប្រ៊ុយណេ កម្ពុជា ហ្កាណា និងកេនយ៉ា
- បានចូលរួមកិច្ចប្រជុំក្រៅផ្លូវការពិសេសលើកទី៤ នៃគណៈកម្មាធិការស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ

ដើម្បីតាមដាន និងស្តាប់កិច្ចពិភាក្សាបន្តលើខ្លឹមសារអត្ថបទសំណើទាំង១០ របស់ G90

- បានចូលរួមកិច្ចប្រជុំក្រៅផ្លូវការពិសេសនៃគណៈកម្មាធិការកសិកម្ម ពាក់ព័ន្ធនឹងការគាំទ្រក្នុងស្រុក។ អង្គប្រជុំបានពិភាក្សាលើបញ្ហាប្រទាក់ក្រឡារួមមាន ប្រព្រឹត្តិកម្មពិសេស(S&DT) តម្លាភាព(Transparance) គោលការណ៍សមាមាត្រ (Proportionality Principle) និងការជ្រោមជ្រែងដល់កសិករ (Per-farmer support)
- បានចូលរួមសិក្ខាសាលារបស់ក្រុមប្រទេសអភិវឌ្ឍន៍តិចតួចស្តីពីក្រុមប្រឹក្សាពាណិជ្ជកម្មផ្នែកសេវាកម្ម ដោយមានការចូលរួមពីលោកជំទាវ Dr. Ngozi OKONJO-IWEALA អគ្គនាយកWTO និងវាគ្មិនសំខាន់ៗជាច្រើនទៀត
- បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការអាស៊ានប្រចាំទីក្រុងហ្សឺណែវ ដើម្បីស្តាប់របាយការណ៍សង្ខេប ស្តីពីលទ្ធផលនៃកិច្ចប្រជុំរវាងប្រធានអគ្គក្រុមប្រឹក្សា និងប្រធានសម្របសម្រួលក្រុម ACG រួមទាំងគណៈប្រតិភូផ្សេងៗ ក៏ដូចជាពិភាក្សាពីដំណើរឆ្ពោះទៅមុខ
- បានចូលរួមសិក្ខាសាលាដែលរៀបចំដោយអង្គការWTO ទាក់ទងនឹងជំនួយសម្រាប់ពាណិជ្ជកម្ម ដើម្បីស្តាប់ការធ្វើបទបង្ហាញលើប្រធានបទនានាជុំវិញប្រធានបទ "សេដ្ឋកិច្ចរាងជារង្វង់ ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងជំនួយសម្រាប់ពាណិជ្ជកម្ម (Circular economic, economic diversification and Aid for Trade)" ពីមន្ត្រីជំនាញរបស់អង្គការ WTO និងអង្គការអន្តរជាតិពាក់ព័ន្ធនឹងសេដ្ឋកិច្ច ពាណិជ្ជកម្ម
- បានចូលរួមក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៃប្រទេសអភិវឌ្ឍន៍តិចតួច ក្នុងក្របខណ្ឌសន្និសីទ UNCTAD 15 និងបានចូលរួមអនុម័តសេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រី នៃប្រទេសអភិវឌ្ឍន៍តិចតួច
- ស្ថានបេសកកម្មបានចូលរួមយ៉ាងសកម្មនៅក្នុងក្រុម Group 77 & China ដើម្បីចរចាលើឯកសារ Bridgetown Covenant សម្រាប់ផ្តល់អាណត្តិឱ្យ UNCTAD លើការងារពាណិជ្ជកម្ម និងអភិវឌ្ឍន៍
- បានជួបប្រជុំជាមួយលោក Xuejun Jiang ប្រធានផ្នែកអាស៊ី-ប៉ាស៊ីហ្វិក នៃអង្គការITC ដើម្បីពិភាក្សាការងារមួយចំនួនរួមមាន៖ (១) ការស្ទង់មតិលើផលប៉ះពាល់បង្កដោយជំងឺកូវីដ-១៩ លើSMEs ដើម្បីកំណត់នូវអនុសាសន៍សម្រាប់ការគាំទ្រដោយរដ្ឋាភិបាលដល់SMEs ដោយការងារនេះ គឺ ITC អនុវត្តជាមួយក្រសួង MISTI (២) កម្មវិធីគាំទ្រដល់ E-Commerce របស់ ITC សហការជាមួយ Alibaba ដែលមានកម្មវិធីបណ្តុះបណ្តាលដល់SMEs ព្រមទាំងជ្រើសរើសយកSMEs មួយចំនួនតូចដើម្បីចុះឈ្មោះដាក់លក់ទំនិញនៅលើផ្សារAlibaba និង(៣) ការងារជំរុញពាណិជ្ជកម្ម ដោយITC នឹងនាំយក SMEs កម្ពុជា មួយចំនួនទៅចូលរួមពិព័រណ៍ China International Import Expo។

## ៦. កិច្ចការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ [5]

## ៦.១. ការងារពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពផលិតផលទំនិញ

- ឃ្លាំពិនិត្យទីផ្សារបានចំនួន ៥៦៩លើក ដកហូតទំនិញមិនមានភាពអនុលោមចំនួន ៣៦តោន ៤០០ គីឡូក្រាម មកកម្ទេចចោល
- ស្ទាក់ចាប់រថយន្តដឹកបង្គារស្រស់ មានចាក់បញ្ចូលសារជាតុ CMC (ចាហួយ) ចំនួន ៧តោន ១០០គីឡូក្រាម និងគ្រឿងក្នុងជ្រូកចំនួន ៣២០គីឡូក្រាម មកកម្ទេចចោល
- រកឃើញនិងដកហូតមកបំផ្លាញចោល នូវសារជាតុបាញ់លើរុក្ខជាតិធ្វើឱ្យស្រស់ និងធាប់លូតលាស់ គ្មានស្លាកសញ្ញាត្រឹមត្រូវបានចំនួន ៧៨ប៊ីដុង ស្មើនឹង ២ ៣៤០លីត្រ(ពីពាន់បីរយសែសិបលីត្រ)
- ស្រាវជ្រាវករណីពុលស្រានៅខេត្តកណ្តាល កំពត ពោធិ៍សាត់ បន្ទាយមានជ័យ និងនៅរាជធានីភ្នំពេញ ដែលបណ្តាលឱ្យប្រជាពលរដ្ឋស្លាប់បាត់បង់ជីវិត ដោយបានដកយកគំរូស្រាស ស្រាថ្នាំ និងស្រាទំពាំងបាយជូ

---

[5] ប្រភព៖ អគ្គនាយកដ្ឋាន ក.ប.ប.

មកវិភាគនៅមន្ទីរពិសោធន៍ ដើម្បីរកសារជាតុមេតាណុល

- បើកយុទ្ធនាការយកគំរូស្រាស ស្រាទំពាំងបាយជូ និងស្រាថ្នាំ នៅបណ្ដាទីតាំងផលិត និងលក់ស្រានៅទូទាំងប្រទេសមកវិភាគ ដើម្បីរកសារជាតុមេតាណុល
- ត្រួតពិនិត្យ និងវិភាគគុណភាពទំនិញចាំបាច់ដែលត្រូវយកមកដាក់លក់ និងចែកជូនប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់បិទខ្ទប់ (តំបន់ក្រហម) នៅតាមបណ្ដាឃ្លាំងស្តុក និងសិប្បកម្មនានាចំនួន ៤១លើក
- បានចូលរួមសម្របសម្រួលតាមគោលដៅដែលបានរៀបចំស្តង់លក់ផ្គត់ផ្គង់ស្បៀង និងគ្រឿងឧបភោគបរិភោគ ជូនប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បិទខ្ទប់បានចំនួន ១១ទីតាំង។

## ៦.២. ការងារពាក់ព័ន្ធនឹងកិច្ចការពារអ្នកប្រើប្រាស់ និងបង្ក្រាបការក្លែងបន្លំ

- បានចុះត្រួតពិនិត្យគុណភាពកម្រិតសន្ទស្សន៍អុកតាន (Octane) និងបរិមាណរង្វាស់រង្វាល់ប្រេងសាំង នៅតាមបណ្ដាស្ថានីយ/ដេប៉ូ លក់ប្រេងឥន្ធនៈ ដោយប្រើប្រាស់រថយន្តពិសោធន៍ចល័តផ្នែកប្រេងឥន្ធនៈ និងPump watch សរុបបានចំនួន ១ ៦៦១ ស្ថានីយ ដេប៉ូ ដោយរកឃើញស្ថានីយ ដេប៉ូចំនួន ៦៩៣ មិនមានភាពអនុលោមផ្នែកគុណភាព(សន្ទស្សន៍អុកតាន) និងបរិមាណ
- បានត្រួតពិនិត្យគុណភាពអាល់កុល និងជែលលាងដៃមានផ្ទុកសារជាតុមេតាណុល នៅតាមបណ្ដាឃ្លាំងស្តុក ទីផ្សារ និងឱសថស្ថាន រកឃើញនិងរឹបអូសមកកម្ទេចចោលសារជាតុមេតាណុលចំនួន១៩១ ៩៥៣លីត្រ យោងបណ្ដឹងរបស់ក្រុមហ៊ុន Unidry Cambodia បានចុះបង្ក្រាបនិងដកហូតបានផលិតផលខោទឹកនោមកូនក្មេងក្លែងម៉ាកចំនួន ១៧ ៤០២ខោ និងបានប្រគល់ឱ្យក្រុមហ៊ុនរក្សាទុកជាបណ្ដោះអាសន្ន
- យោងបណ្ដឹងរបស់ក្រុមហ៊ុន THAI FERMENTATION INDUSTRY CO.,LTD របស់ប្រទេសថៃដែលមានការចុះបញ្ជីនៅប្រទេសកម្ពុជា បានចុះត្រួតពិនិត្យ និងស្រាវជ្រាវលើផលិតផលប៊ីចេងសញ្ញាខ្ទះទ្រវែកក្លែងក្លាយ ដោយ ធ្វើការរឹបអូសផលិតផលបានចំនួន៥៧៨កញ្ចប់ ស្មើនឹង ២៩៤,៥គីឡូក្រាម
- យោងបណ្ដឹងរបស់ក្រុមហ៊ុន អ៊ែតវូត អាហារ័ណ នីហារ័ណ លើផលិតផលដែលបានរំលោភសិទ្ធិផ្ដាច់មុខ ដោយរឹបអូសផលិតផលស្រាបានចំនួន១១ប្រភេទ ស្មើនឹងចំនួន ១០១ដប
- យោងបណ្ដឹងរបស់ក្រុមហ៊ុន ខេមបូឌា បេវេរេជ ខមប៉ានី លីមីតធីត(Coca Cola Cambodia Beverage Company Ltd.,) លើផលិតផលដែលរំលោភសិទ្ធិផ្ដាច់មុខ ដោយរឹបអូសផលិតផលទឹកក្រូចចំនួន ៦ ប្រភេទ ស្មើនឹងចំនួន ២៨៤,២៥កេសស្មើនឹង៦ ៨២២កំប៉ុង និង៦០១,០៨ឡូ ស្មើនឹង៧ ២១៣ដប
- បានចូលរួមដោះស្រាយបណ្ដឹងរបស់ក្រុមហ៊ុនវ៉េជូ ចំកាត់ លើការផ្សាយពាណិជ្ជកម្មបំពាន និងបំភាន់លើផលិតផលការម៉ាក៥០២ របស់ម្ចាស់គណនីឈ្មោះការបិទ X2000 តាមរយៈធ្វើកិច្ចសន្យាឈប់ផ្សព្វផ្សាយបំពាន និងបំភាន់សាធារណជន
- បានចុះត្រួតពិនិត្យ និងធ្វើការណែនាំករណីផ្សព្វផ្សាយរំលោភលើសិទ្ធិសេវា ដែលប្រើប្រាស់ម៉ាកវេចខ្ចប់ដូចគ្នាទៅនឹងក្រុមហ៊ុន DHL Cambodia ដោយក្រុមហ៊ុន DHL បានអនុគ្រោះឱ្យធ្វើកិច្ចសន្យាប្រើនូវសេវារបស់ក្រុមហ៊ុនវិញ និងទុកពេលឱ្យកែសម្រួលក្រោមយន្តការឃ្លាំពិនិត្យ របស់សមត្ថកិច្ច ក.ប.ប.
- បានសហការចុះត្រួតពិនិត្យទីតាំងលើកស្លាកយីហោរថយន្ត Tesla ដោយបានណែនាំឱ្យម្ចាស់ទីតាំងបញ្ឈប់សកម្មភាពបំភាន់ និងសុំសិទ្ធិស្របច្បាប់ ស្របតាមនីតិវិធី
- បានសហការជាមួយគណៈកម្មាធិការ គ.ប.ផ.ក បានចំនួន ៦លើក ក្នុងនាមជាសមត្ថកិច្ចសហការ និងពុំបានចូលរួមអនុវត្តការត្រួតពិនិត្យឆែកឆេរ ឬកសាងកំណត់ហេតុអ្វីឡើយ
- បានកោះអញ្ជើញក្រុមហ៊ុនចំនួន១៥ ឱ្យមកបំភ្លឺ និងផ្ដល់ឯកសារពាក់ព័ន្ធនឹងការផ្សាយពាណិជ្ជកម្មលក់

ផលិតផល ដែលមានភ្ជាប់វង្វាន់តាមប្រព័ន្ធសារព័ត៌មាននានា

- បានសហការចុះបង្ក្រាបទីតាំងផលិត កែច្នៃ និងឃ្លាំងស្តុកផលិតផលក្លែងក្លាយចំនួន ១៤លើក ឃាត់ទុកផលិតផលក្លែងក្លាយចំនួន ១៣តោន និង៣១១គីឡូក្រាម។

## ៦.៣. កិច្ចការទទួល និងដោះស្រាយពាក្យបណ្តឹង

បានទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់ និងក្រុមហ៊ុនឯកជនបានចំនួន ១៨បណ្តឹង ដែលក្នុងនោះមាន ១៣បណ្តឹងកំពុងដោះស្រាយ បញ្ជូនទៅតុលាការចំនួន ៣ពាក្យបណ្តឹង និងបានបញ្ចប់ការដោះស្រាយចំនួន ២ពាក្យបណ្តឹង។

## ៦.៤. ការងារពាក់ព័ន្ធនឹងការវិភាគគុណភាពទំនិញ

- មន្ទីរពិសោធន៍របស់ក្រសួងបានវិភាគគុណភាពទំនិញបាន ២ ២៨៨គំរូ រកឃើញគំរូចំនួន ៣៧៣គំរូមិនអនុលោមនឹងបញ្ញត្តិបច្ចេកទេស
- រថយន្តពិសោធន៍ចល័តរបស់ក្រសួងមានចំនួនសរុប ៨គ្រឿង ក្នុងនោះមានរថយន្តពិសោធន៍ចល័តផ្នែកម្ហូបអាហារ ៦គ្រឿង និងរថយន្តពិសោធន៍ចល័តផ្នែកប្រេងឥន្ធនៈចំនួន ២គ្រឿង ដោយរថយន្តពិសោធន៍ផ្នែកម្ហូបអាហារចំនួន ៥គ្រឿងបានបញ្ជូនទៅកាន់សាខា ក.ប.ប. រាជធានី ខេត្ត។

## ៦.៥. ការងារកំណត់បទល្មើស និងការអនុវត្តទណ្ឌកម្ម

មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន ក.ប.ប. ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ បានរកឃើញបទល្មើសចំនួន ៦៨២ករណី ត្រូវបានអនុវត្តវិធានការពិន័យអន្តរការណ៍ទៅតាមប្រភេទ និងទំហំនៃបទល្មើសនីមួយៗ និងបទល្មើសចំនួន៧ ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅតុលាការ។

## ៦.៦. ការងារវិញ្ញាបនបត្រកម្ម ផលិតផលហាឡាល

បានទទួលពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ចំនួន ៣៩ពាក្យស្នើសុំ (ពាក្យស្នើសុំថ្មី១២ និងពាក្យស្នើសុំបន្តសុពលភាព២៧) និងចេញវិញ្ញាបនបត្របញ្ជាក់បច្ចេកទេស ស្តង់ដារផលិតផលហាឡាលកម្ពុជាចំនួន ២០វិញ្ញាបនបត្រ។

## ៦.៧. ការងារស្រាវជ្រាវសេចក្តីជូនដំណឹង ពីអនាម័យ និងភូតគាមអនាម័យ

- សិក្សាស្រាវជ្រាវ ប្រមូលផ្តុំ និងជ្រើសរើសសេចក្តីជូនដំណឹង ស្តីពីវិធានអនាម័យ និងភូតគាមអនាម័យចំនួន ៥៤៧(ផ្នែកសុវត្ថិភាពផលិតផលម្ហូបអាហារចំនួន ២៥៣ ផ្នែកកិច្ចការពារដំណាំចំនួន ១២៨ និងផ្នែកកិច្ចការពារសុខភាពសត្វចំនួន ១៦៦)
- បាន និងកំពុងសិក្សាស្រាវជ្រាវទៅលើផលិតផលម្ហូបអាហារចំនួន ៤៤មុខ នៅលើទីផ្សារសហរដ្ឋអាម៉េរិក អូស្ត្រាលី និងអឺរ៉ុបដែលអាចមានសក្តានុពលហូរចូលក្នុងដែនទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ដែលផលិតផល ទាំងនោះត្រូវបានមន្ត្រីមានសមត្ថកិច្ចនៅសហរដ្ឋអាម៉េរិក អូស្ត្រាលី និងអឺរ៉ុប ពិនិត្យឃើញមានហានិភ័យគ្រោះថ្នាក់ទៅដល់អ្នកប្រើប្រាស់ ហើយបានហៅត្រឡប់ទៅវិញ។

## ៦.៨. ការងារលើកកម្ពស់ការយល់ដឹងសាធារណៈ

- បានបិទផ្ទាំងរូបភាពផ្សព្វផ្សាយ (Posters) ពីរបៀបពិនិត្យស្លាកសញ្ញាផលិតផលម្ហូបអាហារ ដែលមានសុវត្ថិភាព នៅតាមទីផ្សារ និងទីសាធារណៈ បានចំនួន ៥២ ៤០០ សន្លឹក (ប្រាំម៉ឺនពីរពាន់បួនរយ)
- បានបិទខិត្តប័ណ្ណផ្សព្វផ្សាយ (Flyer) ពីអំពើមិនសុចរិតក្នុងធុរកិច្ចពាក់ព័ន្ធនឹងវិស័យប្រេងឥន្ធនៈ នៅតាមស្ថានីយ/ដេប៉ូលក់ប្រេងឥន្ធនៈនៅទូទាំងប្រទេសចំនួន៥ ៥៨៣ផ្ទាំង(ប្រាំបួនពាន់ប្រាំបួនរយប៉ែតសិបបីផ្ទាំង)
- បានចែកខិត្តប័ណ្ណអប់រំទាក់ទងការពុលស្រាស ស្រាថ្នាំ បានចំនួន ៥ ៣៥៣ខិត្តប័ណ្ណ(ប្រាំពាន់បីរយហាសិបបី)

- បានចែកខិត្តប័ណ្ណអប់រំអំពីផលប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ ដោយសារជាតុអាសបេស្តុសនៅទូទាំងប្រទេស បានចំនួន ២ ៧៦០សន្លឹក (ពីរពាន់ប្រាំពីររយហុកសិប)
- បានរៀបចំសន្និសីទថ្នាក់ជាតិ ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ក្រោមប្រធានបទជំរុញបរិយាកាសអ្នកប្រើប្រាស់ជាគោលដៅកម្ពុជា-វឌ្ឍនភាពនិងសមិទ្ធផលបានចំនួន ១លើក
- បានរៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការផ្សព្វផ្សាយច្បាប់ ស្តីពីកិច្ចការពារអ្នកប្រើប្រាស់បានចំនួន ១លើក។

## ៦.៩. ការងារបង្កើនសមត្ថភាពជំនាញដល់មន្ត្រី

- បានរៀបចំ និងសហការរៀបចំនូវវគ្គបណ្តុះបណ្តាលផ្សេងៗ ដើម្បីពង្រឹងសម្ថតភាពជំនាញបន្ថែមដល់មន្ត្រីបានចំនួន ៤២លើក
- បានបញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាល រៀបចំដោយដៃគូអភិវឌ្ឍន៍ និងស្ថាប័នដៃគូបានចំនួន២០លើក។

## ៦.១០. ការចូលរួមកិច្ចប្រជុំក្នុងក្របខ័ណ្ឌជាតិ តំបន់ និងអន្តរជាតិ

បានចូលរួមប្រជុំពិភាក្សា និងសិក្ខាសាលា ទាំងក្នុងក្របខ័ណ្ឌជាតិ តំបន់ និងអន្តរជាតិ បានចំនួន២១លើកដែលក្នុងនោះប្រធានបទសំខាន់ៗ ដែលត្រូវបានរៀបចំឡើងពាក់ព័ន្ធជាអាទិ៍ សុវត្ថិភាពម្ហូបអាហារ កិច្ចការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងការគ្រប់គ្រងសារជាតុអាសបេស្តុស។

# ៧. ការងារគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ [6]

## ៧.១. ការគ្រប់គ្រងរដ្ឋបាលទូទៅ

- បានចុះលេខលិខិតចូលបានចំនួន ២ ៨៥៩ច្បាប់ លិខិតចេញបានចំនួន ២ ៨៥៩ច្បាប់ លិខិតប្រកាសបានចំនួន ២៣៨ច្បាប់ បេសកកម្មបានចំនួន ៩០៦ច្បាប់ ដីកាអមបានចំនួន ៧១ច្បាប់ បញ្ជីពាណិជ្ជកម្មបានចំនួន ១ ៤៩៥ច្បាប់ និងរៀបចំលិខិតអញ្ជើញចូលរួមប្រជុំនិងសិក្ខាសាលាបានចំនួន ៣២០ច្បាប់
- បានបូកសរុប និងរៀបចំរបាយការណ៍ប្រចាំខែបានចំនួន ១១លើក ត្រីមាសបានចំនួន ១លើក ឆមាសបានចំនួន ១លើក ប្រាំបួនខែបានចំនួន ១លើក និងរបាយការណ៍សន្និបាតឆ្នាំ២០២១ និងទិសដៅឆ្នាំ២០២២
- សម្របសម្រួលកិច្ចប្រជុំអន្តរក្រសួង ២២០លើក កិច្ចប្រជុំគណៈប្រតិភូអន្តរជាតិ ១៥លើក កិច្ចប្រជុំគណៈប្រតិភូជាតិ ១៣លើក កិច្ចប្រជុំផ្ទៃក្នុង ២២លើក និងវគ្គបណ្តុះបណ្តាល ១៤លើក
- ចូលរួមកម្មវិធីបុណ្យជាតិ គោរពវិញ្ញាណក្ខន្ធ និងកិច្ចប្រជុំនានានៅក្នុង និងក្រៅក្រសួងមួយចំនួនទៀត។

## ៧.២. ការងារហិរញ្ញវត្ថុ

### ក. ស្ថានភាពចំណូល

គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២១នេះ ក្រសួងពាណិជ្ជកម្មប្រមូលចំណូលសរុបបានចំនួន **៥៣ ០១៩,៧** លានរៀល ស្មើនឹង **១២៥,៤៨%** ធៀបនឹងផែនការថវិកាឆ្នាំ២០២១ ចំនួន **៤២ ២៥៤,៥** លានរៀល។

ក្នុងនោះរួមមាន៖

- **ចំណូលកម្រៃសេវាសាធារណៈ និងការពិន័យជាប្រាក់**
  - វិញ្ញាបនបត្រប្រភពដើមទំនិញ ការចេញអាជ្ញាបណ្ណ និងសេវាពាក់ព័ន្ធ ៖ ២៦ ៨៣៦,៣ លានរៀល
  - ការចុះបញ្ជីម៉ាក និងសេវាពាក់ព័ន្ធ ៖ ៨ ៥៥០,៥ លានរៀល
  - ការចុះបញ្ជីពាណិជ្ជកម្ម និងសេវាពាក់ព័ន្ធ ៖ ១៤ ២៩២,៩ លានរៀល
  - ការតម្កល់លិខិតជូនដំណឹងមានកិច្ចធានា ៖ ៣៧១,៧ លានរៀល
  - កិច្ចការពិព័រណ៍ ៖ ២,៨ លានរៀល
  - អគ្គនាយកដ្ឋាន ក.ប.ប ៖ ១ ៨៦៨,១ លានរៀល

[6] ប្រភព៖ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

- ចំណូលកិច្ចសន្យា
  - ការជួលដីទំនេរ ៖ ៥៦៨,៦ លានរៀល
  - ការជួលដីមានអគារ ៖ ៥២៨,៨ លានរៀល

**ខ. ស្ថានភាពចំណាយ**

- គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២១នេះ ក្រសួងពាណិជ្ជកម្មចំណាយថវិកាសរុបអស់ចំនួន ៧២ ០៥១,៨លានរៀល ស្មើនឹង ៧០,០៨% ធៀបនឹងផែនការថវិកាឆ្នាំ២០២១ ចំនួន ១០២ ៨១៥,0 លានរៀល
- ការអនុវត្តឥណទានថវិកា មន្ត្រីជំនាញបានសហការជាមួយប្រតិភូអធិការកិច្ចក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យផ្ទៀងផ្ទាត់រាល់សក្ខីប័ត្រចំណូល-ចំណាយ ដើម្បីឱ្យស្របតាមកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ
- រាល់ចំណូល-ចំណាយទាំងអស់របស់ក្រសួងពាណិជ្ជកម្ម ត្រូវបានបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(NRMIS) និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) ជាប្រចាំ។

**គ.ការងារលទ្ធកម្ម**

- បានរៀបចំដំណើរការឯកសារចរចា និងប្រកាសដេញថ្លៃសម្ភារៈការិយាល័យ គ្រឿងសង្ហារឹម ប្រេងឥន្ធនៈរថយន្ត និងការជួសជុលសាងសង់នានា ដោយមានការចូលរួមពីអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពប្រឆាំងអំពើពុករលួយសរុបចំនួន ១៦គម្រោងរួមមាន៖ លទ្ធកម្មទំនិញចំនួន ១០គម្រោង លទ្ធកម្មសំណង់ចំនួន ៤គម្រោង និងលទ្ធកម្មសេវាកម្មចំនួន ២គម្រោង
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារលទ្ធកម្មប្រចាំឆ្នាំ២០២១។

## ៧.៣. ការងារបុគ្គលិក

**ក. ការងារគ្រប់គ្រងមន្ត្រី**

ក្របខ័ណ្ឌឆ្នាំ២០២១ មានចំនួន ១ ៨៨៩នាក់ ស្រី៥៣៧នាក់ ក្របខ័ណ្ឌប្រភេទ(ក) ចំនួន ១ ៦៤៣ នាក់ ក្របខ័ណ្ឌប្រភេទ(ខ) ចំនួន ១៣២នាក់ ក្របខ័ណ្ឌប្រភេទ(គ) ចំនួន ១១៤នាក់ រួមមាន៖

- **ថ្នាក់កណ្ដាល** : **១ ៤៤៧** នាក់
  - ❖ មន្ត្រីក្របខ័ណ្ឌជាក់ស្ដែង : ១ ៣០៩ នាក់
  - ❖ មន្ត្រីមិនមែនក្របខ័ណ្ឌមុខងារសាធារណៈ : ៧៩ នាក់
  - ❖ មន្ត្រីនៅក្រៅក្របខ័ណ្ឌដើម : ៧ នាក់
  - ❖ មន្ត្រីស្ថានតំណាងពាណិជ្ជកម្ម : ២៣ នាក់
  - ❖ មន្ត្រីស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស : ១០ នាក់
- **ថ្នាក់រាជធានី ខេត្ត** : **៤៤២** នាក់
  - ❖ ក្របខ័ណ្ឌជាក់ស្ដែង : ៤២៥ នាក់
  - ❖ មន្ត្រីកម្មសិក្សា : ១ នាក់
  - ❖ មន្ត្រីស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស : ០ នាក់
- **ស្ថានភាពក្របខ័ណ្ឌមន្ត្រីរាជការកើនក្នុងឆ្នាំ** : **៦៣** នាក់
  - ❖ មន្ត្រីក្របខ័ណ្ឌផ្ទេរចូល : ២២ នាក់
  - ❖ មន្ត្រីចូលបម្រើការងារវិញក្រោយទំនេរគ្មានបៀវត្ស: ៥ នាក់
  - ❖ មន្ត្រីទើបប្រឡងជាប់ក្របខ័ណ្ឌថ្មី : ៣៦ នាក់
- **ស្ថានភាពក្របខ័ណ្ឌមន្ត្រីរាជការថយក្នុងឆ្នាំ** : **៥៦** នាក់
  - ❖ ចូលនិវត្តន៍ : ១៥ នាក់
  - ❖ មន្ត្រីក្របខ័ណ្ឌផ្ទេរចេញ : ១៤ នាក់
  - ❖ លុបដោយសាមីខ្លួនសុំលាឈប់ : ១ នាក់

- ❖ លុបដោយមន្ត្រីបោះបង់ក្របខ័ណ្ឌ : ០ នាក់
- ❖ លុបដោយមន្ត្រីទទួលមរណភាព : ៣ នាក់
- ❖ មន្ត្រីធ្វើសមាហរណកម្មចូលរដ្ឋបាលថ្នាក់ក្រោមជាតិ : ២៣ នាក់

## ខ. ការងារចាត់តាំងមន្ត្រី

តែងតាំង និងសម្រួលភារកិច្ចមន្ត្រីរាជការដោយព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសសរុបចំនួន ៧១២ នាក់ (ស្រី១៦៨នាក់) ក្នុងនោះមានៈ

– **ថ្នាក់ជាតិចំនួន ៧០១នាក់(ស្រី ១៦៤នាក់)**

- ❖ អនុរដ្ឋលេខាធិការចំនួន ១នាក់ (ស្រី ១នាក់)
- ❖ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក ក.ប.ប. មានឋានៈស្មើអនុរដ្ឋលេខាធិការ ចំនួន ១នាក់
- ❖ ទីប្រឹក្សាក្រសួងពាណិជ្ជកម្មមានឋានៈស្មើអនុរដ្ឋលេខាធិការចំនួន ២នាក់ (ស្រី ១នាក់)
- ❖ ទីប្រឹក្សាក្រសួងពាណិជ្ជកម្មមានឋានៈស្មើអគ្គនាយកចំនួន ៥នាក់ (ស្រី ១នាក់)
- ❖ ទីប្រឹក្សាក្រសួងពាណិជ្ជកម្មមានឋានៈស្មើអគ្គនាយករងចំនួន ៣នាក់
- ❖ ទីប្រឹក្សាក្រសួងពាណិជ្ជកម្មមានឋានៈស្មើប្រធាននាយកដ្ឋានចំនួន ២នាក់
- ❖ អគ្គនាយកចំនួន ១នាក់
- ❖ អគ្គនាយករងចំនួន ៥នាក់
- ❖ អគ្គាធិការរងចំនួន ១នាក់
- ❖ ប្រធានាយកដ្ឋានចំនួន ៦នាក់
- ❖ ប្រធានវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវចំនួន ១នាក់
- ❖ ប្រធានតំណាងប្រចាំនៅរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ស៊ីន បារិត ចំនួន ១នាក់
- ❖ ប្រធានតំណាងប្រចាំនៅរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ឈីលូ ដាន ពុ ចាយ ចំនួន ១នាក់
- ❖ ប្រធានស្តីទីនាយកដ្ឋានចំនួន ១នាក់
- ❖ អនុប្រធាននាយកដ្ឋានចំនួន ២៣នាក់ (ស្រី ២នាក់)
- ❖ អនុប្រធានវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវចំនួន ១នាក់
- ❖ ជំនួយការក្រសួងពាណិជ្ជកម្ម មានឋានៈស្មើអនុប្រធាននាយកដ្ឋានចំនួន ២នាក់ (ស្រី ១នាក់)
- ❖ ប្រធានសាខាចំនួន ១៩នាក់
- ❖ ប្រធានស្តីទីសាខាចំនួន ១នាក់
- ❖ អនុប្រធានសាខាចំនួន ៦៨នាក់ (ស្រី ៧នាក់)
- ❖ ប្រធានការិយាល័យចំនួន ១៥៣នាក់ (ស្រី ២៥នាក់)
- ❖ អនុប្រធានការិយាល័យចំនួន ៣៣៥នាក់ (ស្រី ១១២នាក់)
- ❖ មន្ត្រីចំនួន ៦៤នាក់ (ស្រី ១៤នាក់)

– **តំណាងក្រសួងពាណិជ្ជកម្មអមស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជានៅបរទេសចំនួន ៥នាក់**

- ❖ ប្រធានស្ថានបេសកកម្មអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជាប្រចាំអង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិ ពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ឋានៈជាអគ្គរាជទូត ចំនួន ១នាក់
- ❖ ទីប្រឹក្សានៃស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការពាណិជ្ជកម្មពិភពលោក និងអង្គការ អន្តរជាតិពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម នៅទីក្រុងហ្សឺណែវ ប្រទេសស្វីសចំនួន ១នាក់
- ❖ អនុព័ន្ធអមស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការពាណិជ្ជកម្ម ពិភពលោក និងអង្គការអន្តរជាតិពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ចំនួន១នាក់

❖ អនុព័ន្ធពាណិជ្ជកម្មអមស្ថានឯកអគ្គរាជទូត ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសប៊ែលហ្ស៊ិកចំនួន១នាក់
❖ សំណើសុំការអនុញ្ញាតពន្យាអាណត្តិបំពេញបេសកកម្មឱ្យអនុព័ន្ធពាណិជ្ជកម្ម ចំនួន១នាក់

– **ថ្នាក់ក្រោមជាតិចំនួន ១១នាក់(ស្រី ៤នាក់)**

❖ ប្រធានមន្ទីរចំនួន ២នាក់
❖ អនុប្រធានមន្ទីរចំនួន ៣នាក់
❖ ប្រធានការិយាល័យចំនួន ២នាក់ (ស្រី ១នាក់)
❖ អនុប្រធានការិយាល័យចំនួន ៤នាក់ (ស្រី ៣នាក់)

– **ផ្ទេរក្របខ័ណ្ឌចូលចំនួន ៥នាក់ (ស្រី ១នាក់)**
– **ផ្ទេរក្របខ័ណ្ឌចេញចំនួន ៦នាក់ (ស្រី២នាក់)**

## ៧.៤. ការខារបណ្តុះបណ្តាល ស្រាវជ្រាវ និងភាពជាដៃគូ

### ក. ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្ស

– **បណ្តុះបណ្តាលក្នុងប្រទេស:** បានចាត់បញ្ជូនមន្ត្រីឱ្យចូលរួមបណ្តុះបណ្តាលវគ្គខ្លី និងសិក្ខាសាលា ចំនួន ៩៤នាក់ ស្រី៣៥នាក់៖

❖ ចូលរួមបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីរាជការចំនួន ១វគ្គ នៅមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ
❖ បានទទួលលិខិតចាត់បញ្ជូនមន្ត្រីរាជការក្របខ័ណ្ឌថ្មីឆ្នាំ២០១៨ វគ្គទី៦ ដែលបានបញ្ចប់វគ្គបណ្តុះបណ្តាល ដំបូងដោយជោគជ័យនៅសាលាភូមិន្ទរដ្ឋបាល មកអង្គភាព-ស្ថាប័នវិញ ដែលក្នុងនោះមានមន្ត្រីរបស់ក្រសួងពាណិជ្ជកម្មចំនួន ៦នាក់ (ស្រី ៥នាក់)
❖ បានទទួលលិខិតកំណត់កាលបរិច្ឆេទចាប់ផ្តើមបើកការបណ្តុះបណ្តាលមន្ត្រីរាជការក្របខណ្ឌថ្មី ឆ្នាំ ២០១៩ វគ្គទី១ បន្ត ក្នុងនោះមានមន្ត្រីរបស់ក្រសួងពាណិជ្ជកម្មចំនួន ២នាក់
❖ បានចាត់បញ្ជូនមន្ត្រីចំនួន ៤នាក់ (ស្រី ៣នាក់) ចូលរួមវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ (Online) ជំនាញភាសាអង់គ្លេស និងទំនាក់ទំនងកម្រិតមធ្យម (Intermediate English Language and Communication Skill) ចាប់ពីថ្ងៃទី១៧ ខែឧសភា ដល់ថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០២១ នៅមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា សឹង្ហបុរី រាជធានីភ្នំពេញ
❖ បានសម្របសម្រួលចុះឈ្មោះមន្ត្រីចំនួន២នាក់ (ស្រី ២នាក់) ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លីតាមប្រព័ន្ធអនឡាញ ដែលរៀបចំដោយ សាធារណរដ្ឋប្រជាមានិតចិនសម្រាប់ឆ្នាំ២០២១
❖ បានចាត់បញ្ជូនថ្នាក់ដឹកនាំ ចំនួន ៤នាក់ (ស្រី ១នាក់) ចូលរួមសិក្ខាសាលា ស្តីពី 'ការរៀបចំផែនការសម្រាប់ទីក្រុងវៃឆ្លាត (Virtual Conference on Smart City Planning) ដែលរៀបចំដោយក្រសួងមុខងារសាធារណៈ
❖ បានចាត់បញ្ជូនមន្ត្រីចំនួន ២នាក់ ចូលរួមកម្មវិធីបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញរបស់វិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ច JETRO (Institute of Developing Economics- JETRO) នៃប្រទេសជប៉ុន ដែលចាប់ផ្តើមពីថ្ងៃទី ១ ខែកញ្ញា ឆ្នាំ២០២១ ដល់ថ្ងៃទី២១ ខែមករា ឆ្នាំ២០២២
❖ ចាត់បញ្ជូនមន្ត្រីចំនួន៤នាក់ (ស្រី ២នាក់) ចូលរួមវគ្គបណ្តុះបណ្តាលដំបូង មន្ត្រីគ្រប់គ្រងរដ្ឋបាលក្របខ័ណ្ឌថ្មីឆ្នាំ២០១៩ វគ្គទី២ និងវគ្គទី៣ រៀបចំដោយសាលាភូមិន្ទរដ្ឋបាល តាមប្រព័ន្ធ Online
❖ បានចាត់បញ្ជូនមន្ត្រីចំនួន ២នាក់ (ស្រី ១នាក់) ចូលរួមវគ្គបណ្តុះបណ្តាល មជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា រៀបចំដោយវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី ៥-៦ ខែសីហា ឆ្នាំ២០២១ តាមប្រព័ន្ធ Online

- ❖ បានចាត់បញ្ជូនមន្ត្រីចំនួន ២នាក់(ស្រី ២នាក់) ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ជំនាញការទូត និងទំនាក់ទំនងអន្តរជាតិ រៀបចំដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ ដែលប្រព្រឹត្តទៅនៅចាប់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ (រយៈពេល ៣សប្តាហ៍) តាមប្រព័ន្ធ Online
- ❖ បានចាត់បញ្ជូនមន្ត្រីចំនួន ២នាក់ ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីយុទ្ធសាស្ត្រភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចសាធារណៈ ចាប់ពីទី២៧ ខែកញ្ញា ដល់ថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ តាមប្រព័ន្ធ Online
- ❖ បានចាត់បញ្ជូនមន្ត្រីចំនួន ៥នាក់ (ស្រី ១នាក់) ចូលរួមក្នុងសិក្ខាសាលា ស្តីពី " The Geopolitics of Cyberspace" ដែលប្រព្រឹត្តទៅនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូ រៀបចំដោយវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ
- ❖ បានទទួលសិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១១ ចំនួន ១១នាក់ (ស្រី ៥នាក់) ចុះកម្មសិក្សានៅក្រសួងពាណិជ្ជកម្ម ចាប់ពីថ្ងៃទី ២៥ ខែសីហា ដល់ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២១
- ❖ បានចាត់បញ្ជូនមន្ត្រី៥នាក់ (ស្រី ២នាក់) ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "សហគ្រិនភាព និងការបើកអាជីវកម្មថ្មី" ចាប់ពីថ្ងៃទី២០-២៦ ខែតុលា ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ របស់ប្រទេសសឹង្ហបុរី
- ❖ ចាត់បញ្ជូនមន្ត្រីចំនួន៤នាក់ (ស្រី២នាក់) ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី "Trade Expert Training Program for ASEAN Countries" ដែលប្រព្រឹត្តទៅនៅថ្ងៃទី១៩-២៥ ខែតុលា ឆ្នាំ ២០២១ តាមប្រព័ន្ធអនឡាញ ដែលរៀបចំដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)
- ❖ បានបញ្ជូនមន្ត្រីជាន់ខ្ពស់ចំនួន៥នាក់ ចូលរួមវគ្គបណ្តុះបណ្តាលអនឡាញ ស្តីពី"ភាពជាអ្នកដឹកនាំ និងនវានុវត្តន៍" ជំនាន់ទី២ "Workshop on Leadership and Innovation Program" ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ រៀបចំដោយក្រសួងមុខងារសាធារណៈ
- ❖ បានចាត់បញ្ជូនមន្ត្រី ២នាក់ (ស្រី ១នាក់) ចូលរួមវគ្គបណ្តុះបណ្តាលជំនាញភាសាអង់គ្លេស និងទំនាក់ទំនងកម្រិតខ្ពស់ ពីថ្ងៃទី២២ វិច្ឆិកា ដល់១០ ធ្នូ ឆ្នាំ២០២១ តាមអនឡាញ របស់ប្រទេសសឹង្ហបុរី
- ❖ បានចាត់បញ្ជូនមន្ត្រី ២០នាក់ (ស្រី ៩នាក់) ចូលរួមសិក្ខាសាលាតាមប្រព័ន្ធអនឡាញស្តីពី "Trade Facilitation and Improvement on Investment and Trade Environment Cambodia" ពីថ្ងៃទី២៩ វិច្ឆិកា ដល់ទី១០ ធ្នូ ឆ្នាំ២០២១ រៀបចំដោយស្ថានទូតចិនប្រចាំប្រទេសកម្ពុជា
- ❖ បានចាត់បញ្ជូនមន្ត្រី២៣នាក់(ស្រី ៤នាក់) ចូលរួមសិក្ខាសាលាតាមអនឡាញស្តីពី "E-Commerce and Cross-Border E-Commerce Development Cooperation" ពីថ្ងៃទី៧-១៧ ខែធ្នូ ឆ្នាំ ២០២១ រៀបចំដោយស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំប្រទេសកម្ពុជា

– **បណ្តុះបណ្តាលក្រៅប្រទេស**: បានចាត់បញ្ជូនមន្ត្រីរាជការសរុបចំនួន ៩នាក់(ស្រី ២នាក់) ឱ្យចូលរួមវគ្គបណ្តុះបណ្តាល និងដាក់ពាក្យចូលរួមអាហារូបករណ៍ នៅក្រៅប្រទេសដូចខាងក្រោម៖

- ❖ បានផ្សព្វផ្សាយសេចក្តីជូនដំណឹងអាហារូបករណ៍ របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) សម្រាប់ឆ្នាំសិក្សា ២០២១
- ❖ បានផ្សព្វផ្សាយសេចក្តីជូនដំណឹងរបស់ស្ថានទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា ស្តីពីការបើកឱ្យដាក់ពាក្យអាហារូបករណ៍ Australia Awards Scholarship intake 2022 សម្រាប់ឆ្នាំ២០២២
- ❖ បានផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលក្រោមកម្មវិធី Indian Technical and Economic Cooperation (ITEC) របស់រដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌា សម្រាប់ឆ្នាំសិក្សា ២០២០-២០២១ តាមប្រព័ន្ធអនឡាញ

- ❖ បានផ្សព្វផ្សាយកម្មវិធីបណ្តុះបណ្តាលរបស់សាធារណរដ្ឋប្រជាមានិតចិន សិក្សាតាមប្រព័ន្ធអនឡាញ ចំនួន ១៣វគ្គ សម្រាប់ឆ្នាំ២០២១
- ❖ បានចាត់មន្ត្រីរាជការចំនួន ៣នាក់ ស្រី៣នាក់ ចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លី សរុបចំនួន ១៦វគ្គ តាមប្រព័ន្ធអនឡាញ (Online) របស់សាធារណរដ្ឋប្រជាមានិតចិន
- ❖ បានផ្សព្វផ្សាយ និងចាត់បញ្ជូនមន្ត្រីរាជការចំនួន ៥នាក់ ស្រី ២នាក់ ដាក់ពាក្យចូលរួមប្រកួតប្រជែងអាហារូបករណ៍ថ្នាក់អនុបណ្ឌិត សម្រាប់ឆ្នាំសិក្សា២០២១ ក្រោមការឧបត្ថម្ភរបស់ក្រសួងពាណិជ្ជកម្មរបស់សាធារណរដ្ឋប្រជាមានិតចិន(MOFCOM)
- ❖ បានផ្សព្វផ្សាយកម្មវិធីអាហារូបករណ៍ របស់ចក្រភពអង់គ្លេសថ្នាក់អនុបណ្ឌិត Chevening Scholarships Programme សម្រាប់ឆ្នាំសិក្សា ២០២២-២០២៣
- ❖ បានផ្សព្វផ្សាយ អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ក្រោមគម្រោងកម្មវិធីអាហារូបករណ៍របស់ប្រទេសជប៉ុនសម្រាប់ការអភិវឌ្ឍធនធានមនុស្សនៅប្រទេសកម្ពុជាក្នុងឆ្នាំ២០២១
- ❖ បានផ្សព្វផ្សាយអាហាររូបករណ៍កម្មវិធី "Young Leader's Program" របស់រាជរដ្ឋាភិបាលនៃប្រទេសជប៉ុន លើមុខជំនាញច្បាប់ (Law) សម្រាប់ឆ្នាំសិក្សា ២០២២
- ❖ បានចាត់បញ្ជូនមន្ត្រីចំនួន១នាក់ (ស្រី១នាក់) ចូលរួមដាក់ពាក្យប្រកួតប្រជែងអាហារូបរណ៍រយៈពេលវែង របស់ JICA សម្រាប់ឆ្នាំសិក្សា ២០២២ ថ្នាក់អនុបណ្ឌិត លើមុខជំនាញ Investment Promotion and Industrial Development for ASIA Region។

– **វគ្គបណ្តុះបណ្តាលរៀបចំដោយវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ ចំនួន ១៦វគ្គ៖**

- ❖ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "អ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំឯកសារនាំចេញ នាំចូល" ជំនាន់ទី១៤ ចាប់ពីថ្ងៃទី១៨ មករា ដល់ទី៤ កុម្ភៈ ឆ្នាំ២០២១ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ដែលមានសិក្ខាកាមចូលរួមមកពីតំណាងក្រុមហ៊ុន រោងចក្រ និងសហគ្រាស សរុបចំនួន៣៨នាក់ ស្រី១០នាក់
- ❖ សហការការជាមួយសមាគមភស្តុភារកម្មកម្ពុជា រៀបចំវគ្គបណ្តុះបណ្តាល ស្តីពី "មូលដ្ឋានគ្រឹះនៃភស្តុភារកម្ម និងការគ្រប់គ្រងប្រវាក់ផ្គត់ផ្គង់" ដែលប្រព្រឹត្តិទៅចាប់ពីថ្ងៃទី១៣-១៤ ខែកក្កដា ឆ្នាំ២០២១
- ❖ សហការជាមួយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម(ម.ជ.គ) រៀបចំវគ្គបណ្តុះបណ្តាល ស្តីពី "មជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា" ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី៥-៦ ខែសីហា ឆ្នាំ២០២១
- ❖ បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពី "ការគ្រប់គ្រងគម្រោង" ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៦-២៧ ខែសីហា ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូ Zoom
- ❖ បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពី "លក្ខខណ្ឌស្តង់ដារពាណិជ្ជកម្ម និងការគ្រប់គ្រងហានិភ័យ" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី២៩-៣០ ខែកញ្ញា ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូ Zoom
- ❖ រៀបចំវិញ្ញាបនបត្របញ្ចប់ការសិក្សា ស្តីពីអ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំឯកសារនាំចេញ នាំចូល ជំនាន់ទី១៤ ចំនួន ២៧នាក់ (ស្រី ៩នាក់)។

## ខ. ការស្រាវជ្រាវ និងអភិវឌ្ឍន៍

– បានសរសេរអត្ថបទស្រាវជ្រាវ (Factsheet) ទាក់ទងនឹងរបាំងពន្ធគយ និងរបាំងមិនមែនពន្ធគយ លើមុខទំនិញសក្តានុពលសម្រាប់ការនាំចេញ ទៅកាន់ប្រទេសចិន ទាក់ទងនឹងវិស័យកសិកម្ម ជូនដល់លេខាធិការដ្ឋាន នៃក្រុមការងាររៀបចំយុទ្ធសាស្ត្រ ដើម្បីទាញយកផលប្រយោជន៍អតិបរមាពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ចំនួន ២៥មុខ ដូចជា៖

- គោពូជសុទ្ធ(សាច់គោ ស្បែកគោ) ក្របីពូជសុទ្ធ ពពែពូជសុទ្ធ ចៀម កង្កែប បង្គារ បង្កង អន្ទង់ ត្រីរស់ មាន់
- កៅស៊ូធម្មជាតិ ស្វាយស្រស់ ស្រការនាគ ធុរេន ចេកស្រស់ ដំណាប់ស្វាយ ដំណាប់ចេក គ្រាប់ល្ហុង សណ្តែក តែម្រុំ ផ្កាចំប៉ីក្រៀម
- ក្រចៅ គ្រឿងកំប៉ុង ឈើកែច្នៃ ចំណីសត្វ

- បានធ្វើការស្រាវជ្រាវលើបន្ទាត់ពន្ធគយ (Matrix) នៃទំនិញសក្តានុពលសម្រាប់ការនាំចេញដែលបានកំណត់ដោយប្រទេសកម្ពុជា ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ទ្វេភាគី និងពហុភាគី ASEAN - New Zealand, Australia, ASEAN - Japan និង ASEAN - India ជូនដល់លេខាធិការដ្ឋានក្រុមការងាររៀបចំយុទ្ធសាស្ត្រ អនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី
- រៀបចំអត្ថបទស្រាវជ្រាវសង្ខេបពីពាណិជ្ជកម្មស្វាយចន្ទី និងជំនួយពាណិជ្ជកម្ម(Aid for Trade)
- បានរៀបចំអត្ថបទស្រាវជ្រាវ ស្តីពី "Promote Comparative Advantage in crop sectors, Promote Niche: Organic and GI products"
- រៀបចំនិងរចនាគេហទំព័រការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកឡើងវិញ(https://elearning.ttri.info/)
- បានពិនិត្យ និងផ្តល់ធាតុចូលលើសេចក្តីព្រាងរបាយការណ៍ចុងក្រោយ ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិ ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ ២០១៧-២០២៥ សម្រាប់ឆ្នាំ ២០១៨-២០១៩ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**គ. ការអភិវឌ្ឍភាពជាដៃគូ**

- រៀបចំកិច្ចប្រជុំពិភាក្សាការងារជាមួយ ក្រុមការងារនៃមជ្ឈមណ្ឌលជំរុញការនាំចូលពីប្រទេសកំពុងអភិវឌ្ឍន៍របស់ប្រទេសហូឡង់ The Center for the Promotion of Imports from Developing Countries of the Netherlands (CBI) សហគ្រិនខ្មែរ) KE) និងទីប្រឹក្សាឯករាជ្យ ស្តីពី"ការជំរុញការនាំចេញទៅកាន់សហភាពអឺរ៉ុប) EU)" "ការបណ្តុះបណ្តាលសហគ្រិនភាព និងការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម) SMEs)" និង "ការរៀបចំផែនការយុទ្ធសាស្ត្ររវាង TTRI និង CBI" តាមរយៈប្រព័ន្ធអនឡាញ
- បានសហការជាមួយ GIZ ក្រោមគម្រោង ARISE Plus Cambodia រៀបចំលិខិតអញ្ជើញមន្ត្រី និងមន្ត្រីជំនាញជាន់ខ្ពស់នៅក្រសួងពាណិជ្ជកម្ម និងអន្តរក្រសួងដើម្បីចូលរួម សិក្ខាសាលាកសាងសមត្ថភាពជាសេរី ស្តីពី "ការចរចាពាណិជ្ជកម្ម" ចំនួន ៤ដងតាមរយៈប្រព័ន្ធអនឡាញ
- បានជំនួបពិភាក្សាការងារជាមួយ សហគ្រិនខ្មែរ (KE) លើការបណ្តុះបណ្តាលសហគ្រិនភាព និងការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម (SMEs) តាមរយៈប្រព័ន្ធអនឡាញ
- បានរៀបចំផ្សព្វផ្សាយពីអាហារូបករណ៍ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត របស់រដ្ឋាភិបាលអូស្ត្រាលីក្រោមគម្រោង "Australia Awards Scholarship" និងអាហារូបករណ៍ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ របស់សាធារណរដ្ឋកូរ៉េ ក្រោមគម្រោង "Korea International Cooperation Agency" ជូនដល់មន្ត្រីរាជការនៃក្រសួងពាណិជ្ជកម្ម
- បានរៀបចំផ្សព្វផ្សាយពីវគ្គបណ្តុះបណ្តាលចំនួន ៤វគ្គ ស្តីពី ១.ការប្រមូលទិន្នន័យអាជីវកម្ម និងការវិភាគសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ២.កិច្ចសហប្រតិបត្តិការសម្របសម្រួលពាណិជ្ជកម្ម សម្រាប់ប្រទេសផ្លូវមួយខ្សែក្រវ៉ាត់មួយ ៣.កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម វិនិយោគ និងឧស្សាហកម្មសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ និង៤ ខ្សែច្រវ៉ាក់ពាណិជ្ជកម្មកសិកម្ម ក្រោមគម្រោងសាធារណរដ្ឋប្រជាមានិតចិន តាមប្រព័ន្ធអនឡាញ ជូនមន្ត្រីរាជការនៃក្រសួងពាណិជ្ជកម្ម
- បានរៀបចំផ្សព្វផ្សាយវគ្គបណ្តុះបណ្តាល ស្តីពី "Specialized Training Programme for Asian Countries

On Select Issues for Forthcoming WTO Ministerial Conference" ក្រោមគម្រោង "India Technical and Economic Coorperation (ITEC)" តាមប្រព័ន្ធអនឡាញ

- បានរៀបចំផ្សព្វផ្សាយពីវគ្គបណ្តុះបណ្តាលស្តីពី "សហប្រតិបត្តិការបច្ចេកទេស និងសេដ្ឋកិច្ចឥណ្ឌា" ក្រោមគម្រោង "Prestigious India Institutes" តាមប្រព័ន្ធអនឡាញ។

## ៨. ក្រុមហ៊ុនហ្គ្រីនត្រេដ[7]

ជាក្រុមហ៊ុនក្រោមអាណាព្យាបាលបច្ចេកទេសក្រសួងពាណិជ្ជកម្ម ដែលមានតួនាទី និងសកម្មភាពក្នុងការអនុវត្តការងារ អាជីវកម្ម ផលិតផលស្បៀង និងម្ហូបអាហារក្នុងគោលដៅរក្សាស្ថេរភាពទីផ្សារ រួមចំណែកក្នុងការនាំចេញ/នាំចូល ស្បៀង និងគ្រប់គ្រងសន្និធិស្បៀងត្រៀមបម្រុង ជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។ លទ្ធផលការងារមានដូចតទៅ៖

### ក. លទ្ធផលការងារសម្រេចបាន ១០ខែ ក្នុងឆ្នាំ ២០២១

- សរុបចំណូលចំនួន = ៧ ៨៨១ ២៤០៧៧៣៛
- សរុបចំណាយចំនួន = ៥ ៣១៣ ៨៦០ ៥១៧៛
- សរុបចំណេញពិតចំនួន = ២ ៥៦៧ ៣៨០ ២៥៦៛

### ខ. ផែនការហិរញ្ញកិច្ចប៉ាន់ស្មានឆ្នាំ២០២២

- ផលចំណូល = ១៦ ៥១៧ ៣៧៤ ០០០៛
- បន្ទុកចំណាយ = ១៤ ៦៨២ ៧៧១ ០០០៛
- លទ្ធផលបង់មុន = ១ ៥១៧ ៣៧៤ ០០០៛
- ពន្ធលើប្រាក់ចំណាយ = ៣៦៦ ៩២០ ៦០០៛
- លទ្ធផលចំណេញពិត = ១ ៤៦៧ ៦៨២ ៤០០៛

### គ. ការងារអាជីវកម្ម និងវិនិយោគ ឆ្នាំ ២០២១

- **លទ្ធផលប្រមូលទិញ**
  - ❖ លើមុខទំនិញអង្ករ ៖
    - ទិញចូលរយៈពេល ១១ខែ ២០២១ = ៣ ៤៦៣តោន
    - ប៉ាន់ស្មានទិញចូល ខែធ្នូ ២០២១ = ១ ៨០០តោន

    **សរុបអនុវត្តឆ្នាំ ២០២១ = ៥ ២៦៣តោន**
- **លទ្ធផលលក់ចេញ**
  - ❖ លើមុខទំនិញអង្ករ ៖
    - លក់ចេញរយៈពេល១១ខែ ២០២១ = ៣ ៤៦០,១៤០តោន
    - ប៉ាន់ស្មានលក់ចេញ ខែធ្នូ ២០២១ = ១ ៨០០តោន

    **សរុបអនុវត្តឆ្នាំ ២០២១ = ៥ ២៦០,១៤០តោន**

### ឃ. ការងារគ្រប់គ្រងសន្និធិស្បៀងបម្រុងរាជរដ្ឋាភិបាល(អង្ករ)

- ស្ថានភាពស្តុកត្រៀមរបស់រាជរដ្ឋាភិបាលឆ្នាំ ២០២១ រួមមាន ៖
  - ស្តុកដើមគ្រាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ = **១៦ ៨២៥,៨៣៣តោន**
  - បញ្ចូលស្តុកក្នុងគ្រាឆ្នាំ២០២១ = ១ ១៦១,៤០០តោន
  - បញ្ចេញស្តុកប្រើប្រាស់ក្នុងគ្រាឆ្នាំ២០២១ = ៥ ២៥៥,៦០៦តោន
  - ស្តុកចុងគ្រាឆ្នាំ២០២១ = **១២ ៧៣១,៦២៧តោន**

[7] ប្រភព៖ ក្រុមហ៊ុន ហ្គ្រីនត្រេដ

(ក្នុងនោះមានអង្ករ IR35% =៦ ០៦៥,២៧៤តោន, អង្ករ ៥៤៥១ = ៦ ៦៦៦,៣៩៣តោន)

- ស្ថានភាពបច្ចុប្បន្នបរិមាណស្តុកត្រៀមបម្រុងអប្បបរមា សម្រាប់ត្រៀមជួយអន្តរាគមន៍ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩

| | | |
|---|---|---|
| - អង្ករ | ចំនួន | = ៤ ៩៩៤ តោន |
| - ទឹកសុទ្ធអរុណា | ចំនួន | = ៥០ ០០០ កេស |
| - ទឹកសុទ្ធវីតាល់ | ចំនួន | = ៥០ ០០០ កេស |
| - មីជាតិ | ចំនួន | = ២០ ០០០ កេស |
| - ទឹកត្រី | ចំនួន | =១៥០ ០០០ ដប |
| - ទឹកស៊ីអ៊ីវ | ចំនួន | =១៥០ ០០០ ដប |

### ខ. ការងារផ្សេងៗ

- សាងសង់របងការពារដី-ឃ្លាំងព្រះនេត្រព្រះប្រវែង ២៦០ម៉ែត្រ ស្ថិតនៅស្រុកព្រះនេត្រព្រះខេត្តបន្ទាយមានជ័យ
- សហការជាមួយអន្តរក្រសួងចុះធ្វើការដោះស្រាយបញ្ហាដីធ្លីរបស់ក្រុមហ៊ុន ដែលមានវិវាទជាមួយប្រជាពលរដ្ឋនៅខេត្តព្រះសីហនុបានចប់រួចរាល់ជាស្ថាពរ និងកំពុងបន្តដោះស្រាយបញ្ចប់ករណីដីធ្លីជាមួយប្រជាពលរដ្ឋដែលបានតាំងទីលំនៅ និងរស់នៅលើដី-ឃ្លាំងរបស់ក្រុមហ៊ុនស្ថិតនៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
- បញ្ចប់ការងារធ្វើប្លង់សម្គាល់សិទ្ធិកាន់កាប់ដី-ឃ្លាំងនៅស្រុកថ្មគោល ជាមួយមន្ទីររៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ខេត្តបាត់ដំបង
- ចូលរួមកិច្ចប្រជុំអន្តរក្រសួង ពាក់ព័ន្ធការត្រៀមរៀបចំកិច្ចប្រជុំលើកទី២ នៃក្រុមកាងារជាន់ខ្ពស់កម្ពុជា-រុស្ស៊ីដើម្បីជំរុញគម្រោងវិនិយោគអាទិភាពរួមកម្ពុជា-រុស្ស៊ី នៅទីស្តីការក្រសួងពាណិជ្ជកម្ម
- ចូលរួមកិច្ចប្រជុំ Kick off ស្តីពីផលប៉ះពាល់ដោយសារទឹកជំនន់ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមសិក្សារៀបចំគម្រោងជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករក្នុងក្របខណ្ឌឥណទានសម្បទានសហប្រតិបត្តិការពីសាធារណរដ្ឋប្រជាមានិតចិន ដែលដឹកនាំការងារគម្រោងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានបញ្ចេញស្តុកសន្និធិស្បៀងត្រៀមបម្រុងរបស់រាជរដ្ឋាភិបាលចែកជូនប្រជាពលរដ្ឋ ក្នុងអំឡុងពេលធ្វើចត្តាឡីស័ករបស់ពលករ និងប្រជាពលរដ្ឋដែលរងគ្រោះដោយសារទឹកជំនន់នៅតាមបណ្តាខេត្តជាប់ព្រំដែនថៃ
- ចូលរួមប្រជុំ ស្តីពីកម្មវិធីរៀបចំបែងចែកជំនួយសង្គមជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមប្រព័ន្ធវីដេអូ
- ចុះធ្វើការប្រគល់ - ទទួល ដីឃ្លាំងអក្សរ"ក" ជាមួយមន្ទីរពាណិជ្ជកម្មខេត្តតាកែវ
- ចូលរួមពិធីប្រគល់-ទទួល មី ម៉ាស់ និងផ្លែមៀន ជូនកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិដែលឈរជើងនៅតាមខ្សែបន្ទាត់ព្រំដែន នៅពេងចក្រ ម៉ែន សារុន។

## ៩. ការងារយេនឌ័រ [8]

### ក. ការរៀបចំសិក្ខាសាលា និងកិច្ចប្រជុំផ្សេងៗ

ក្នុងឆ្នាំ២០២១ ក្រុមការងារយេនឌ័រក្រសួងពាណិជ្ជកម្ម បានរៀបចំសិក្ខាសាលាចំនួន ២លើក រៀបចំកិច្ចប្រជុំផ្ទៃក្នុងចំនួន ២លើក ចូលរួមកិច្ចប្រជុំនានាពាក់ព័ន្ធការងារយេនឌ័រចំនួន ៣លើក ផ្តល់កិច្ចសម្ភាសន៍ចំនួន ២លើក និងចូលរួមវគ្គបណ្តុះបណ្តាលចំនួន ១លើក ដែលសម្រេចបានលទ្ធផលការងារមានដូចខាងក្រោម៖

- បានរៀបចំសិក្ខាសាលាស្តីពី"សុខភាពផ្លូវចិត្ត និងបញ្ហាប្រឈមរបស់ស្ត្រីក្នុងបរិបទកូវីដ-១៩"ក្នុងគោលបំណង ដើម្បីពង្រឹងដល់ស្មារតីស្ត្រី នៃក្រសួងពាណិជ្ជកម្ម ដែលកំពុងមានបញ្ហាប្រឈមមួយចំនួន ក្នុងអំឡុងពេល នៃការរីករាលដាលនៃជំងឺកូវីដ-១៩ ប្រព្រឹត្តទៅនាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ ក្រោមអធិបតីភាព **លោកជំទាវ ចម និម្មល រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម** ដែលមានសមាសភាពចូលរួមពី

[8] ប្រភព៖ ក្រុមការងារយេនឌ័រក្រសួងពាណិជ្ជកម្ម

អនុរដ្ឋលេខាធិការ អគ្គាធិការ ថ្នាក់ដឹកនាំ សមាជិកក្រុមការងារយេនឌ័រ ព្រមទាំងមន្ត្រីជាស្ត្រីផ្សេងទៀតសរុប ៩០រូប (ក្នុងនោះមានស្ត្រី ៩០ភាគរយ)។ ជាលទ្ធផលសិក្ខាកាមបានទទួលនូវចំណេះដឹង និងបទពិសោធន៍ជាច្រើនទាក់ទងនឹងសុខភាពផ្លូវចិត្ត និងផ្នែកសតិអារម្មណ៍ ក្នុងស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩

- បានរៀបចំសិក្ខាសាលាស្តីពី "សមភាពយេនឌ័រក្នុងវិស័យពាណិជ្ជកម្ម" ក្នុងគោលបំណងឱ្យមន្ត្រីរាជការក្រសួងពាណិជ្ជកម្ម បានយល់ដឹងពីគោលគំនិតយេនឌ័រ ទំនាក់ទំនងអំណាច ការបញ្ជ្រាបយេនឌ័រ និងការងារពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញាស៊ីដ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ក្រោមអធិបតីភាព **លោកជំទាវ ចម និម្មល រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម** ដែលមានសមាសភាពចូលរួមពីអនុរដ្ឋលេខាធិការ អគ្គាធិការ ថ្នាក់ដឹកនាំ សមាជិកក្រុមការងារយេនឌ័រ ព្រមទាំងមន្ត្រីជាស្ត្រីផ្សេងទៀតសរុប ៩០រូប (ក្នុងនោះមានស្ត្រី ៩៥ភាគរយ)។ លទ្ធផលនៃសិក្ខាសាលា សិក្ខាកាមបានទទួលនូវចំណេះដឹងផ្នែក សមភាពយេនឌ័រ ទំនាក់ទំនងអំណាច ការបញ្ជ្រាបយេនឌ័រ និងការអនុវត្តអនុសញ្ញាស៊ីដ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១ ក្រុមការងារយេនឌ័រ បានរៀបចំកិច្ចប្រជុំផ្ទៃក្នុង ស្តីពីវឌ្ឍនភាពការងារយេនឌ័ររបស់ក្រសួង ដឹកនាំដោយ **លោកជំទាវ ចម និម្មល រដ្ឋលេខាធិការ** និងជាប្រធានក្រុមការងារយេនឌ័រក្រសួងពាណិជ្ជកម្ម តាមប្រព័ន្ធវីដេអូ Zoom ដែលមានសមាសភាព ចូលរួមសរុបមានចំនួន ៥៥រូប
- ថ្ងៃទី១ ខែតុលា ២០២១ ក្រុមការងារយេនឌ័រ បានរៀបចំកិច្ចប្រជុំ ដើម្បីបូកសរុបលទ្ធផលការងារ យេនឌ័ររយៈពេល៩ខែឆ្នាំ២០២១ និងផែនការសកម្មភាពបន្ត ដឹកនាំដោយ **លោកជំទាវ ចម និម្មល រដ្ឋលេខាធិការ** និងជាប្រធានក្រុមការងារយេនឌ័រក្រសួងពាណិជ្ជកម្ម តាមប្រព័ន្ធវីដេអូ សមាសភាពចូលរួមសរុប៥៥រូប ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ ក្រុមការងារយេនឌ័រ បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួល (JCC)លើកទី៤ របស់គម្រោងបញ្ជ្រាបយេនឌ័រ ដើម្បីបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី(PGM-WEE) តាមប្រព័ន្ធវីដេអូ ក្រោមអធិបតីភាព **លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី
- ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ ក្រុមការងារយេនឌ័រ បានចូលរួមកិច្ចប្រជុំ ស្តីពីក្រុមការងារបច្ចេកទេសយេនឌ័រ (TWG-G) ដើម្បីពិនិត្យលើវឌ្ឍនភាពគន្លឹះៗ និងទិសដៅបន្ត ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីនៅកម្ពុជា តាមរយៈប្រព័ន្ធវីដេអូ Zoom Meeting ក្រោមអធិបតីភាព **លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី
- ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ ក្រុមការងារយេនឌ័រ បានចូលរួមកិច្ចប្រជុំ ស្តីពីកិច្ចពិភាក្សាអំពីស្ថានភាពភាគលាភប្រជាសាស្ត្រ និងភាគលាភយេនឌ័រនៅកម្ពុជា តាមរយៈប្រព័ន្ធវីដេអូ Zoom Meeting ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ប៉ូច ប៊ុណ្ណាក់ រដ្ឋលេខាធិការ** ក្រសួងផែនការ
- ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ **លោកជំទាវ ចម និម្មល រដ្ឋលេខាធិការ** និងជាប្រធានក្រុមការងារយេនឌ័រ អមដោយសមាជិកនៃក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួងពាណិជ្ជកម្ម បានផ្តល់កិច្ចសម្ភាសន៍ ស្តីពីដំណើរការនៃការរៀបចំអនុវត្ត ការត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យពាណិជ្ជកម្ម ជាមួយសមាជិកគម្រោងបញ្ជ្រាបយេនឌ័រ ដើម្បីបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (PGM-WEE) របស់ក្រសួងកិច្ចការនារី
- ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ **លោកជំទាវ សេរី បុរាពេជ្រ អនុរដ្ឋលេខាធិការ** និងជាអនុប្រធានក្រុមការងារយេនឌ័រក្រសួងពាណិជ្ជកម្ម តំណាង **លោកជំទាវ ចម និម្មល** អមដោយសមាជិកនៃក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួងពាណិជ្ជកម្ម បានផ្តល់កិច្ចសម្ភាសន៍លើការងារពាក់ព័ន្ធអំពីផលប៉ះពាល់មកលើយេនឌ័រ តាមរយៈប្រព័ន្ធវីដេអូ Zoom Meeting ជាមួយក្រុមការងារបច្ចេកទេសទទួលបន្ទុកផ្នែកយេនឌ័រ និងសេវាពាណិជ្ជកម្ម នៃក្រសួងកិច្ចការងារនារី
- ថ្ងៃទី៣ ដល់ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២១ ក្រុមការងារយេនឌ័រ បានចូលរួមបណ្តុះបណ្តាលស្តីពី ការលើកកម្ពស់សមភាពយេនឌ័រ និងបរិយាបន្នពិការភាព តាមប្រព័ន្ធវីដេអូ រៀបចំឡើងដោយក្រសួងកិច្ចការនារី ។

## ខ. សកម្មភាពផ្សេងៗរបស់ក្រុមលេខាធិការដ្ឋានការងារយេនឌ័រ

- ពីថ្ងៃទី២០ ខែមេសា ដល់ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២១ លោកជំទាវ តាំង សុគន្ធមាលា អគ្គាធិការ និង ជាប្រធានក្រុមលេខាធិការដ្ឋានការងារយេនឌ័រ បានដឹកនាំក្រុមការងារយេនឌ័រចូលរួមក្នុងយុទ្ធនាការលក់ ផ្គត់ផ្គង់ស្បៀង និងគ្រឿងឧបភោគបរិភោគ ជូនប្រជាពលរដ្ឋរស់នៅតំបន់បិទខ្ទប់ និងតំបន់ក្រហម ក្នុង ភូមិសាស្ត្ររាជធានីភ្នំពេញ ដែលកំពុងរងហានិភ័យពីការឆ្លងរីករាលដាលធ្ងន់ធ្ងរ នៃជំងឺកូវីដ-១៩
- បានរៀបចំចងក្រងសៀវភៅផែនការយុទ្ធសាស្ត្របញ្ជ្រាបការងារយេនឌ័រ ២០២១-២០២៥
- បានរៀបចំតារាងតារាងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ២០២១-២០២៥
- បានរៀបចំផែនការសកម្មភាពការងារបញ្ជ្រាបយេនឌ័រប្រចាំឆ្នាំ២០២១ ដោយបំបែកពីផែនការយុទ្ធសាស្ត្រ យកមកលម្អិតជាផែនការសកម្មភាពប្រចាំឆ្នាំ ២០២១-២០២៣
- បានធ្វើសេចក្តីកំណត់ ស្តីពីរបៀបរបបការងាររបស់ក្រុមលេខាធិការដ្ឋានការងារយេនឌ័រ
- ក្រុមលេខាធិការដ្ឋានការងារយេនឌ័របានរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ខ្លួនចំនួន ៤លើករួមមានៈ កិច្ចប្រជុំ ពិគ្រោះយោបល់បែងចែកតួនាទីភារកិច្ច និងកិច្ចដំណើរការរៀបចំផែនការសកម្មភាពបញ្ជ្រាបយេនឌ័រក្នុង វិស័យពាណិជ្ជកម្ម និងកិច្ចប្រជុំ ស្តីពីការប្រមូលធាតុចូល ដើម្បីត្រៀមរៀបចំសិក្ខាសាលាចំនួន ២លើក។

## ១០. ការងារអគ្គាធិការដ្ឋាន [9]

- បានចុះធ្វើអធិការកិច្ចផ្ទាល់ នៅក្រុមហ៊ុនហ្រ្គីនត្រេដ ១លើក លើការងារគ្រប់គ្រងរដ្ឋបាល គណនេយ្យ និងហិរញ្ញវត្ថុ សន្និធិស្បៀងបម្រុងរដ្ឋ ការគ្រប់គ្រងបំណុល និងបានពិនិត្យលើការកែលម្អអនុសាសន៍ ដែលបានរកឃើញដោយក្រុមអធិការកិច្ច/សវនកម្ម ការិយបរិច្ឆេទ ឆ្នាំ២០១៩។ ជាលទ្ធផល ក្រុមការងារ បានសង្កេតឃើញថា មានចំណុចបន្តិចបន្តួចដែលត្រូវកែលម្អបន្ថែម
- បានចុះអធិការកិច្ចដោយមិនជូនដំណឹងមុនចំនួន ១អង្គភាព ចំណុះទីស្តីការក្រសួង លើការគោរពវិន័យ ពេលម៉ោងធ្វើការ សណ្តាប់ធ្នាប់ និងសកម្មភាពអវិជ្ជមាននានា
- បានប្រជុំតាមប្រព័ន្ធវីដេអូ Zoom ជាមួយ ៦អង្គភាព រួមមានៈ មន្ទីរពាណិជ្ជកម្មខេត្តប៉ៃលិន ខេត្តបន្ទាយ មានជ័យ ខេត្តឧត្តរមានជ័យ ខេត្តបាត់ដំបង ខេត្តព្រៃវែង និងមន្ទីរពាណិជ្ជកម្មខេត្តរតនគិរី
- បានធ្វើអធិការកិច្ចតាមរយៈការពិនិត្យ លើរបាយការណ៍កែលម្អតាមអនុសាសន៍របស់ប្រតិភូអធិការកិច្ច/ សវនកម្មឆ្នាំ២០២០ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច អាជ្ញាធរសវនកម្មជាតិ និងសវនកម្មផ្ទៃក្នុងនៃក្រសួងពាណិជ្ជកម្មចំនួន ២៧អង្គភាព ចំណុច ដែលត្រូវបានកែលម្អមាន ១៣០ចំណុច (ការងាររដ្ឋបាលនិងបច្ចេកទេស ៤២ចំណុច គណនេយ្យ និង ហិរញ្ញវត្ថុ ២៨ចំណុច ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ២៩ចំណុច កិច្ចលទ្ធកម្មសាធារណៈ ២១ចំណុច និង ការផ្តល់សេវាសាធារណៈ ១០ចំណុច)។ អង្គភាពទាំង ២៧រួមមានៈមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ១៨ អង្គភាព (ខេត្តប៉ៃលិន កណ្តាល តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ កោះកុង បាត់ដំបង កំពង់ធំ សៀមរាប បន្ទាយមានជ័យ ឧត្តរមានជ័យ ព្រៃវែង ស្វាយរៀង កំពង់ចាម ត្បូងឃ្មុំ រតនគិរី និងស្ទឹងត្រែង)
  - សាខាអគ្គនាយកដ្ឋាន ក.ប.ប. រាជធានី-ខេត្ត ៤អង្គភាព (ខេត្តកណ្តាល កំពង់ស្ពឺ ប៉ៃលិន និង ខេត្តបាត់ដំបង)
  - តំណាងពាណិជ្ជកម្មប្រចាំតំបន់សេដ្ឋកិច្ចពិសេស ២អង្គភាព (តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ និងតំបន់ សេដ្ឋកិច្ចពិសេសប៉ោយប៉ែត-អូរនាង)
- បានធ្វើការដោះស្រាយចប់ជាស្ថាពរនូវ ករណីវិវាទរបស់លោកអនុប្រធានមន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង

[9] ប្រភពៈ អគ្គាធិការដ្ឋាន

ដោយបានបញ្ជូនលោកអនុប្រធានមន្ទីរឱ្យត្រឡប់ទៅបំពេញការងារនៅអង្គភាពដើមវិញ
- បានចុះពិនិត្យដោះស្រាយវិវាទដីធ្លីរបស់មន្ទីរពាណិជ្ជកម្មខេត្តកណ្តាលចំនួន ២ករណី ចប់ជាស្ថាពរដោយបានរៀបចំដីជូនប្រជាពលរដ្ឋចំនួន ១០គ្រួសារ នៅស្រុកល្វាឯម និងបានសម្របសម្រួលបញ្ឈប់ការសាងសង់អាគារស្នាក់ការលើដីកម្មសិទ្ធិរបស់មន្ទីរ នៅស្រុកខ្សាច់កណ្តាល
- បានបូកសរុបរបាយការណ៍ និងកំណត់ហេតុកិច្ចប្រជុំប្រចាំខែ របស់បណ្តាអង្គភាពក្រោមឱវាទក្រសួងពាណិជ្ជកម្ម ចំនួន ២៨អង្គភាព ក្រុមហ៊ុនហ្គ្រីនត្រេដចំនួន ១អង្គភាព មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ២៥អង្គភាព សរុបចំនួន ៥៤អង្គភាព បានចូលរួមកិច្ចប្រជុំក្នុង និងក្រៅប្រទេស តាមប្រព័ន្ធអនឡាញសរុបចំនួន ៣៨លើក
- បានរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីអគ្គាធិការដ្ឋានចំនួន ១០លើក
- បានចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗ សរុបចំនួន ៣៦លើក។

## ១១. ការងារសវនកម្មផ្ទៃក្នុង[10]

ផ្អែកតាមផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០២១ ក្រសួងបានចុះធ្វើសវនកម្មសរុបចំនួន ៣អង្គភាព និងពិនិត្យ តាមដានតាមរយៈរបាយការណ៍ឆ្លើយតប នៃការអនុវត្តកែលម្អអនុសាសន៍សវនកម្មគ្រាមុន នៅមន្ទីរពាណិជ្ជកម្មសរុបចំនួន ៨អង្គភាពដូចខាងក្រោម៖

- **អង្គភាពថ្នាក់កណ្តាល:** បានចុះធ្វើសវនកម្ម និងពិនិត្យតាមដាននៃការអនុវត្តកែលម្អអនុសាសន៍សវនកម្មគ្រាមុនបានចំនួន ៣អង្គភាព ចំណុះអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេសរួមមាន៖ ១.នាយកដ្ឋាននីតិកម្ម ២.នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន និង៣.នាយកដ្ឋានផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម
- **អង្គភាពថ្នាក់មូលដ្ឋាន:** បានពិនិត្យតាមដាន តាមរយៈរបាយការណ៍ឆ្លើយតប នៃការអនុវត្តកែលម្អអនុសាសន៍សវនកម្មគ្រាមុន នៅមន្ទីរពាណិជ្ជកម្មចំនួន ៨អង្គភាពរួមមាន៖ ១.មន្ទីរពាណិជ្ជកម្មខេត្តត្បូងឃ្មុំ ២.កណ្តាល ៣.បន្ទាយមានជ័យ ៤.ពោធិ៍សាត់ ៥.កំពង់ចាម ៦.បាត់ដំបង ៧.កំពង់ឆ្នាំង និង ៨.ខេត្តតាកែវ ដែលបានឆ្លើយតប និងអនុវត្តនូវអនុសាសន៍គ្រាមុនបានពេញលេញគួរជាទីមោទនៈ។

## ១២. សកម្មភាពការងារមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត

- ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មបានចំនួន 0 នៅតាមបណ្តារាជធានី-ខេត្តទាំង២៥
- ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មបាន ៣ ១១២ តាមរយៈការិយាល័យច្រកចេញ ចូលតែមួយ នៅតាមក្រុង-ស្រុក ខណ្ឌគោលដៅ
- ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មគ្រឿងអលង្ការ លោហៈធាតុ និងត្បូងថ្មមានតំលៃមាន សរុប៣០ច្បាប់
- ផ្តល់ការប្រឹក្សាជួយសម្រួលដល់ពាណិជ្ជករ អាជីវករដែលមានបំណងចង់បង្កើតអាជីវកម្ម ការចុះបញ្ជីពាណិជ្ជកម្ម សហគ្រាស ក្រុមហ៊ុន ចុះបញ្ជីម៉ាក និងសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការប្រកបអាជីវកម្ម
- ផ្សព្វផ្សាយណែនាំពីតម្រូវការទីផ្សារ ពិសេសចំពោះទំនិញកសិផលដែលជាតម្រូវការក្នុងស្រុក និងទីផ្សារអន្តរជាតិ ដើម្បីតម្រង់ទិសឱ្យកសិករអាចសម្រេចចិត្តធ្វើការដាំដុះបានត្រឹមត្រូវជៀសវាងការធ្លាក់ថ្លៃ និងកកស្ទះ។

## ១៣. ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន រាជធានី ខេត្ត

ដើម្បីតាមដានត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល តាមរយៈការជួបប្រាស្រ័យផ្ទាល់ជាមួយប្រជាពលរដ្ឋ មន្ត្រីក្រសួងពាណិជ្ជកម្ម ចាប់ពីថ្នាក់អគ្គនាយករងឡើងទៅបានចូលរួម សកម្មភាពក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋាន រាជធានី ខេត្ត ក្រុង ស្រុក

[10] ប្រភព៖ នាយកដ្ឋានសវនកម្មផ្ទៃក្នុង

ខណ្ឌ តាមគោលដៅរៀងៗខ្លួន នៅទូទាំងប្រទេសប្រកបដោយប្រសិទ្ធភាព និងទទួលខុសត្រូវខ្ពស់។

កាលពីដើមឆ្នាំ២០២១នេះ ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាប្រធាន អនុប្រធាន ឬសមាជិកក្រុមការងារនីមួយៗ បានចូលរួមក្នុងវេទិកាសាធារណៈ ដើម្បីពិភាក្សា បំភ្លឺ និងផ្សព្វផ្សាយ ជូនដល់ប្រជាពលរដ្ឋឱ្យបានជ្រួតជ្រាប នូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលបញ្ហាថ្មីៗទាក់ទងនឹងស្ថិរភាពនយោបាយសន្តិសុខសណ្តាប់ធ្នាប់សង្គម យុទ្ធសាស្រ្តពាណិជ្ជកម្ម ដើម្បីលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ និងការចូលរួមដោះស្រាយសំណូមពរ និងកង្វល់ផ្សេងៗ។ ប៉ុន្តែបន្ទាប់ពីមានការផ្ទុះឆ្លងរាលដាលជាបន្តបន្ទាប់នៃជំងឺកូវីដ-១៩ ពោលគឺ "ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ" និងដើម្បីចូលរួមអនុវត្តតាមវិធានការណែនាំរបស់ក្រសួងសុខាភិបាល ជាពិសេសគឺ ៣ការពារ ៣កុំ នោះការរៀបចំវេទិកាសាធារណៈ ដើម្បីពិភាក្សា បំភ្លឺ និងផ្សព្វផ្សាយ ជូនដល់ប្រជាពលរដ្ឋត្រូវបានផ្អាកស្ទើរតែទាំងស្រុង។ ទោះជាយ៉ាងនេះក្តី ក៏ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាប្រធាន អនុប្រធានសមាជិក សមាជិកាក្រុមការងារបានចូលរួមផ្សព្វផ្សាយ និងដោះស្រាយបញ្ហារួមមាន៖

- បញ្ហាទីផ្សារ ថ្លៃកសិផល ការពង្រឹងគុណភាព និងការជំរុញកែច្នៃធ្វើពិពិធកម្មកសិផលសម្រាប់ទីផ្សារក្នុងស្រុក និងនាំចេញ ការប្រើប្រាស់យន្តការទីផ្សារព្រំដែនដើម្បីលើកកម្ពស់ជីវភាពពលរដ្ឋ
- ចូលរួមជំរុញការអនុវត្ត និងដោះស្រាយបញ្ហាទាក់ទងនឹងការអនុវត្តកម្មវិធីភូមិ ឃុំមានសុវត្ថិភាព ការជំរុញការផ្តល់សេវាសាធារណៈឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា រួមទាំងការយកចិត្តទុកដាក់ដល់សុវត្ថិភាពចំណីអាហារ គ្រឿងឧបភោគបរិភោគផ្សេងៗ ក្នុងកាលៈទេសដែលមានការបិទខ្ទប់
- ជួយឧបត្ថម្ភជាថវិកា និងសម្ភារៈ ដល់ការរៀបចំមណ្ឌលចត្តាឡីស័កមួយចំនួនដែលមានទីតាំង នៅតាមខេត្ត ក្រុង ស្រុក ខណ្ឌ ផ្សព្វផ្សាយសេចក្តីណែនាំ និងព័ត៌មានថ្មីៗទាក់ទងនឹងការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល ដើម្បីឆ្លើយតបនឹងបញ្ហាដែលកើតមានដូចជា ករណីបង្ការ និងទប់ស្កាត់ជំងឺរីករាលដាលកូវីដ-១៩ តាមវិធានការអនាម័យ និងវិធានការរក្សាសុខភាព ការបង្ការទប់ស្កាត់នូវការឆ្លងក្នុងសហគមន៍នៃជំងឺកូវីដ-១៩ និងការចូលរួមចាក់ថ្នាំការពារជំងឺកូវីដ-១៩ឱ្យបានគ្រប់ចំនួនពេញលេញ។

ជារួម ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្តរបស់ក្រសួងពាណិជ្ជកម្ម បានបំពេញការងារប្រកបដោយការទទួលខុសត្រូវដោយបានសហការសម្របសម្រួល និងបន្តដោះស្រាយបញ្ហានានាក្នុងមូលដ្ឋានសំដៅធ្វើឱ្យប្រជាពលរដ្ឋកាន់តែមានការជឿទុកចិត្ត និងគាំទ្រពីរាជរដ្ឋាភិបាល ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រមុខដឹកនាំ។

## ១៤. ការងារឆ្លើយតបសភាពការណ៍ចំពោះមុខ

### ក.ការងារចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩

ក្នុងគោលដៅចូលរួមទប់ស្កាត់ការឆ្លងរាលដាល និងការស្លាប់ដោយមេរោគកូវីដ-១៩ ក្រសួងពាណិជ្ជកម្ម បានសហការយ៉ាងជិតស្និទ្ធជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសម្ព័ន្ធគ្រូពេទ្យសហភាពសហព័ន្ធយុវជនកម្ពុជា(ស.គ.ស.ស.យ.ក) ក្នុងការចាក់វ៉ាក់សាំងជូនដល់មន្ត្រីរាជការ និងបងប្អូនប្រជាពលរដ្ឋក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ ស្របតាមការរៀបចំរបស់គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) បានចំនួន ២ លើក សរុបចំនួន **៦ ៤៦២**នាក់

- លើកទី១៖ ចាប់ពីថ្ងៃទី៣ ដល់ទី៦ ខែមេសា ឆ្នាំ២០២១ សម្រាប់មន្ត្រីរាជការក្រោមឱវាទក្រសួងពាណិជ្ជកម្ម
- លើកទី២៖ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១ សម្រាប់មន្ត្រីរាជការ និងប្រជាពលរដ្ឋ ដែលរស់នៅក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ។

### ខ.ការងារចុះជួយប្រជាពលរដ្ឋក្នុងតំបន់ក្រហម

- បានចូលរួមត្រួតពិនិត្យ និងបញ្ចេញស្តុកសន្និធិស្បៀងត្រៀមបម្រុងរបស់រាជរដ្ឋាភិបាលចែកជូនប្រជាពលរដ្ឋក្នុងអំឡុងពេលធ្វើចត្តាឡីស័កពលករ នៅតាមបណ្តាខេត្តជាប់ព្រំដែនថៃ និងក្នុងអំឡុងពេលបិទខ្ទប់ភូមិ

សាស្ត្រាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល

- បានសម្របសម្រួលកៀរគរវិស័យឯកជន និងរៀបចំស្តង់លក់ទំនិញយុទ្ធសាស្ត្រ ក្នុងយុទ្ធនាការផ្គត់ផ្គង់ស្បៀង និងគ្រឿងឧបភោគបរិភោគ បម្រើជីវភាពប្រជាពលរដ្ឋប្រចាំថ្ងៃក្នុងតំបន់ក្រហម ខណៈពេលដែលមានការបិទខ្ទប់តំបន់មួយចំនួនក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ដោយការរីករាលដាលនៃជំងឺកូវីដ-១៩ ក្រោយព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ
- បានសហការសម្របសម្រួលតាមគោលដៅស្តង់លក់ទំនិញជូនប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បិទខ្ទប់ បានចំនួន ១១ទីតាំង។

ក្នុងរយៈពេល ១៦ថ្ងៃ ក្នុងការសម្របសម្រួលដំណើរការនៃការផ្គត់ផ្គង់ស្បៀងក្នុងតំបន់បិទខ្ទប់ (ពីថ្ងៃទី២០ ខែមេសា ដល់ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២១) ក្រសួងពាណិជ្ជកម្ម បានចំណាយថវិកាសរុបអស់ប្រមាណ ៤៩០ លានរៀល សម្រាប់ចំណាយបំពេញខាតក្នុងការលក់ទំនិញថ្លៃដើមជូនប្រជាពលរដ្ឋក្នុងតំបនបិទខ្ទប់។ ចំណាយទាំងនោះរួមមានៈ ចំណាយលើថ្លៃជួលរថយន្តធុនធំប្រចាំការសម្រាប់ដឹកជញ្ជូនទំនិញបែងចែកតាមស្តង់ ចំណាយសម្រាប់ក្រុមហ៊ុនដឹកជញ្ជូនទំនិញជូនប្រជាពលរដ្ឋក្នុងតំបន់បិទខ្ទប់ ចំណាយលើការបង្កើតកម្មវិធីលក់ទំនិញតាមអនឡាញ ចំណាយ លើការផ្គត់ផ្គង់អាហារ ចំណាយលើការជួលស្តង់ ចំណាយទិញសម្ភារសុវត្ថិភាព (អាល់កុល ម៉ាស ស្រោមដៃ និងដបដាក់អាល់កុល...) និងចំណាយលើការខូចខាតបែកបាក់ជាដើម។

**គ. ការងាររកសាងឯកសារយុទ្ធសាស្ត្រទាញផលប្រយោជន៍ជាអតិបរមាពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី(FTA)**

យុទ្ធសាស្ត្រទាញយកអត្ថប្រយោជន៍ជាអតិបរមាពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីៈ គឺជាការសិក្សាដើម្បីជំរុញការនាំចេញឲ្យអស់សក្តានុពលនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលកម្ពុជាជាហត្ថលេខី។ ការសិក្សានេះគឺផ្តោតលើរបាំងពន្ធគយ និងរបាំងមិនមែនពន្ធគយ (ស្តង់ដារ អនាម័យ ភូតគាមអនាម័យ របាំងបច្ចេកទេស បទប្បញ្ញត្តិ បច្ចេកទេស អនុលោមភាព និងភស្តុភារកម្ម) ចំពោះទំនិញសក្តានុពលដែលត្រូវធ្វើការនាំចេញទៅប្រទេសដែលជាភាគីហត្ថលេខីនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី សំដៅធ្វើយ៉ាងណាដើម្បីឲ្យការនាំចេញនោះទទួលបានប្រយោជន៍ជាអតិបរមា ។ ការសិក្សាស្រាវជ្រាវនេះបានរកឃើញម៉ាទ្រីសនៃបញ្ហាសម្រាប់ជំរុញផលិតកម្ម និងការនាំចេញ ចំនួន១៥ចំណុច ដែលត្រូវធ្វើការវិភាគ និងដោះស្រាយ។ គោលបំណងសំខាន់ៗនៃការសិក្សាមានៈ

- សិក្សាស្វែងយល់ពីកត្តាដែលមានឥទ្ធិពលសំខាន់ៗ ដើម្បីពង្រឹងសមត្ថភាពវិស័យពាក់ព័ន្ធ សំដៅទាញយកផលប្រយោជន៍ជាអតិបរមាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដែលកម្ពុជាជាហត្ថលេខី
- ជ្រើសរើស និងលើកសំណើអំពីទំនិញសក្តានុពលសម្រាប់ជំរុញការផលិត និងនាំចេញ ក្នុងរយៈពេលខ្លី មធ្យម និងវែង យោងតាមទីផ្សារដែលកម្ពុជាទទួលបាន
- វិភាគពីកត្តាពាក់ព័ន្ធ តាមរយៈការធ្វើវិភាគ SWOT លើចំណុចខ្លាំង (Strength) ចំណុចខ្សោយ (Weakness) ឱកាស (Opportunity) និងបញ្ហាគំរាមកំហែង (Threat) នៃផលិតផល ដើម្បីស្វែងយល់ពីកត្តាពាក់ព័ន្ធនឹងការជំរុញការនាំចេញបន្ថែម ទៅកាន់ទីផ្សារគោលដៅ
- កំណត់កត្តាប្រឈមទាំងឡាយ និងដាក់ចេញនូវវិធានការ និងសកម្មភាពដែលត្រូវអនុវត្តន៍ សម្រាប់ក្រសួងស្ថាប័នពាក់ព័ន្ធ
- ផ្សព្វផ្សាយជូនសាធារណជន ធុរជន និងផ្នែកពាក់ព័ន្ធទាំងអស់ ដើម្បីចូលរួមអនុវត្តន៍លក្ខខណ្ឌ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ឲ្យមានប្រសិទ្ធភាពខ្ពស់។

# ជំពូកទី២
# ទិសដៅការងារ
# ពាណិជ្ជកម្មឆ្នាំ២០២២

## ១. អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម [11]

### ១.១. ការងារចុះបញ្ជីពាណិជ្ជកម្ម

- បន្តជំរុញការអនុម័តសេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពី"សហគ្រាសពាណិជ្ជកម្ម" និងច្បាប់ស្តីពី"វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម"ពីរដ្ឋសភា និងព្រឹទ្ធសភា
- ដាក់ឱ្យដំណើរការមជ្ឈមណ្ឌលទិន្នន័យ (DATA CENTER) សម្រាប់ផ្ទុកព័ត៌មានចុះបញ្ជីពាណិជ្ជកម្ម ព័ត៌មានការស្នើសុំវិញ្ញាបនបត្រប្រភពដើមទំនិញ និងព័ត៌មានផ្សេងៗទៀតរបស់ក្រសួងពាណិជ្ជកម្ម និងដាក់ឱ្យដំណើរការមជ្ឈមណ្ឌលទិន្នន័យថ្មីនេះ
- ផ្ទេរ ទិន្នន័យចុះបញ្ជីពាណិជ្ជកម្ម ទៅមជ្ឈមណ្ឌលទិន្នន័យ (DATA CENTER)
- ការអភិវឌ្ឍប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ការផ្តល់លិខិតអនុញ្ញាត និងអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- អភិវឌ្ឍន៍ប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ការចុះបញ្ជីកែប្រែ ដើម្បីជំនួសប្រព័ន្ធចុះបញ្ជីកែប្រែបច្ចុប្បន្ន
- រៀបចំប្រកាសរួមជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈ និងបទប្បញ្ញត្តិសម្រាប់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បន្តភ្ជាប់ប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងតាមរយៈប្រព័ន្ធថ្នាលបច្ចេកវិទ្យាព័ត៌មានវិទ្យា
- បន្តការបណ្តុះបណ្តាល និងផ្សព្វផ្សាយច្បាប់ ក្នុងការចុះបញ្ជីពាណិជ្ជកម្ម និងការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- ជំរុញការផ្តល់លិខិតអនុញ្ញាត និងអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

### ១.២. ការងារកម្មសិទ្ធិបញ្ញា

- ដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីម៉ាក IPAS ជំនាន់ទី៤ និងបន្តលើកកម្ពស់ការចុះបញ្ជីម៉ាកតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ដែលអនុញ្ញាតឱ្យបង់ប្រាក់ចុះបញ្ជីម៉ាកតាមប្រព័ន្ធអនឡាញពេញលេញ
- ដាក់ឱ្យដំណើរការប្រព័ន្ធស្វ័យប្រវត្ត សម្រាប់ការដាក់ពាក្យការចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិ នៅព្រះរាជាណាចក្រកម្ពុជា (Madrid e-Filing)
- បញ្ចប់សេចក្តីព្រាងច្បាប់ ស្តីពី ការសម្ងាត់ពាណិជ្ជកម្ម និងព័ត៌មានមិនបង្ហាញ
- បញ្ចប់សេចក្តីព្រាងអនុក្រឹត្យ ស្តីពី នីតិវិធីរដ្ឋបាលនៃការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា
- បន្តត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរបស់គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ឆ្នាំ ២០២១-២០២៣
- រៀបចំទិវាកម្មសិទ្ធិបញ្ញាពិភពលោក និងព្រឹត្តិការណ៍កម្មសិទ្ធិបញ្ញានៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២
- បន្តសិក្សាលើលទ្ធភាព និងអត្ថប្រយោជន៍ចូលជាសមាជិកកិច្ចព្រមព្រៀង អនុសញ្ញា ឬសន្ធិសញ្ញាអន្តរជាតិផ្សេងទៀតពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា
- ចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ"អំបិល និងផ្កាអំបិលកំពត" "បង្កងតាកែវ" និង "ទឹកត្រីកំពត-កែប"
- ចុះបញ្ជីម៉ាកសមូហភាព "ក្រូចពោធិ៍សាត់" "ចម្លាក់ប្រាក់ ស្ពាន់ខេត្តកណ្តាល" និង "នំបញ្ចុកសៀមរាប"
- បន្តសហការជាមួយដៃគូអភិវឌ្ឍន៍នានា ក្នុងការលើកកម្ពស់ និងកសាងកេរ្តិ៍ឈ្មោះម៉ាកសម្រាប់ទំនិញសក្តានុពល ដូចជា ទឹកឃ្មុំព្រៃមណ្ឌលគិរី អំបិលនិងផ្កាអំបិលកំពត អំបុកកំពង់ធំ ក្រូចពោធិ៍សាត់ ចម្លាក់ប្រាក់ ស្ពាន់ខេត្តកណ្តាល និងនំបញ្ចុកសៀមរាប

[11] ប្រភព ៖ អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម

- រៀបចំពិធីសម្ពោធម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ទឹកឃ្មុំព្រៃមណ្ឌលគិរី និងម៉ាកសមូហភាព អំបុកកំពង់ធំ
- បន្តអនុវត្តគម្រោងថ្នាក់តំបន់(AFD) ស្តីពី ការលើកកម្ពស់ និងការទទួលស្គាល់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ សម្រាប់ប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ឆ្នាំ២០១៩-២០២២
- បន្តលើកកម្ពស់ចំណេះដឹងសាធារណៈ បង្កើនសមត្ថភាពមន្ត្រី និងមន្ត្រីអនុវត្តច្បាប់ផ្នែកកម្មសិទ្ធិបញ្ញា និងសាធារណជនទូទៅ ព្រមទាំងបញ្ចូលទៅក្នុងកម្មវិធីសិក្សានៅតាមគ្រឹះស្ថានអប់រំតាមរាជធានី ខេត្ត ក្រុង
- បន្តរៀបចំវគ្គបណ្តុះបណ្តាលភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក។

## ១.៣. នាយកដ្ឋាននាំចេញ នាំចូល

- បន្តរៀបចំកម្មវិធី និងវគ្គបណ្តុះបណ្តាល ដល់អ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំឯកសារនាំចេញ-នាំចូល នៅក្រសួងពាណិជ្ជកម្ម
- បន្តផ្សព្វផ្សាយស្តីពី វិធានដើមកំណើតទំនិញ
- បន្តសហការចូលរួមចុះអង្កេតដើមកំណើតទំនិញជាមួយគយ/ក្រុមការងារ ចុះអង្កេតនានានៃប្រទេសផ្តល់ភាពអនុគ្រោះពាណិជ្ជកម្ម
- បន្តចូលរួមអនុវត្តនូវស្វ័យបញ្ជាក់ដើមកំណើតទំនិញទូទាំងអាស៊ាន(ASEAN-Wide Self-Certification AWSC)
- បន្តរៀបចំបន្ថែម CO ទម្រង់ផ្សេងៗទៀតស្របតាមវិធានដើមកំណើតទំនិញ នៃប្រទេសនាំចូល ក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម
- បន្តអនុវត្តប្រព័ន្ធស្វ័យប្រវត្តកម្មបញ្ជាក់ដើមកំណើតទំនិញ (CO) ជាមួយប្រព័ន្ធអាស៊ីគូដា(ASYCUDA) ជាមួយបណ្តាប្រទេសសមាជិកអាស៊ាន
- បន្តចូលរួមអនុវត្តជំហានដំបូងប្រព័ន្ធបញ្ជរតែមួយជាតិសម្រាប់ការចេញអាជ្ញាបណ្ណនាំចេញ-នាំចូល និងវិញ្ញាបនបត្រគឹមប័រលីប្រូសេស ក្រោមប្រព័ន្ធបញ្ជរតែមួយជាតិ(NSW) តាមរយៈគេហទំព័រ www.nsw. gov.kh
- បន្តចូលរួមកិច្ចប្រជុំប្រចាំត្រីមាស រវាងក្រុមការងារក្រសួងពាណិជ្ជកម្ម ក្រុមការងារក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមការងារនៃគម្រោងរោងចក្រកាន់តែប្រសើរ (ILO/BFC) និងក្រុមការងារសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC)
- បន្តចូលរួមកិច្ចប្រជុំគណៈកម្មការប្រឹក្សាការងារ Labor Advisory Committee (LAC)
- បន្តចូលរួមកិច្ចប្រជុំគណៈកម្មការប្រឹក្សាគម្រោង Project Advisory Committee (PAC)
- បន្តចូលរួមកិច្ចប្រជុំជាមួយគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម និងបាតុកម្មនៅតាមគ្រប់មុខសញ្ញា
- បន្តចូលរួមរាល់កិច្ចប្រជុំពាក់ព័ន្ធនឹងវិធានដើមកំណើតទំនិញ ដែលអនុវត្តក្នុងតំបន់ និងដៃគូ
- រៀបចំអភិវឌ្ឍប្រព័ន្ធផ្ទៀងផ្ទាត់វិញ្ញាបនបត្រដើមកំណើតទំនិញ (Verification System) ជាមួយអាស៊ាន
- បន្តចុះបញ្ជីអ្នកនាំចេញទៅកាន់ទីផ្សារសហភាពអឺរ៉ុប ប្រទេសស្វីស ណ័រវែស និងទួរគី (REX System)
- បន្តរៀបចំតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្រដើមកំណើតទំនិញជាមួយធនាគារសម្រាប់ទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក(E-payment)។

## ១.៤. តំណាងពាណិជ្ជកម្មប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស

- បន្តផ្សព្វផ្សាយពីវិធានដើមកំណើតទំនិញ ការប្រើប្រព័ន្ធ REX (Registered Exporter System-REX) និងណែនាំពីបែបបទស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញគ្រប់ទម្រង់ តាមប្រព័ន្ធស្វ័យប្រវត្តកម្ម
- បន្តសហការ ជាមួយតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ចុះធ្វើអធិការកិច្ចរោងចក្រ ត្រួតពិនិត្យការនាំចូលវត្ថុធាតុដើម និងពិនិត្យទំនិញមុនធ្វើការនាំចេញ

- បន្តសហការ ជាមួយតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ដោះស្រាយវិវាទកម្មករ និងម្ចាស់រោងចក្រ
- បន្តផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការនាំចេញទំនិញ
- បន្តចូលរួមប្រជុំជាមួយតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីស្វែងយល់បន្ថែមពីដំណើរការនៃតំបន់សេដ្ឋកិច្ចពិសេស ច្បាប់ នីតិវិធី បែបបទ និងបញ្ហាផ្សេងៗទៀត
- បន្តសហការជាមួយនឹងរោងចក្រ និងក្រសួង ដើម្បីផ្តល់ឯកសារសក្ខីកម្មនៅពេលដែលមានការស្នើសុំផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃវិធានដើមទំនិញពីប្រទេសនាំចូល
- បន្តចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ និងឯកសារឧបសម្ព័ន្ធជូនដល់អ្នកនាំចេញ តាមការស្នើសុំ។

## ២. អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស [12]

### ២.១. ការងារនីតិកម្ម

- គ្រោងបញ្ជូនសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្មទៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីត្រៀមពិភាក្សាកម្រិតអន្តរក្រសួង និងបញ្ជូនទៅសុំឆ្លងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី (ចង្អៀត) ព្រមទាំងបញ្ជូនទៅសុំការពិនិត្យ និងអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ
- បន្តពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ ស្តីពីភ្នាក់ងារពាណិជ្ជកម្ម ដើម្បីបញ្ជូនទៅសុំឆ្លងកិច្ចប្រជុំបច្ចេកទេសនៅទីស្តីការគណៈរដ្ឋមន្ត្រី
- ពិនិត្យលទ្ធភាពក្នុងការរៀបចំសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពី ប្រតិបត្តិការដែលមានកិច្ចធានា និងសេចក្តីព្រាង វិសោធនកម្មច្បាប់ក្ស័យធន
- ផ្សព្វផ្សាយច្បាប់ពាណិជ្ជកម្ម (ច្បាប់ស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, ច្បាប់ស្តីពីក្ស័យធនដល់ស្ថាប័នពាក់ព័ន្ធនានា និងផ្នែកឯកជន តាមបណ្តារាជធានី ខេត្តទូទាំងប្រទេស
- បន្តការងារចុះបញ្ជីតម្កល់លិខិតជូនដំណឹង នៃប្រតិបត្តិការដែលមានកិច្ចធានា និងការធ្វើទំនើបកម្មនូវប្រព័ន្ធតម្កល់លិខិតជូនដំណឹង នៃប្រតិបត្តិការដែលមានកិច្ចធានា (www.setfo.gov.kh) ព្រមទាំងពង្រឹងយន្តការកៀរគរប្រមូលចំណូលនេះឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការផ្សព្វផ្សាយ ការកែសម្រួល និងការធ្វើទំនើបកម្មប្រព័ន្ធតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា (www.setfo.gov.kh) ដើម្បីតភ្ជាប់ជាមួយប្រព័ន្ធទូទាត់ប្រាក់តាមប្រព័ន្ធអនឡាញ (Online Payment)
- បន្តផ្តល់ប្រឹក្សាយោបល់ និងការដោះស្រាយវិវាទពាណិជ្ជកម្មតាមរយៈការសម្រុះសម្រួលជូនដល់អាជីវករ-ពាណិជ្ជករ និងបន្តសម្របសម្រួលជាមួយមជ្ឈមណ្ឌលជាតិផ្នែកមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ពិនិត្យឡើងវិញ និងធ្វើការវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួងពាណិជ្ជកម្ម និងធ្វើការផ្តល់យោបល់ចំពោះផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តទាំងនោះ និងផ្សព្វផ្សាយលទ្ធផល
- សហការជាមួយ ASEAN អង្គការ OECD និងស្ថាប័នពាក់ព័ន្ធរៀបចំសិក្ខាសាលា និងកិច្ចប្រជុំ The ASEAN-OECD on Good Regulatory Practice Network ចំនួន ០២ លើក ក្នុងឋានៈកម្ពុជាធ្វើជាប្រធានអាស៊ាន
- ចូលរួមរៀបចំផែនការសកម្មភាពសម្រាប់ការអនុវត្តកិច្ចព្រមព្រៀងអាស៊ាន ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (ASEAN Agreement of Electronic Commerce) និងកិច្ចព្រមព្រៀង RCEP (ជំពូកស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក)

---

[12] ប្រភព៖ អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស

- រៀបចំកិច្ចប្រជុំអន្តរជាតិដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះក្រោមក្របខណ្ឌគណៈកម្មាធិការសម្របសម្រួលអាស៊ាន ស្តីពី ពាណិជ្ជតាមប្រព័ន្ធអេឡិចត្រូនិក (ASEAN Coordinting Committee on Electronic Commerce) ចំនួន ២លើក ក្នុងឆ្នាំ២០២២។

## ២.២. ការងារអភិវឌ្ឍន៍វិស័យឯកជន

- បន្តពិនិត្យតាមដានរបាយការណ៍ ស្តីពីថ្លៃទំនិញចាំបាច់ប្រចាំជីវភាព និងការស្តុកស្រូវ-អង្ករតាមបណ្តាខេត្ត ថ្លៃប្រេងឥន្ធនៈនៅរាជធានីភ្នំពេញ និងសន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សាររាជធានីភ្នំពេញ
- បន្តតាមដាន និងបូកសរុបរបាយការណ៍នៃការអនុវត្តចេញលិខិតអនុញ្ញាតធ្វើអាជីវកម្ម ពាណិជ្ជកម្ម សេវាកម្ម និងលិខិតអនុញ្ញាតធ្វើអាជីវកម្មត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ របស់មន្ទីរពាណិជ្ជកម្មរាជធានី/ខេត្ត ដើម្បីធានាប្រសិទ្ធភាពនៃការធ្វើប្រតិភូកម្មពីថ្នាក់កណ្តាលទៅថ្នាក់ខេត្ត
- បន្តតាមដានរបាយការណ៍ ស្តីពីបញ្ហាប្រឈម-សំណូមពរ និងទំនិញសក្តានុពលប្រចាំខែ របស់មន្ទីរពាណិជ្ជកម្មខេត្ត
- បន្តតាមដាន និងគ្រប់គ្រងសន្និធិទំនិញយុទ្ធសាស្ត្រ និងទំនិញចាំបាច់នៅលើទីផ្សារ
- ចុះពិនិត្យលទ្ធភាពនៃការរៀបចំបង្កើតសភាពាណិជ្ជកម្មខេត្តថ្មី នៅក្នុងខេត្តចំនួន ៧ ដូចជាៈ ខេត្តព្រះវិហារ កែប ឧត្តរមានជ័យ រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង និងខេត្តកំពង់ឆ្នាំង ព្រមទាំងផ្សព្វផ្សាយពីតួនាទី ភារកិច្ច និងអត្ថប្រយោជន៍របស់សភាពាណិជ្ជកម្ម
- រៀបចំបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងសភាពាណិជ្ជកម្មខេត្តថ្មី សម្រាប់អាណត្តិថ្មី និងសភាពាណិជ្ជកម្ម រាជធានី-ខេត្ត សម្រាប់អាណត្តិបន្ត និងសមាជិកតំណាងការិយាល័យសភាពាណិជ្ជកម្មកម្ពុជាប្រចាំប្រទេសជប៉ុន
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយពីសារប្រយោជន៍ នៃការរៀបចំសមាគម និងសម្របសម្រួលក្នុងរៀបចំបោះឆ្នោតសមាគមអាជីវកម្មនៅតាមបណ្តារាជធានី-ខេត្ត
- នឹងបន្តធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងនូវថ្លៃដើម បញ្ហាប្រឈម នៃផលិតផលសក្តានុពលដទៃទៀត រួមមានៈ កៅស៊ូ ត្រីចំនួន៦មុខ ពោតក្រហម ម្រេច គ្រាប់ស្វាយចន្ទី និងចេក
- នឹងចុះរៀបចំស្រាវជ្រាវ និងប្រមូលទិន្នន័យពីផលិតផលសូត្រតាមបណ្តាខេត្តចំនួន ៥ និងរៀបចំយុទ្ធនាការជំរុញ និងប្រើប្រាស់ផលិតផលធ្វើពីសូត្រ
- នឹងរៀបចំសិក្ខាសាលា និងផ្សព្វផ្សាយយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសូត្រ ផលិតផលសូត្រ និងម៉ាកសមូហភាពផលិតផលសូត្រខ្មែរ នៅខេត្តចំនួន ៣
- នឹងពង្រឹងការប្រើប្រាស់ម៉ាកសមូហភាពផលិតផលសូត្រខ្មែរ និងណែនាំអាជីវករសូត្រឱ្យប្រើប្រាស់
- នឹងចុះស្រាវជ្រាវកំណត់ទីតាំងភូមិសាស្ត្រផលិតផលដែលមានសក្តានុពលទៅលើការអភិវឌ្ឍខ្សែច្រវាក់តម្លៃ
- នឹងរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីគុណភាពការវេចខ្ចប់ តម្លៃដើម ស្តង់ដារស្លាកសញ្ញា ផលិតផលសក្តានុពល
- នឹងជំរុញការផ្សារភ្ជាប់រវាងអ្នកប្រមូលទិញ អ្នកកែច្នៃ អ្នកនាំចេញ និងភាគីពាក់ព័ន្ធទៅនឹងអ្នកដាំដុះ
- នឹងគ្រោងសិក្សាពីផលិតភាពនៃផលិតផលកសិពាណិជ្ជកម្មសក្តានុពលនៅតាមខេត្តគោលដៅ។

## ២.៣. ការងារផែនការ ស្ថិតិ និងព័ត៌មានវិទ្យា

- ស្រាវជ្រាវអភិវឌ្ឍន៍ និងផ្សព្វផ្សាយលើការរៀបចំនូវឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ "វិស័យពាណិជ្ជកម្ម"
- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងរៀបចំចងក្រងវឌ្ឍនភាពនៃសមិទ្ធផលការងារជាធាតុចូលសំខាន់ៗរបស់ក្រសួងពាណិជ្ជកម្មសម្រាប់ដាក់បញ្ចូលទៅក្នុងឯកសារនានារបស់រាជរដ្ឋាភិបាល ទៅតាមតម្រូវការដាក់ស្តែង

- អភិវឌ្ឍការរៀបចំ ចងក្រង និងផ្សព្វផ្សាយស្ថិតិពាណិជ្ជកម្មសំខាន់ៗ និងទាន់ពេលវេលាជូនសាធារណជន ជាពិសេសពាក់ព័ន្ធនឹងការធ្វើប្រតិបត្តិការក្នុងវិស័យពាណិជ្ជកម្ម
- ចងក្រង និងបោះពុម្ពផ្សាយនូវព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម ដែលឆ្លើយតបនឹងតម្រូវការបច្ចុប្បន្ន នៃការអភិវឌ្ឍវិស័យពាណិជ្ជកម្ម
- រៀបចំ និងគ្រប់គ្រងបណ្ដាញព័ត៌មានវិទ្យា និងគេហទំព័ររបស់ក្រសួង ឱ្យដំណើរការបានល្អមានសុវត្ថិភាព ស្ថេរភាព ទាក់ទាញ និងទាន់សម័យ ស្របតាមបរិបទនៃភាពរីកចំរើននៃប្រព័ន្ធព័ត៌មានវិទ្យាសាកល។

## ២.៤. ការងារអនុវត្តគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច

- បន្តសម្របសម្រួលជាមួយវិស័យឯកជនដើម្បីពង្រីកទីផ្សារក្នុងស្រុកតាមរយៈការពង្រឹង និងពង្រីកកិច្ចសន្យាទិញ-លក់ និងការនាំចេញទៅក្រៅប្រទេស ដោយរៀបចំឱ្យមានការចុះអនុស្សរណៈយោគយល់ ក្នុងនោះគម្រោងមាន ផែនការចុះអនុស្សរណៈយោគយល់ជាមួយបណ្ដាក្រុមហ៊ុន និងរោងម៉ាស៊ីនកិនស្រូវចំនួន ៦ ក្រុមហ៊ុនទិញបន្លែចំនួន ៥ និងក្រុមហ៊ុនផ្គត់ផ្គង់ជាតុចូលកសិកម្មចំនួន ៤បន្ថែមទៀត
- បន្តគាំទ្រ និងជួយសម្របសម្រួលកសិករខ្នាតតូច រៀបចំផែនការវិនិយោគ និងសំណើគម្រោងវិនិយោគទី១ (Window I) និងចាប់ផ្ដើមរៀបចំសម្របសម្រួលសហគ្រាសធុនតូច និងមធ្យមក្នុងការរៀបចំផែនការវិយោគ និងសំណើគម្រោងវិនិយោគទី២ (Window II) ក្នុងទំហំថវិកាប្រចាំឆ្នាំចំនួនប្រមាណមួយលានដុល្លារសហរដ្ឋអាម៉េរិក
- សម្របសម្រួលជាមួយវិស័យសាធារណៈ វិស័យឯកជន និងដៃគូអនុវត្តគម្រោងទាំងអស់ ក្នុងការជំរុញ និងពន្លឿនការអនុវត្តសកម្មភាពគម្រោងឱ្យសម្រេចបានតាមសូចនាករ និងផែនការរួមរបស់គម្រោងទាំងមូល
- រៀបចំយុទ្ធសាស្ត្រគាំទ្រតួអង្គខ្សែច្រវាក់តម្លៃ តាមរយៈការជំរុញការអភិវឌ្ឍតំបន់ប៉ូលសេដ្ឋកិច្ច ដែលបានកំណត់ទៅតាមផលិតផលកសិ-ពាណិជ្ជកម្មសក្ដានុពលទាំង៥ប្រភេទរបស់គម្រោង និងពិនិត្យលទ្ធភាព ធ្វើការសិក្សាផលិតផលកសិ-ពាណិជ្ជកម្ម សក្ដានុពល២ទៅ៣ប្រភេទទៀតបញ្ចូលទៅក្នុងគម្រោង ដើម្បីឈានចាប់យកគម្រោងដំណាក់កាលទី២ គឺពង្រីកពីគម្រោងឱ្យទៅជាកម្មវិធី AIMS ដែលគ្របដណ្ដប់លើខេត្តទាំង២៤ ដូចកម្មវិធី ASPIRE ដែលអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រៀបចំយន្តការ និងយុទ្ធសាស្ត្រដកថយ/បញ្ចប់គម្រោង ដើម្បីធានាបាននូវនិរន្តរភាព ភាពជាម្ចាស់នៅពេលបញ្ចប់គម្រោងតាមរយៈការផ្ទេរមុខងារ និងការទទួលខុសត្រូវទៅថ្នាក់ក្រោមជាតិ (មន្ទីរពាណិជ្ជកម្មខេត្តទាំង១៨)។

# ៣. អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ [13]

## ៣.១. ការធ្វើសមាហរណកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម ទ្វេភាគី អនុតំបន់ និងសមាហរណកម្មសេដ្ឋកិច្ច

- ផ្សព្វផ្សាយពីសក្ដានុពល និងអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដែលចូលជាធរមាន ដូចជាជាមួយចិន កូរ៉េ អាស៊ាន ជាដើម ដើម្បីទាក់ទាញវិនិយោគិន និងផ្ដល់ឱកាសឱ្យវិស័យឯកជនចាប់យកកាលានុវត្តភាពនេះ
- ត្រៀមរៀបចំធ្វើជាម្ចាស់ផ្ទះថ្នាក់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានក្រុមការងារជាន់ខ្ពស់ ស្ដីពីសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន និងកិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន ដែលក្រសួងពាណិជ្ជកម្ម ជាតំណាងជាតិ សម្រាប់សសរស្ដម្ភសេដ្ឋកិច្ចអាស៊ាន
- ត្រៀមរៀបចំ និងចូលរួមកិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-វៀតណាម លើកទី១២ ដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ

[13] ប្រភព៖ អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ

ក្នុងឆ្នាំ២០២២
- បន្តចរចាបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយដៃគូសំខាន់ៗមានជាអាទិ៍ឥណ្ឌា ជប៉ុន ម៉ុងហ្គោលី កាណាដា អង់គ្លេស ដើម្បីធ្វើពិពិធកម្មទីផ្សារ និងជំរុញការនាំចេញស្របតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា
- រៀបចំ និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលអាស៊ាន ស្តីពីសេវាកម្ម។

### ៣.២. ការធ្វើសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មជាមួយអឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិក

- សហការជាមួយសភាពាណិជ្ជកម្មកម្ពុជា ដើម្បីរៀបចំវេទិកាជំនួបធុរកិច្ចរវាងវិស័យឯកជនកម្ពុជា ជាមួយភាគីហុងគ្រី ក្នុងអំឡុងត្រីមាសទី១ ឆ្នាំ២០២២ តាមប្រព័ន្ធវីដេអូ
- ត្រៀមចូលរួមកិច្ចប្រជុំលើកទី៤ គណៈកម្មការចម្រុះនៃកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចរវាងកម្ពុជា-បេឡារុស នៅសាធារណរដ្ឋបេឡារុស
- បន្តតាមដាន និងទំនាក់ទំនងជាមួយភាគីរុស្ស៊ី ដើម្បីស្វែងរកលទ្ធភាព ក្នុងការចាប់ផ្តើមការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយសហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី(EAEU) ដែលជាគោលដៅមួយដែលរាជរដ្ឋាភិបាលកម្ពុជាចង់សម្រេចឱ្យបានឆាប់រហ័ស
- ពន្លឿនដំណើរការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម រវាងកម្ពុជា និងអាស៊ែបៃហ្សង់
- ត្រៀមរៀបចំជំនួបពិភាក្សាការងារជាមួយប្រទេសកាហ្សាក់ស្ថាន ក្នុងអំឡុងត្រីមាសទី១ ឆ្នាំ២០២២ តាមប្រព័ន្ធវីដេអូ និងពន្លឿនការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ច
- ត្រៀមឯកសារពាក់ព័ន្ធចូលរួមកិច្ចប្រជុំលើកទី២ នៃគណៈកម្មាធិការពាណិជ្ជកម្មចម្រុះកម្ពុជា-កូវ៉ែត នៅប្រទេសកូវ៉ែត
- ត្រៀមរៀបចំកិច្ចប្រជុំលើកទី៣ នៃគណៈកម្មការសេដ្ឋកិច្ចចម្រុះកម្ពុជា-តួកគីដែលគ្រោងនឹងធ្វើនៅកម្ពុជាក្នុងឆមាសទី២ ឆ្នាំ២០២២
- ពន្លឿនការពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងតប នៃកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចពាណិជ្ជកម្ម និងបច្ចេកទេសរវាងកម្ពុជា និងកាតា និងសេចក្តីព្រាង នៃអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម ដើម្បីឈានដល់ការចុះហត្ថលេខាក្នុងឆ្នាំ២០២២។

### ៣.៣. កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មជាមួយទ្វីបអាម៉េរិក

- បន្តសហការ និងភ្ជាប់ទំនាក់ទំនងដៃគូពាណិជ្ជកម្មរវាងកម្ពុជា និងបណ្តាប្រទេសនៅក្នុងទ្វីបអាម៉េរិក
- រៀបចំទទួលគណៈប្រតិភូក្រុមប្រឹក្សាធុរកិច្ចសហរដ្ឋអាម៉េរិក-អាស៊ាន(US-ABC) មកបំពេញទស្សនកិច្ចនៅកម្ពុជា
- ចូលរួមកិច្ចប្រជុំស្តីពី កិច្ចព្រមព្រៀងក្របខ័ណ្ឌវិនិយោគនិងពាណិជ្ជកម្ម រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហរដ្ឋអាម៉េរិកលើកទី៦ (6th TIFA) និងកិច្ចសន្ទនាស្តីពីភាពប្រកួតប្រជែង និងកំណើនសេដ្ឋកិច្ច (CGD) រវាងកម្ពុជានិងសហរដ្ឋអាម៉េរិក នៅសហរដ្ឋអាម៉េរិក
- ចុះអនុស្សរណៈយោគយល់រវាងក្រសួងពាណិជ្ជកម្ម និងការិយាល័យសម្របសម្រួលពាណិជ្ជកម្មកាណាដា TFO (Trade Facilitation Office) ដើម្បីបន្តធ្វើកិច្ចសហប្រតិបត្តិការឡើងវិញជាមួយក្រសួងពាណិជ្ជកម្ម ដោយសារតែគម្រោងកិច្ចសហប្រតិបត្តិការនេះត្រូវបានបញ្ចប់តាំងពីឆ្នាំ២០១៨

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការនាំចេញទៅប្រទេសក្នុងទ្វីបអាម៉េរិក
- សិក្សាស្រាវជ្រាវគោលនយោបាយទីផ្សារ និងផលិតផលសក្តានុពល ដែលកម្ពុជានាំចេញ ទៅបណ្តាប្រទេសនៅក្នុងទ្វីបអាម៉េរិក និងបន្តផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវពីទីផ្សារ និងគោលនយោបាយនៃប្រទេសនៅក្នុងទ្វីបអាម៉េរិក។

## ៣.៤. ការងារសមាហរណកម្មពាណិជ្ជកម្មពិភពលោក

- បន្តតាមដានការងារនិងសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធលើកិច្ចការក្នុងតារាងកម្មវិធីការងាររបស់រាជរដ្ឋាភិបាលក្នុងក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក (WTO Work Program) និងពិនិត្យលើសង្គតិភាពនៃច្បាប់ ឬសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋាននានា ដើម្បីបំពេញកាតព្វកិច្ចក្នុងនាមជាសមាជិក
- បន្តរៀបចំឯកសារ និងសម្របសម្រួល សូមគោរពជូន សម្តេចតេជោនាយករដ្ឋមន្ត្រី ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំនៃវេទិកាសេដ្ឋកិច្ចពិភពលោក (WEF) ដែលនឹងប្រព្រឹត្តទៅនៅខែមករា ឆ្នាំ២០២២ នៅប្រទេសស្វីស
- ត្រៀមរៀបចំការងារពាក់ព័ន្ធនឹង Trade Policy Review របស់កម្ពុជា
- ត្រៀមពិនិត្យ និងធ្វើបច្ចុប្បន្នភាពលើការងាររៀបចំបទប្បញ្ញត្តិសម្រាប់អនុវត្តច្បាប់ឧបាស្រ័យពាណិជ្ជកម្ម និងពិនិត្យលទ្ធភាពរៀបចំកិច្ចប្រជុំលើកទី២ នៃអនុគណៈកម្មការរៀបចំបទប្បញ្ញត្តិសម្រាប់អនុវត្តច្បាប់ឧបាស្រ័យពាណិជ្ជកម្ម ព្រមទាំងត្រៀមរៀបចំឯកសារពាក់ព័ន្ធ
- បន្តពិនិត្យ និងផ្តល់ព័ត៌មានជូនអង្គការ WTO ក្រោមមាត្រា នៃកិច្ចព្រមព្រៀងមួយចំនួនក្រោមក្របខ័ណ្ឌអង្គការ WTO
- បន្តការងារករណីលេខាធិការដ្ឋានអង្គការ WTO ស្នើសុំឱ្យផ្ទៀងផ្ទាត់ព័ត៌មានបន្ថែមក្នុងទម្រង់ថ្មី ក្រោមមាត្រា៥.១-៥.៤) និងផ្តល់តំណភ្ជាប់ទៅកាន់ច្បាប់ដើមនៃលិខិតបទដ្ឋាន ដែលបានផ្តល់ព័ត៌មានក្រោមកិច្ចព្រមព្រៀង ស្តីពីនីតិវិធីអាជ្ញាបណ្ណនាំចូលទំនិញ (Agreement on Import Licensing Procedures)។

## ៣.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងជំនួយ

- បន្តអនុវត្តន៍សមាសភាគទាំង ៤ របស់ គម្រោង Go4eCAM ស្របតាមផែនការការងារ និងផែនការថវិកាឆ្នាំ២០២២ របស់គម្រោង ពិសេសជំរុញលើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យមកម្ពុជា ចូលរួមក្នុងការនាំចេញផលិតផលខ្មែរតាមរយៈផ្សារអេឡិចត្រូនិកខេមបូឌាត្រេដ
- បន្តសហការអនុវត្តគម្រោង AIMS ដើម្បីបន្តគាំទ្រអភិវឌ្ឍន៍វិស័យទាំងប្រាំ (ស្រូវ ដំឡូងមី មាន់ បន្លែ និងសូត្រ) របស់គម្រោង
- បន្តសហការជាមួយអង្គការ GIZ ARISE Plus Cambodia អនុវត្តគម្រោងស្រាវជ្រាវស្តីពី FTA Potential Studies និង FTA Feasibility Studies ដើម្បីសិក្សាពីប្រទេសដែលបានសក្តានុពលសម្រាប់កម្ពុជាធ្វើការចរចាពាណិជ្ជកម្មសេរី និងធ្វើការវិភាគលម្អិតលើលទ្ធភាពនៃការចរចាពាណិជ្ជកម្មសេរីជាមួយប្រទេសជាដៃគូ
- បន្តតាមដាន និងត្រួតពិនិត្យពីវឌ្ឍនភាពនៃផែនការសកម្មភាពនៃយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ជាមួយអន្តរក្រសួងស្ថានប័នពាក់ព័ន្ធ ដើម្បីវាស់វែងពីអត្រាសម្រេចបានការអនុវត្តផែនការទាំងនោះ ហើយនឹងស្វែងរកកៀរគរធនធានបន្ថែមក្នុងការអនុវត្តឱ្យបានជោគជ័យ
- ត្រៀមរៀបចំធ្វើការតាមដាន និងត្រួតពិនិត្យផែនការសកម្មភាពដែលមានក្នុងយុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីត្រួតពិនិត្យ និងវាយលើអត្រានៃការអនុវត្តផែនការទាំងនោះ ហើយនឹងស្វែងរក

កៀរគរធនធានបន្ថែមក្នុងការអនុវត្តឱ្យបានជោគជ័យ
- ត្រៀមអនុវត្តគម្រោងថ្មីឈ្មោះថា "Institutional Reform of Trade Training and Research Institute (TTRI) and Development of an FTA Knowledge and National Trade Negotiation Secretariat" ដែលកបានស្នើទៅអង្គការ GIZ ក្នុងឆ្នាំ២០២១ ដើម្បីរៀបចំលេខាធិការដ្ឋានអ្នកចរចាពាណិជ្ជកម្ម និងបណ្តុះបណ្តាលសមត្ថភាពបន្ថែមទៅលើការចរចា FTA និងកិច្ចព្រមព្រៀងពាណិជ្ជកម្ម
- ត្រៀមសហការជាមួយអង្គការ Swisscontact ក្នុងការអនុវត្តគម្រោងថ្មីឈ្មោះថា "Set4SMEs" ដើម្បីតភ្ជាប់ប្រព័ន្ធបញ្ចូញទំនិញគយ(ASYCUDA) និងប្រព័ន្ធប្រៃយសនីយ៍កម្ពុជា(CDS) សម្រាប់E-commerce
- ត្រៀមសហការជាមួយអង្គការ GIZ ក្នុងការអនុវត្តគម្រោងថ្មីឈ្មោះថា "Sustainable Textile Industry in Cambodia" ដើម្បីជួយធ្វើឱ្យវិស័យនេះមាននិរន្តរភាព និងមានភាពប្រកួតប្រជែង
- ត្រៀមសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងការអនុវត្តគម្រោងថ្មីឈ្មោះថា "Enabling a Conducive Environment for the Digital Economy" ដើម្បីកសាងសមត្ថភាពដល់មន្ត្រី និងវិស័យឯកជនពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល និងបទប្បញ្ញត្តិពាក់ព័ន្ធពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

## ៤. អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម[14]

### ៤.១. ការងារពិព័រណ៍

- ត្រៀម និងបន្តរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេសចំនួន ៦ព្រឹត្តិការណ៍ នៅខេត្តក្រចេះ ត្បូងឃ្មុំ សៀមរាប បន្ទាយមានជ័យ រាជធានីភ្នំពេញ និងខេត្តព្រះសីហនុ
- ត្រៀមរៀបចំទិវាជាតិកម្ពុជា ក្នុងព្រឹត្តិការណ៍ពិព័រណ៍ពិភពលោក នាទីក្រុងឌុយបៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
- ត្រៀម និងបន្តរៀបចំចូលរួមព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្មក្រៅប្រទេសចំនួន ៣ព្រឹត្តិការណ៍ រួមមាន ពិព័រណ៍ចិន អាស៊ីខាងត្បូង នៅទីក្រុងគុនមិញ ពិព័រណ៍អាស៊ានចិន នៅទីក្រុងណាននីង ពិព័រណ៍ទំនិញនាំចូលអន្តរជាតិចិន នៅទីក្រុងសៀងហៃ
- ត្រៀមរៀបចំជំរុញការផ្សព្វផ្សាយផលិតផលសក្តានុពលខ្មែរ និងការរៀបចំជំរុញដាក់តាំងលក់ផលិតផលខ្មែរ តាមប្រព័ន្ធឌីជីថល។

### ៤.២. ការអភិវឌ្ឍទីផ្សារ

- បន្តនីតិវិធី ចុះសិក្សាគម្រោងបង្កើតផ្សារព្រំដែនកម្ពុជាចំនួន ២ទីតាំងទៀត នៅខេត្តស្វាយរៀង និងកំពត
- បន្តរៀបចំជំនួបពាណិជ្ជកម្ម និងវេទិកាពិគ្រោះយោបល់ រវាងម្ចាស់ផ្សារទំនើប ម្ចាស់ភោជនីយដ្ឋាន ប្រធានក្រុមហ៊ុននាំចេញផលិតផលខ្មែរ ជាមួយនឹងម្ចាស់ផលិតផលខ្មែរ ម្ចាស់សហគ្រាសផលិតនានា ក្នុងព្រះរាជាណាចក្រកម្ពុជា
- បន្តរៀបចំកិច្ចប្រជុំអចិន្ត្រៃយ៍ប្រចាំឆ្នាំ ជាមួយតំណាងពាណិជ្ជកម្មក្រៅប្រទេស នៅរាជធានីភ្នំពេញ និងប្រជុំតាមប្រព័ន្ធ Video Conference ប្រចាំត្រីមាសសម្រាប់តំណាងពាណិជ្ជកម្មក្រៅប្រទេស ដើម្បីធ្វើការជំរុញធុរជន និងវិនិយោគិននៅក្រៅប្រទេស មកកម្ពុជា
- បន្តរៀបចំសិក្ខាសាលា ស្តីពី "ផ្សព្វផ្សាយជូនអ្នកនាំចេញកម្ពុជា ពីព័ត៌មានទីផ្សារក្នុង និងក្រៅប្រទេស"
- បន្តរៀបចំសិក្ខាសាលា ស្តីពី "ការផ្សព្វផ្សាយ និងការបញ្ជូនផលិតផលសក្តានុពលកម្ពុជា ទៅទីផ្សារអន្តរជាតិ

[14] ប្រភព៖ អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម

- បន្តរៀបចំសិក្ខាសាលា ស្តីពី "យុទ្ធសាស្ត្រលើកកម្ពស់ផលិតផលខ្មែរ និងពង្រឹងសមត្ថភាពអ្នកផលិត និងកែច្នៃផលិតផល"
- បន្តរៀបចំវេទិកាជំរុញពាណិជ្ជកម្មកម្ពុជា នៅក្រៅប្រទេស និងបណ្តាប្រទេសផ្សេងទៀតតាមលទ្ធភាពជាក់ស្តែង
- បន្តបង្កើត និងគ្រប់គ្រងមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជានៅក្រៅប្រទេស និងចុះពិនិត្យតាមដានវឌ្ឍនភាពនៃមជ្ឈមណ្ឌលពាណិជ្ជកម្ម ដែលបានបង្កើតរួចហើយ។

## ៤.៣. ការអភិវឌ្ឍគោលនយោបាយពាណិជ្ជកម្ម

- បន្តផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីជំឡូងមី២០២០-២០២៥ តាមរយៈការរៀបចំសិក្ខាសាលានិងទិវាជាតិជំឡូងមី
- បន្តពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពី ជំឡូងមី ២០២០-២០២៥
- បន្តប្រមូល និងបូកសរុបរបាយការណ៍វាយតម្លៃការងារគោលនយោបាយជាតិជំឡូងមី ២០២០-២០២៥ ត្រីមាស ឆមាស និងពាក់កណ្តាលអាណត្តិ និងទិសដៅបន្ត ជូនទៅគណៈកម្មការសេដ្ឋកិច្ច និងវិនិយោគ
- បន្តរៀបចំបញ្ចប់សេចក្តីព្រាងគោលនយោបាយជាតិស្តីពីស្វាយចន្ទី ២០២២ - ២០២៧
- បន្តរៀបចំសេចក្តីព្រាងគោលនយោបាយជាតិស្តីពីម្រេច
- បន្តពិនិត្យតាមដានការរៀបចំបង្កើត "មជ្ឈមណ្ឌលជំរុញអភិវឌ្ឍន៍វិស័យចម្លាក់ប្រាក់-ស្ពាន់កម្ពុជា" នៅឃុំកោះចិន និងឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល
- បន្តពិនិត្យតាមដានដំណើរការ "មជ្ឈមណ្ឌលជំរុញអភិវឌ្ឍវិស័យស្មូនដីកម្ពុជា" នៅភូមិបាញ់ឆ្កោល ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង
- បន្តចុះសិក្សាលទ្ធភាពក្នុងការបង្កើត "មជ្ឈមណ្ឌលជំរុញអភិវឌ្ឍវិស័យចម្លាក់ថ្ម" នៅខេត្តពោធិ៍សាត់
- បន្តសហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាលើកិច្ចការងារអនុវត្ត និងគាំទ្រគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ២០១៥-២០២៥ (IDP)
- បន្តចូលរួមអនុវត្តការងារជំរុញចលនាភូមិ១ ផលិតផល១
- បន្តសហការជាមួយគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា
- បន្តសហការជាមួយក្រសួងរ៉ែ និងថាមពល ក្នុងការរៀបចំគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល
- បន្តសហការជាមួយលេខាធិការដ្ឋាន នៃក្រុមការងាររៀបចំយុទ្ធសាស្ត្រ IBeeC
- បន្តធ្វើបច្ចុប្បន្នភាព ពីវឌ្ឍនភាពនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន និងអន្តរជាតិ កម្មវិធីកំណែទម្រង់គោលនយោបាយក្នុងក្របខណ្ឌក្រសួង ប្រមូលព័ត៌មាន និងពិនិត្យមើលផលប៉ះពាល់ និងអត្ថប្រយោជន៍ក្រោមការអនុវត្តវិធានការបច្ចេកទេសមិនមែនពន្ធគយ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី និងពហុភាគី
- រៀបចំសិក្សាស្រាវជ្រាវ និងប្រមូលធាតុចូលចងក្រងជាឯកសារស្តីពី បរិយាកាសធុរកិច្ចនៅបណ្តាខេត្តនានា
- ពិនិត្យលទ្ធភាពស្នើពន្យារសុពលភាព MoU រវាងក្រសួង និងក្រុមហ៊ុន BRB សម្រាប់អនុវត្តន៍ការងារគាំទ្រលើវិស័យស្មូនដីកម្ពុជា
- គ្រោងរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ពាក់ព័ន្ធនឹងច្រកចូលទីផ្សារកម្ពុជា ទៅកាន់ប្រទេសជាដៃគូគោលនយោបាយអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម និងកម្មវិធីកំណែទម្រង់របស់ក្រសួង បរិយាកាសធុរកិច្ចនៅកម្ពុជា ការអនុវត្តគោលនយោបាយពាណិជ្ជកម្មលើវិស័យ SMEs ព័ត៌មានពាណិជ្ជកម្មលើផលិតផលដំណាំមានតម្លៃខ្ពស់ និងការជំរុញ IBeeC តាមបណ្តារាជធានី-ខេត្ត។

## ៤.៤.ស្ថានបេសកកម្មអចិន្ត្រៃយ៍ប្រចាំទីក្រុងហ្សឺណែវ

- បន្តបន្តស្នើសុំឱ្យ WIPO បន្តជួយបណ្តុះបណ្តាលធនធានមនុស្ស ជាពិសេសក្រោមកម្មវិធី WIPO Fellowship Program, Junior Professional Program និង Young Expert Program
- បន្តស្នើសុំឲ្យ WIPO គាំទ្រលើការបណ្តុះបណ្តាលសហគ្រាសធុនតូច និងមធ្យម ជាពិសេស
- សហគ្រិនវ័យក្មេង និងនារី លើការប្រើប្រាស់កម្មសិទ្ធិបញ្ញា ជាឧបករណ៍ដើម្បីជំរុញអាជីវកម្ម។ លើការងារនេះ ភាគី WIPO បានឯកភាពសហការជាមួយក្រសួងពាណិជ្ជកម្ម ដើម្បីរៀបចំសិក្ខាសាលាជាសេរីលើប្រធានបទ IP for Business, IP for Tourism ក៏ដូចជាឧបករណ៍ជំនួយលើកម្មសិទ្ធិបញ្ញាដែល WIPO បានរៀបចំ ដូចជា WIPO Academy ជាដើម
- បន្តចូលរួមកិច្ចប្រជុំក្រុមប្រទេសអភិវឌ្ឍន៍តិចតួចថ្នាក់ទូត ដើម្បីចូលរួមស្តាប់នូវការសង្ខេប និងពិភាក្សាទៅលើសេចក្តីព្រាងសេចក្តីសម្រេចក្នុងការស្នើសុំពន្យារពេលអនុវត្តមាត្រា៦៦.១ នៃកិច្ចព្រមព្រៀង TRIPs ដល់ក្រុមប្រទេស LDC សម្រាប់រយៈពេល១៣ ឆ្នាំ គឺចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១ ដល់ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០៣៤
- បន្តចូលរួមកិច្ចប្រជុំអគ្គក្រុមប្រឹក្សា ដើម្បីតាមដាន និងស្តាប់កិច្ចពិភាក្សាសម្រេចលើបញ្ហានានា ដើម្បីរៀបចំអនុម័តបញ្ចប់នៅក្នុងកិច្ចប្រជុំ MC 12។
- បន្តចូលរួមកិច្ចប្រជុំពិភាក្សាក្រុមតូចនៃរចនាសម្ព័ន្ធស្តីពីការសម្របសម្រួលការវិនិយោគសម្រាប់ការអភិវឌ្ឍ (IFD) ដើម្បីតាមដានកិច្ចពិភាក្សាលើប្រធានបទ Section I: Scope and General Principle នៃឯកសារ INF-IFD50-REV.6
- បន្តសកម្មភាពពិគ្រោះយោបល់ក្រុម LDC ជាមួយអ្នកវាយតម្លៃ ក្នុងការវាយតម្លៃទៅលើការលើកកម្ពស់ក្របខ័ណ្ឌសមាហរណកម្ម (EIF) ដើម្បីតាមដាន និងស្តាប់កិច្ចពិគ្រោះយោបល់ ដើម្បីប្រមូលធាតុចូល និង ស្តាប់ការធ្វើបទបង្ហាញទៅលើរបាយការណ៍ឆ្នាំ២០២១
- បន្តតាមដានលើបច្ចុប្បន្នភាពនៃកិច្ចពិភាក្សាពិគ្រោះយោបល់ទាក់ទងនឹងប្រព្រឹត្តិកម្មពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍តិចតួច នៅក្នុងការចរចាការឧបត្ថម្ភធនជលផល។
- បន្តការពិភាក្សាលើបញ្ហាការគាំទ្រក្នុងស្រុក (Domestic Support) ដោយមានការចូលរួមធ្វើបទបង្ហាញពីអ្នកជំនាញការជុំវិញបញ្ហាការគាំទ្រក្នុងស្រុក
- បន្តការសហការជាមួយគណៈកម្មាធិការកសិកម្ម ពាក់ព័ន្ធនឹងផ្នែកការគាំទ្រក្នុងស្រុក។ អង្គប្រជុំបានពិភាក្សាលើបញ្ហាប្រទាក់ក្រឡារួមមាន ប្រព្រឹត្តិកម្មពិសេស (S&DT) តម្លាភាព (Transparance) គោលការណ៍សមាមាត្រ (Proportionality Principle) និងការជ្រោមជ្រែងដល់កសិករ (Per-farmer support)
- បន្តចូលរួមកិច្ចប្រជុំក្រុម LDC ដើម្បីតាមដាន និងចូលរួមកិច្ចពិភាក្សាជុំវិញបញ្ហាពាក់ព័ន្ធនឹងដំណើរការពិគ្រោះយោបល់ទៅលើខ្លឹមសារអត្ថបទដែលរៀបចំឡើងដោយប្រធានក្រុមប្រឹក្សា TRIPS ទាក់ទងនឹងការបន្តរយៈពេលនៅក្រោមមាត្រា៦៦.១ និងការពិភាក្សាអំពីជំហានបន្ទាប់
- បន្តជួបពិភាក្សាជាមួយភាគីពាក់ព័ន្ធដើម្បីពិភាក្សាពីបញ្ហាក្នុងការបំពេញព័ត៌មានដែលជាសមិទ្ធកម្ម ស្តីពីការអនុវត្តម៉ាទ្រីសសកម្មភាពរបស់យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា (Cambodia Trade Integration Strategy) សម្រាប់ឆ្នាំ២០១៩-២០២៣ តាមការស្នើសុំរបស់ក្រសួងពាណិជ្ជកម្ម
- បន្តចូលរួមកិច្ចប្រជុំក្រុមប្រទេសអភិវឌ្ឍន៍តិចតួច (LDC) ថ្នាក់ទូត ដើម្បីតាមដានស្តាប់ពីរបាយការណ៍សង្ខេប ស្តីពីដំណើរការពិគ្រោះយោបល់ផ្នែក TRIPs ទាក់ទងនឹងសំណើសុំពន្យារពេលការអនុវត្តមាត្រា ៦៦.១ នៃកិច្ចព្រមព្រៀង TRIPs
- បន្តការពិភាក្សាជាមួយគណៈកម្មាធិការថវិកា ហិរញ្ញវត្ថុ និងរដ្ឋបាល ដើម្បីតាមដានស្តាប់របាយការណ៍

ពាក់ព័ន្ធ នឹងបច្ចុប្បន្នភាពការងាររបស់គណៈកម្មាធិការ និងរបាយការណ៍ជុំវិញការបង្កើតនិងគ្រប់គ្រងមូលនិធិទំនុកចិត្ត អង្គការ WTO

- បន្តការពិភាក្សាផ្លាស់ប្តូរយោបល់លើឯកសារព្រាងរបស់ប្រធានអង្គប្រជុំ TN/RL/W/276 លើប្រធានបទសសរស្តម្ភនៃការនេសាទខុសច្បាប់ ការនេសាទមិនបាន រាយការណ៍ និងការនេសាទដោយមិនមានការអនុញ្ញាត (IUU)។

## ៥. អគ្គនាយកដ្ឋានកិច្ចការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ ក.ប.ប"[15]

- ពង្រឹងប្រសិទ្ធភាពឃ្លាំពិនិត្យទីផ្សារ ដើម្បីការពារផលប្រយោជន៍អ្នកប្រើប្រាស់ ទាំងផលប្រយោជន៍ផ្នែកសុខុមាលភាព និងផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច
- ពង្រឹងប្រសិទ្ធភាពនៃការត្រួតពិនិត្យទំនិញនាំចូលក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការជាមួយអន្តរស្ថាប័ន
- ពង្រឹងកិច្ចសហការណ៍ ចូលរួមអនុវត្តសកម្មភាពការងារ ក្នុងតំបន់ និងអន្តរជាតិ
- ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ ឱ្យមានលក្ខណៈសម្បត្តិបច្ចេកទេសសមស្របតាមស្តង់ដារអន្តរជាតិ ISO-17025
- កិច្ចការកសាងគោលនយោបាយ ច្បាប់ បទប្បញ្ញត្តិបច្ចេកទេស និងការពង្រឹងសមត្ថភាពបច្ចេកទេស
- ពង្រឹងក្របខណ្ឌស្ថាប័ន និងធ្វើឱ្យប្រសើរ និងមានប្រសិទ្ធភាព នៃដំណើរការអនុវត្តកិច្ចការការពារសិទ្ធិ និងផលប្រយោជន៍របស់អ្នកប្រើប្រាស់។

## ៦. អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ[16]

### ៦.១. ការងារគណនេយ្យ

- រៀបចំផែនការយុទ្ធសាស្ត្រថវិកា និងរៀបចំគម្រោងផែនការថវិការបស់ក្រសួងឆ្នាំ២០២៣
- ចូលរួមចរចា និងការពារគម្រោងថវិការបស់ក្រសួងឆ្នាំ២០២៣
- រៀបចំប្រកាសរួមស្តីពី"ការបង្កើតរជ្ជទេយ្យចំណូល ក្រសួងពាណិជ្ជកម្មឆ្នាំ២០២២"
- រៀបចំប្រកាសអាណាប័កផ្ទេរសិទ្ធិ រដ្ឋបាលកណ្តាល និងរាជធានី ខេត្ត
- រៀបចំបង់ និងបង្វែរចំណូលថវិកាទៅតាមជំពូក គណនី អនុគណនី
- រៀបចំសំណើការចំណាយប្រចាំខែ ត្រីមាស និងរបាយការណ៍ចំណូលប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ពិនិត្យនិងដោះស្រាយសំណើថវិកាតាមបណ្តាអង្គភាពរៀបចំរបាយការណ៍ត្រួតពិនិត្យថវិកាពាក់កណ្តាលឆ្នាំ លើកកម្មវិធីចំណូល ចំណាយថវិកាប្រចាំត្រីមាស ឆមាស និងឆ្នាំ
- រៀបចំទូទាត់ចំណាយប្រាក់រង្វាន់លើកទឹកចិត្តតាមសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំផ្ទៀងផ្ទាត់ចំណូល ចំណាយប្រចាំឆ្នាំ២០២១ ជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ
- បន្តចូលរួមពិនិត្យ និងសម្របសម្រួលក្នុងការកែសម្រួលកម្រងសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម
- រៀបចំប្រកាសអន្តរក្រសួង និងលក្ខខណ្ឌវិនិច្ឆ័យសម្រាប់បង្កើតអង្គភាពថវិកា
- រៀបចំបញ្ជីសារពើភ័ណ្ឌ ដោយបញ្ចូលអគារដែលទើបសាងសង់ហើយក្នុងបញ្ជី និងធ្វើរបាយការណ៍បូកសរុបបញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំ២០២១ និងចូលរួមគណៈកម្មការដើម្បីផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌ
- បន្តពិនិត្យឡើងវិញនូវកិច្ចសន្យាជួលទីតាំងរបស់ក្រសួង និងជំរុញរៀបចំធ្វើបណ្ណកម្មសិទ្ធិអចលនទ្រព្យ
- ចូលរួមត្រួតពិនិត្យ និងតាមដានការបង់ចំណូល និងបំណុលដែលមានភាពយឺតយ៉ាវ

---

[15] ប្រភព៖ អគ្គនាយកដ្ឋានក.ប.ប.

[16] ប្រភព៖ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

- ចូលរួមអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋតាមប្រព័ន្ធព័ត៌មានវិទ្យា។

### ៦.២. ការងារបុគ្គលិក

- បន្តសហការជាមួយដៃគូអភិវឌ្ឍន៍ធនធានមនុស្សនានា ទាំងក្នុង និងក្រៅប្រទេស ដើម្បីផ្តល់ឱកាសដល់មន្ត្រីក្រសួងពាណិជ្ជកម្មទទួលបានការបណ្តុះបណ្តាលដែលមានគុណភាព ក្នុងគោលបំណងបង្កើនសមត្ថភាព និងផលិតភាពការងារ
- បន្តរៀបចំវគ្គបណ្តុះបណ្តាលពាក់ព័ន្ធ នឹងការពង្រឹងសមត្ថភាពមន្ត្រីរាជការក្រសួងពាណិជ្ជកម្ម ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីរាជការ និងសំណុំឯកសារពាក់ព័ន្ធនានារបស់មន្ត្រីរាជការម្នាក់ៗនៅតាមអង្គភាពនីមួយៗ ដើម្បីរៀបចំគ្រប់គ្រងទិន្នន័យមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យា
- រៀបចំបែងចែកមន្ត្រីក្របខ័ណ្ឌថ្មី និងចាត់បញ្ជូនឱ្យធ្វើកម្មសិក្សាទៅតាមជំនាញ
- រៀបចំឯកសារពាក់ព័ន្ធនឹងការវាយតម្លៃផ្តល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការមានស្នាដៃប្រចាំឆ្នាំ២០២១
- បន្តធ្វើចលនាផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងគ្រួសាររបស់មន្ត្រីរាជការស៊ីវិលនៃក្រសួងពាណិជ្ជកម្ម
- បន្តរៀបចំធ្វើសំណើសុំបង្វែរថវិកាចូលក្នុងគណនីរបស់ធនាគារកាណាឌីយ៉ា ក.អ ដើម្បីបើកប្រាក់បៀវត្សជូនមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៃក្រសួងពាណិជ្ជកម្ម ឱ្យទាន់ពេលវេលា ស្របតាមគោលការណ៍ដែលត្រូវបើកបៀវត្សជូនមន្ត្រីរាជការស៊ីវិលចំនួន ២ដង ក្នុងមួយខែ
- បន្តរៀបចំធ្វើសំណើសុំបង្វែរថវិកាចូលក្នុងគណនីរបស់ធនាគារកាណាឌីយ៉ា ក.អ ដើម្បីបើកប្រាក់ឧបត្ថម្ភចូលនិវត្តន៍និងសម្រាលមាតុភាពជូនមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៃក្រសួងពាណិជ្ជកម្មឱ្យស្របតាមគោលការណ៍
- បន្តរៀបចំរបាយការណ៍បច្ចុប្បន្នភាពមន្ត្រីរាជការដែលបើកគណនីបៀវត្សតាមប្រព័ន្ធធនាគារ
- បន្តធ្វើរបាយការណ៍ក្របខណ្ឌប្រចាំខែឱ្យបានទៀងទាត់ និងទាន់ពេលវេលា
- បន្តធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការនៅតាមមន្ទីររាជធានី-ខេត្ត
- រៀបចំបែបបទឯកសារ ស្នើសុំដំឡើងឋានន្តរស័ក្តិ និងថ្នាក់តាមវេនជូនមន្ត្រីរាជការសម្រាប់ឆ្នាំ២០២២
- ត្រៀមរៀបចំសំណុំឯកសារស្នើសុំពិនិត្យសលាកប័ត្រព័ត៌មានមន្ត្រីរាជការស្តេនរូបយកស្នាមមេដៃជូនមន្ត្រីរាជការស៊ីវិលចំនួន ៣៦នាក់ សម្រាប់ក្របខណ្ឌឆ្នាំ២០២១។

### ៦.៣. ការងាររដ្ឋបាល

- រៀបចំរបាយការណ៍បូកសរុបសកម្មភាពការងារពាណិជ្ជកម្ម របស់ក្រសួង ជាប្រចាំ ជូនទីស្តីការគណៈរដ្ឋមន្ត្រី
- រៀបចំសន្និបាតបូកសរុបការងារពាណិជ្ជកម្ម និងទិសដៅការងារពាណិជ្ជកម្មប្រចាំឆ្នាំបន្ត
- ចាត់ចែងការងារពិធីការ និងបដិសណ្ឋារកិច្ចផ្សេងៗ ក្នុងការរៀបចំបន្ទប់ សាលប្រជុំ និងរៀបចំពិធីបុណ្យ/ឬ ទិវាបុណ្យជាតិ និងអន្តរជាតិនានា
- គ្រប់គ្រងចរាចរលិខិតចេញ ចូល ឯកសាររដ្ឋបាលផ្សេងៗ រៀបចំលិខិតអញ្ជើញ ទទួល និងចែកលិខិត
- ធ្វើផែនការជួសជុលអគារ កែលម្អសោភ័ណភាពទូទៅក្នុង និងបរិវេណទីស្តីការក្រសួងពាណិជ្ជកម្ម
- ពង្រឹងការគោរពបទបញ្ជាផ្ទៃក្នុង និងថែរក្សាសណ្តាប់ធ្នាប់ សន្តិសុខសុវត្ថិភាព អនាម័យ សួនច្បារ ទឹក ភ្លើងក្នុងបរិវេណខាងក្នុងទីស្តីការក្រសួង
- ពង្រឹងការអនុវត្តឱ្យបានម៉ឺងម៉ាត់តាមវិធានការណែនាំរបស់ក្រសួងសុខាភិបាល សំដៅការពារទប់ស្កាត់នូវការរីករាលដាលឆ្លង នៃជំងឺកូវីដ-១៩។

### ៦.៤. ការងារវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ

- បន្តការសរសេរអត្ថបទស្រាវជ្រាវ លើមុខទំនិញសក្តានុពល សម្រាប់ការនាំចេញទាក់ទងនឹងវិស័យពាណិជ្ជកម្ម

និងកសិកម្ម

- បន្តការរៀបចំការអភិវឌ្ឍកម្មវិធីសិក្សា ឱ្យកាន់តែមានគុណភាពជូនមន្ត្រីរាជការក្រសួងពាណិជ្ជកម្ម និងវិស័យឯកជន
- បន្តសហការជាមួយ GIZ ក្រោមគម្រោង ARISE Plus Cambodia រៀបចំសិក្ខាសាលាជាស៊េរីកសាងសមត្ថភាពជូនដល់មន្ត្រីរាជការក្រសួងពាណិជ្ជកម្ម
- បន្តស្វែងរកដៃគូទាំងក្នុងនិងក្រៅប្រទេសដើម្បីរៀបចំវគ្គបណ្តុះបណ្តាលជូនមន្ត្រីរាជការក្រសួងពាណិជ្ជកម្ម។

## ៧. ក្រុមហ៊ុនគ្រីនត្រេដ [17]

### ក. ផែនការអាជីវកម្មឆ្នាំ ២០២២

❖ **ផែនការទិញចូលឆ្នាំ ២០២២**

- បរិមាណគ្រោងទិញអង្ករចូល ៤ ៧០០តោន សរុបទឹកប្រាក់ ១០ ៣២០ ១១០ ០០០៛
- បរិមាណគ្រោងទិញសំបកការ៉ុង ៧២ ៨០០សំបក សរុបទឹកប្រាក់ ៨៣ ៥៧៤ ៤០០៛

❖ **ផែនការលក់ចេញឆ្នាំ ២០២២**

- បរិមាណគ្រោងលក់អង្ករចេញ ៤ ៧០០តោន ទឹកប្រាក់សរុប១១ ២៥៧ ៥៧៥ ០០០៛។

### ខ. សន្និធិស្បៀងត្រៀមបម្រុងឆ្នាំ ២០២២

- ក្រុមហ៊ុនគ្រីនត្រេដ ត្រូវបានអនុញ្ញាតឱ្យរក្សាទុកសន្និធិស្តុកស្បៀងត្រៀមបម្រុងជាអង្ករ ត្រឹមចំនួន ៣ ០០០តោន នៅឃ្លាំងស្តុកក្រុមហ៊ុនគ្រីនត្រេដ ដោយឡែកសន្និធិស្បៀងបម្រុងជាយុទ្ធសាស្ត្រផ្សេងទៀតជារូបវន្តត្រូវរក្សាទុកក្នុងក្រុមហ៊ុនផ្គត់ផ្គង់ជាដៃគូ ដែលអាចផ្គត់ផ្គង់បានទាន់ពេលវេលា ក្នុងករណីមានតម្រូវការប្រើប្រាស់ពីរាជរដ្ឋាភិបាល
- ថវិកាទ្រទ្រង់ស្តុកត្រៀមបម្រុងយុទ្ធសាស្ត្រជាអង្ករឆ្នាំ២០២២ រាជរដ្ឋាភិបាលបានផ្អាកក្នុងការផ្តល់កញ្ចប់ថវិកាទិញប្រចាំឆ្នាំ ជូនក្រុមហ៊ុនគ្រីនត្រេដ ដោយរក្សាទុកសន្និធិស្បៀងបម្រុងជាសាច់ប្រាក់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ទិញអង្ករប្រើប្រាស់ក្នុងករណីមានការប្រើប្រាស់ជាបន្ទាន់។

## ៨. អគ្គាធិការដ្ឋាន [18]

- ពង្រឹងការចុះធ្វើអធិការកិច្ច និងអធិការកិច្ចដោយមិនជូនដំណឹងមុន (Spot Check) នៅតាមអង្គភាពចំណុះទីស្តីការក្រសួងពាណិជ្ជកម្ម និងមន្ទីររាជធានី-ខេត្ត ចំនួន ៥០អង្គភាព ដោយបែងចែកជា ៤ត្រីមាសៈ ត្រីមាសទី១ ចំនួន ១២អង្គភាព ត្រីមាសទី២ ១៤អង្គភាព ត្រីមាសទី៣ ១២អង្គភាព និងត្រីមាសទី៤ ចំនួន ១២អង្គភាព
- អង្កេត តាមដាន និងវាយតម្លៃលើការកែលម្អ/កែតម្រូវតាមអនុសាសន៍គ្រាមុន របស់ប្រតិភូអធិការកិច្ច/សវនកម្មចំនួន ២៥អង្គភាព ក្នុងចំណោមអង្គភាពចំណុះក្រសួងពាណិជ្ជកម្ម និងមន្ទីររាជធានី-ខេត្ត
- ពង្រឹងយន្តការទទួលព័ត៌មានត្រឡប់ (feedback) និងដោះស្រាយបណ្តឹងតវ៉ារបស់អ្នកទទួលសេវាដោយបង្កើត ប្រអប់ផ្តល់មតិនិងទទួលពាក្យបណ្តឹង និងគេហទំព័ររបស់អគ្គាធិការដ្ឋាន ដើម្បីពង្រឹងការផ្សព្វផ្សាយ ការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា
- ពង្រឹងយន្តការតាមដាន ពិនិត្យ និងវាយតម្លៃលើការផ្តល់សេវាសាធារណៈ ដោយធ្វើអធិការកិច្ចលើការផ្តល់សេវា តាមប្រព័ន្ធអេឡិកត្រូនិក ដើម្បីរួមចំណែកជំរុញកិច្ចសម្រួលពាណិជ្ជកម្ម
- បន្តតាមដាន និងដោះស្រាយវិវាទក្នុងការតែងតាំងអនុប្រធានមន្ទីរពាណិជ្ជកម្មខេត្តស្ទឹងត្រែង រួមទាំងវិវាទ

[17] ប្រភពៈ ក្រុមហ៊ុន គ្រីនត្រេដ

[18] ប្រភពៈ អគ្គាធិការដ្ឋាន

នានាពាក់ព័ន្ធវិស័យពាណិជ្ជកម្ម ក្រោមឱវាទក្រសួងពាណិជ្ជកម្ម

- រៀបចំវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីអគ្គាធិការដ្ឋានចំនួន ១៨លើក។

**៩. នាយកដ្ឋានសវនកម្មផ្ទៃក្នុង** [19]

- បន្តចុះធ្វើសវនកម្មលើប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋ ការផ្តល់សេវាសាធារណៈ និងការអនុវត្តអនុលោមតាមច្បាប់ បទប្បញ្ញត្តិ រាល់ប្រតិបត្តិការឆ្នាំ២០២១ និងឆ្នាំពាក់ព័ន្ធនៅតាមអង្គភាពក្រោមឱវាទក្រសួងពាណិជ្ជកម្មចំនួន ៥៧សវនដ្ឋាន៖ អង្គភាពថ្នាក់កណ្តាលចំនួន ១១សវនដ្ឋាន និងអង្គភាពថ្នាក់មូលដ្ឋានចំនួន ៤៦សវនដ្ឋាន
- បន្តលើកទឹកចិត្តមន្ត្រី ពង្រឹងសមត្ថភាពជំនាញ និងវិជ្ជាជីវៈរបស់ខ្លួន តាមរយៈការចូលរួមក្នុងវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាផ្សេងៗ
- បន្តរៀបចំកិច្ចប្រជុំផ្ទៃក្នុង ដើម្បីជំរុញ និងពង្រឹងការគោរពវិន័យការងារ សាមគ្គីភាពផ្ទៃក្នុង ការចែករំលែកបទពិសោធន៍ ដើម្បីជំរុញការងារសវនកម្មផ្ទៃក្នុងឱ្យកាន់តែទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផលល្អ។

ថ្ងៃសុក្រ ១៣កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន_សូរស័ក្តិ**

[19] ប្រភព៖ នាយកដ្ឋានសវនកម្មផ្ទៃក្នុង